# វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

# Advocacy and Policy Institute



# របាយការណ៍ប្រចាំឆ្នាំ២០១៩

ម្ចាស់ជំនួយ និងដៃគូ

# មាតិការ


១.អំពីវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ .......... 4

២.លទ្ធផលប្រចាំឆ្នាំ២០១៩ .......... 10

*សមទ្ធិផលសមាសភាគទី១៖ធ្វើអោយមានឥទ្ធិពលលើគោលនយោបាយ និងការអនុវត្ត ដើម្បីដោះស្រាយសិទ្ធិ និងសេចក្តីត្រូវការរបស់ពលរដ្ឋជាពិសេសយុវជន ស្ត្រី និងក្រុមងាយរងគ្រោះ ដើម្បីអនុវត្តសិទ្ធិរបស់ពួកគេប្រកបដោយសុវត្ថិភាព* .......... **10**

លទ្ធផលគម្រោងទី ១៖ សំឡេង និងសកម្មភាពរបស់ពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅប្រទេសកម្ពុជា .......... 10

លទ្ធផលគម្រោងទី២៖ ការពិភាក្សារបស់យុវជនអំពីការកសាងច្បាប់សិទ្ធិទទួលព័ត៌មាន .......... 11

លទ្ធផលគម្រោងទី៣៖ កិច្ចសន្ទនាយុវវ័យក្នុងគោលនយោបាយបង្កើតច្បាប់ និងការអនុវត្តច្បាប់ការងារដែលទាក់ទងទៅនឹងយុវជន .......... 15

លទ្ធផលគម្រោងទី៤៖ លេខាធិការដ្ឋានសម្ព័ន្ធភាពដៃគូការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ .......... 18

*សមទ្ធិផលសមាសភាគទី២៖លើកកម្ពស់ភាពអង់អាចរបស់ប្រជាពលរដ្ឋ ជាពិសេសយុវជនក្រុមស្ត្រី និងក្រុមដែលងាយរងគ្រោះ ចង់ឱ្យរដ្ឋាភិបាលមានគណនេយ្យភាពចំពោះការសម្រេចចិត្ត និងសកម្មភាពឆ្លើយតប ដើម្បីកែលម្អសេវាកម្ម សាធារណៈនិងការអនុវត្តគោលនយោបាយនៅថ្នាក់ក្រោមជាតិ។* .......... **20**

លទ្ធផលគម្រោងទី៥៖ លើកកម្ពស់ សិទ្ធិ សម្លេង ជម្រើស និងការសម្រេចចិត្តប្រជាពលរដ្ឋ .......... 20

លទ្ធផលគម្រោងទី ៦៖ ការលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យមូលដ្ឋាននៅ .......... 36

លទ្ធផលគម្រោងទី៧ ៖ ប្រជាពលរដ្ឋក្នុងក្របខណ្ឌគនេយ្យភាពសង្គម " ២០១៩ដល់២០២០ .......... 39

លទ្ធផលគម្រោងទី៨៖ សម្លេងរបស់ជនមានពិការភាពក្នុងសកម្មភាពគណនេយ្យភាពសង្គម» .......... 48

លទ្ធផលគម្រោងទី៩ ៖ លើកកម្ពស់ការចូលរួមរបស់យុវជន ដំណើរការរៀបចំផែនការ និងថវិការដ្ឋបាលឃុំសង្កាត់ ២០១៩ - ២០២១ .......... 52

លទ្ធផលគម្រោងទី១០ ៖ គំពេងះពង្រឹងគណនេយ្យភាពការិយាល័យច្រកចេញចូលតែមួយ .......54

លទ្ធិផលគម្រោងទី១១៖កសាងសមត្ថភាពអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាស្តីពីជំនាញការកៀរគរការគាំទ្រ និង ការកៀរគរធនធានក្នុងស្រុក.......................................................................57

**សមទ្ធិផលសមាសភាគទី ៣៖ ធ្វើអោយប្រសើរឡើងក្នុងការទទួលបានព័ត៌មាន និងការបើកចំហព័ត៌មានសាធារណៈស្តីពីបញ្ហាសំខាន់ៗចាប់ពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ។ ..................................61**

លទ្ធផលគម្រោងទី១២. ពង្រឹងសមត្ថភាពស្ថាប័ន និងការអនុវត្តសមាជិកសមាគមន៍ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្ត/ក្រុង..........................................................................................................................64

# ១.អំពីវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) គឺជាអង្គការកសាងសមត្ថភាពកម្ពុជាឈានមុខគេ ក្នុងវិស័យតស៊ូមតិ ឥទ្ធិពលគោលនយោបាយ ការចូលរួមរបស់ប្រជាពលរដ្ឋ និងអភិបាលកិច្ចល្អ។

**បេសកកម្ម** API គឺជាអង្គការមិនមែន រដ្ឋាភិបាល មិនរកប្រាក់ចំណេញមួយ ដែលមានបេសកកម្ម ដើម្បីបំពេញតម្រូវការអភិវឌ្ឍន៍ប្រជាធិបតេយ្យ និងសង្គមរយៈពេលវែង របស់ប្រទេសកម្ពុជា តាមរយៈការពង្រឹងអំណាចប្រជាពលរដ្ឋ ឱ្យមានទំនាក់ទំនង ជាមួយរដ្ឋាភិបាល ដើម្បីការពារសិទ្ធិ និងបំពេញតម្រូវការរបស់ពួកគេ។ ជាពិសេស តាមរយៈផែនការយុទ្ធសាស្រ្តរបស់ខ្លួន ២០១៩~២០២៣ អង្គការ API នឹងចូលរួមជាមួយស្ត្រី យុវជន និងក្រុមប្រជាពរដ្ឋដែលជួបការលំបាក មានដូចជាប្រជាពលរដ្ឋក្រីក្រ ជនពិការ ជនជាតិដើមភាគតិច និងកុមារនៅក្រៅសាលារៀន។

កម្មវិធី API គឺផ្តោតទៅលើះ

- អនុវត្តន៍ជំនាញផ្នែកគោលនយោបាយរបស់ API លើ ៖ ក្នុងការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មានសាធារណៈ ជាធាតុសំខាន់នៃអភិបាលកិច្ចល្អ។ លើកកម្ពស់សុវត្ថិភាពចរាចរណ៍តាមរយៈការជម្រុញការអនុវត្តច្បាប់ចរាចរណ៍ឆ្នាំ ២០១៥ ។ ហើយនិងការតស៊ូមតិដើម្បីផ្ទេរនូវមុខងារមួយចំនួនរបស់រដ្ឋាភិបាលទៅថ្នាក់មូលដ្ឋាន និងការត្រួតពិនិត្យដើម្បីធានាគណនេយ្យភាពសង្គមរបស់អ្នកផ្តល់សេវា។
- ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី យុវជន និងក្រុមប្រជាពលរដ្ឋដែលជួបការលំបាក ដើម្បីបង្ហាញពីការព្រួយបារម្ភរបស់ពួកគេ និងចង់ឱ្យរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវគណនេយ្យភាពចំពោះការសម្រេចចិត្តនិងសកម្មភាពរបស់ខ្លួន។
- លើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន និងការបើកចំហព័ត៌មានសាធារណៈ អំពីបញ្ហាសំខាន់ៗ ចាប់ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ។

អង្គការ API ធ្វើការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដែលចែករំលែកនូវតម្លៃរបស់យើង ក្នុងការតស៊ូមតិដើម្បីការផ្លាស់ប្តូរសង្គមជាវិជ្ជមាន និងសន្តិភាព ហើយនិងដើម្បីលើកកម្ពស់សមត្ថភាព និងកិច្ចសហប្រតិបត្តិការសម្រាប់ប្រជាជនកម្ពុជាទាំងមូល។ ភាពខ្លាំងរបស់ API គឺឈរលើការកសាងស្ពានចម្លង រវាងរដ្ឋាភិបាល ទៅកាន់ប្រជាពលរដ្ឋ និងវិស័យឯកជន ចាប់ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ

ស្របតាមគោលបំណងរបស់យើង ក្នុងការបង្កើនលំហប្រជាធិបតេយ្យនៅកម្ពុជា ដោយបង្កើតឱ្យមានការតស៊ូមតិប្រកបដោយប្រសិទ្ធភាព និងស្ថាប័នរដ្ឋាភិបាលប្រកបដោយទំនួលខុសបន្ថែមទៀត។

ចាប់តាំងពីការបង្កើតដំបូងរបស់យើងនៅឆ្នាំ ២០០៣ អង្គការAPI ត្រូវគេបានស្គាល់ថាជាស្ថាប័នបណ្តុះបណ្តាលផ្នែកការតស៊ូមតិដល់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ការផលិតឯកសារបោះពុម្ពផ្សាយឱ្យកាន់តែទូលំទូលាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីការតស៊ូមតិ សកម្មភាពចូលរួមជាច្រើនទៀតក្នុងការជម្រុញនិងរួមចំណែកដល់ការបំពេញកំណែទម្រង់វិមជ្ឈការរបស់រដ្ឋាភិបាល ហើយនិងយុទ្ធនាការដ៏ជោគជ័យផ្សេងទៀតទៅលើចំពោះដំណើរការតាក់តែងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានសាធារណៈ និងការបើកចំហព័ត៌មានសារណៈ (សេចក្តីព្រាងនេះ ត្រូវបានបញ្ចប់ទៅកាលពីឆ្នាំ ២០១៨) និង ច្បាប់ចរាចរណ៍ផ្លូវគោក (ដែលបានអនុម័តកាលពីឆ្នាំ២០១៥)។ អង្គការ API បានទទួលការឆ្លើយតបជាវិជ្ជមានពីអង្គការជាតិ និងអន្តរជាតិចំពោះភាពជឿជាក់ភាពពាក់ព័ន្ធនិងវិជ្ជាជីវៈរបស់ខ្លួន។

## ផែនការយុទ្ធសាស្រ្ត API ឆ្នាំ ២០១៩-២០២៣

ក្នុងផែនការយុទ្ធសាស្រ្តលើកទី ៤ សម្រាប់រយៈពេលពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៣ អង្គការ API បានអនុវត្តគោលដៅយុទ្ធសាស្រ្តនៃការលើកកម្ពស់សិទ្ធិ និងសម្លេងប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជាដោយផ្តោតលើស្រ្តីយុវវ័យ និងក្រុមដែលជួបការលំបាកប្រជាពលរដ្ឋក្រីក្រ ជនពិការ ជនជាតិដើមភាគតិច និងកុមារនៅក្រៅសាលារៀន។

ដើម្បីឈានទៅរកការសម្រេចបានគោលដៅនេះ អង្គការ API បន្តខិតខំធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានព័ត៌មានសាធារណៈរបស់ប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាននិងតាមដានការផ្តល់សេវាសាធារណៈ និងដើម្បីអភិវឌ្ឍសមត្ថភាពសង្គមស៊ីវិលនិងចូលរួមក្នុងការតស៊ូមតិនិង គោលនយោបាយមានឥទ្ធិពល។ អង្គការ API បន្តបង្កើតភាពខ្លាំងក្លាតែមួយគត់របស់ខ្លួនដើម្បីកសាងសមត្ថភាពសម្រាប់ការផ្លាស់ប្តូរ និងដើម្បីភ្ជាប់ទំនាក់ទំនងសម្លេងពលរដ្ឋសហគមន៍ សង្គមស៊ីវិល និងការទាមទារឱ្យមានគោលនយោបាយជាតិល្អដែលលើកកម្ពស់សិទ្ធិនិងឆ្លើយតបតម្រូវការរបស់ពួកគេ។ ដើម្បីគាំទ្រដល់សហគមន៍ សង្គមស៊ីវិល និងរដ្ឋាភិបាលមូលដ្ឋានដើម្បីយល់ដឹងនិងបំពេញសិទ្ធិរបស់ប្រជាពលរដ្ឋនិងគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីទទួលបានព័ត៌មានសាធារណៈសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងអភិបាលកិច្ចមូលដ្ឋាន និងការតស៊ូមតិដើម្បីលើកកម្ពស់សិទ្ធិនិងដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។

ការពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធនិងការឆ្លុះបញ្ចាំងពីបរិយាកាសនយោបាយសេដ្ឋកិច្ចសង្គម និង បច្ចេកវិទ្យាដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សនិងសមិទ្ធផលថ្មីៗនិងបញ្ហាប្រឈមនានាបាននាំឱ្យមាន ការផ្លាស់ប្តូរក្រុមនិងយុទ្ធសាស្ត្រគោលដៅ។ ប្រជាជនពីរភាគបីនៃប្រជាជនសុរបនៅកម្ពុជាដែលមាន អាយុក្រោម ៣៥ ឆ្នាំ និងភាគច្រើនជាក្រុមដែលជួបការលំបាក ហើយពួកគេក្លាយជាចំណុចសំខាន់នៃ កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពរបស់ API ក្នុងផែនការយុទ្ធសាស្ត្រថ្មី។ ការពង្រឹងសិទ្ធិទទួលបាន ព័ត៌មាននៅកម្រិតថ្នាក់ក្រោមជាតិបានដំណើរការល្អ ហើយឧទាហរណ៍ក្លាយជាផ្នែកសំខាន់នៃ ក្របខ័ណ្ឌគណនេយ្យភាពសង្គម (I-SAF) ហេតុដូច្នេះ API ចង់ពង្រឹងសិទ្ធិទទួលបានព័ត៌មាន លើបញ្ហា សំខាន់ៗ ដូចជាការបើកចំហព័ត៌មានស្តីពី ថវិកាសាធារណៈ កិច្ចសន្យារវាងស្ថាបន័សាធារណៈនិងក្រុម ហ៊ុនឯកជន ផែនការវិនិយោគវិស័យឯកជន និងការទទួលបាននិងប្រើប្រាស់សិទ្ធិក្នុងការគ្រប់គ្រង ធនធានធម្មជាតិ។ API បន្តគាំទ្រមធ្យោបាយនានាដែលត្រូវការចាំបាច់សម្រាប់អង្គការនិងបណ្តាញ ពលរដ្ឋត្រូវប្រើប្រាស់ដើម្បីការពារលំហ និងយន្តការសម្រាប់ការចូលរួម និងការបញ្ចេញមតិយោបល់ ផ្សេងៗរបស់សង្គមស៊ីវិល។ ហើយបន្ទាប់ពីទទួលបានជោគជ័យក្នុងការផ្តល់ធាតុចូលលើការធ្វើសេចក្តី ព្រាងច្បាប់និងគោលនយោបាយនានា API បន្តការសិក្សាមេរៀនទាំងនេះ និងពង្រឹងសមត្ថភាព តាម ដានការអនុវត្តគោលនយោបាយ។

វិធីសាស្ត្ររបស់ API គឺយកសិទ្ធិមនុស្សជាមូលដ្ឋាន ហើយមានគោលបំណងដើម្បីបំពេញនូវសិទ្ធិរបស់ ប្រជាពលរដ្ឋជាពិសេសស្ត្រីយុវជននិងក្រុមដែលជួបការលំបាក។ និងសម្រាប់ការពង្រឹងភាពអង់អាច ដល់ពួកគេ និងពួកគេអាចលើកឡើងពីការទាមទារនិងកង្វល់នានារបស់ពួកគេជាមួយរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធដទៃទៀតនិងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។ API លើកម្ពស់សមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាចដល់យុវជន និងការដាក់បញ្ចូលក្រុមដែលជួបការ លំបាកគ្រប់កម្មវិធីទាំងអស់។

គោលដៅយុទ្ធសាស្ត្ររបស់ API សម្រាប់ឆ្នាំ ២០២៣ កំពុងរួមចំណែកដល់ចក្ខុវិស័យរបស់API គឺ ប្រជា ជាតិកម្ពុជាដែលមានការកាត់បន្ថយភាពក្រីក្រ និងការពារសិទ្ធិមនុស្ស បង្កើតវប្បធម៌ជាតិមួយដែលមាន ស្ថេរភាព ប្រជាធិបតេយ្យ នយោបាយ និងសេដ្ឋកិច្ចប្រកបដោយចីរភាព។ API ចូលរួមសម្រេចគោល ដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ជាពិសេស គោលដៅទី១៦ "លើកកម្ពស់សង្គមប្រកបដោយ សន្តិភាពនិងបរិយាបនសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា និងកសាងស្ថាប័នដែលមានប្រសិទ្ធិភាព គណនេយ្យភាពនិងបរិយាបនគ្រប់លំដាប់ថ្នាក់។"

គោលដៅយុទ្ធសាស្ត្រចំនួន ៣ រួមចំណែកដល់គោលដៅយុទ្ធសាស្ត្រ។ វាជាបញ្ហាដែលត្រូវដោះស្រាយ និងអន្តរាគមន៍ដើម្បីសម្រេចបាន គឺ៖

1) ដើម្បីជះឥទ្ធិពលលើគោលនយោបាយនិងការអនុវត្តដើម្បីលើកកម្ពស់សិទ្ធិនិងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសយុវជន ក្រុមស្ត្រី និងក្រុមដែលជួបការលំបាកនិងធានាបាននូវលំហប្រជាធិបតេយ្យសម្រាប់អនុវត្តសិទ្ធិរបស់ពួកគេ។
   ឆ្លើយតបទៅនឹងភាពខ្វះខាតនៅក្នុងច្បាប់គោលនយោបាយនិងជាពិសេសការអនុវត្តច្បាប់ ក៏ដូចជាការខ្វះខាតការចូលរួមរបស់ពលរដ្ឋក្នុងដំណើរការធ្វើគោលនយោបាយនិងការត្រួតពិនិត្យ API
   ផ្តោតលើ៖
   - ការជះឥទ្ធិពលនិងការត្រួតពិនិត្យលើការអនុវត្តគោលនយោបាយនៅតាមផ្នែក៖
     - សិទ្ធិទទួលបានព័ត៌មានសាធារណៈ
     - ការផ្ទេរមុខងារនិងធនធានទៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ
     - ការអនុវត្តន៍ច្បាប់ចរាចរផ្លូវគោកប្រកបដោយប្រសិទ្ធភាពនិង
     - ការផ្តល់សេវាសង្គមកិច្ចប្រកបដោយសមធម៌និងគុណភាពក្នុងវិស័យអប់រំ។
   - ពង្រឹងសមត្ថភាពនិងការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងបណ្តាញរបស់ពួកគេនៅក្នុងការតស៊ូមតិការពិភាក្សាគោលនយោបាយនិងការត្រួតពិនិត្យដើម្បីដោះស្រាយបញ្ហាសំខាន់ៗ
   - ការអភិវឌ្ឍនិងការប្រើប្រាស់នូវវិធីសាស្ត្ររៀនច្បាស់លាស់សម្រាប់ការស្រាវជ្រាវ និងការច្នៃប្រឌិតនៅក្នុងគោលនយោបាយដែលជះឥទ្ធិពលលើបញ្ហាគោលនយោបាយសំខាន់ៗមួយចំនួន
2) ដើម្បីលើកកម្ពស់ភាពអង់អាចរបស់ប្រជាពលរដ្ឋ ជាពិសេសយុវជនក្រុមស្ត្រីនិងក្រុមដែលងាយរងគ្រោះ ចង់ឱ្យរដ្ឋាភិបាលមានគណនេយ្យភាពចំពោះការសម្រេចចិត្ត និងសកម្មភាពឆ្លើយតបដើម្បីកែលម្អសេវាកម្ម សាធារណៈនិងការអនុវត្តគោលនយោបាយនៅថ្នាក់ក្រោមជាតិ។
   ឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋនៅតែមាន ភាគច្រើនការកំហិតលំហប្រជាធិបតេយ្យ កង្វះគណនេយ្យភាពរបស់រដ្ឋាភិបាលនៅបន្តកើតមាន ដូចនេះ អង្គការ API ត្រូវផ្តោតលើ៖

- ពង្រឹងការឃ្លាំមើលរបស់ប្រជាពលរដ្ឋលើការផ្តល់សេវាសាធារណៈការអភិវឌ្ឍផែនការរដ្ឋាភិបាលនិងថវិកានៅក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គម (I-SAF) និងយន្តការផ្សេងៗទៀតលើសពីនេះ
- ពង្រឹងសមត្ថភាពអ្នកតំណាងប្រជាពលរដ្ឋនិងអង្គការសហគមន៍និងបរិយាកាសដែលអាចធ្វើឱ្យមានការចូលរួមប្រកបដោយនិរន្តរភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋាន។
- បង្កើនភាពជាដៃគូនិងសកម្មភាពរវាងរដ្ឋាភិបាលសង្គមស៊ីវិលនិងវិស័យឯកជនក្នុងការឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ។

3) ដើម្បីកែលម្អសិទ្ធិទទួលបានព័ត៌មាននិងការបើកចំហព័ត៌មានសាធារណៈស្តីពីបញ្ហាសំខាន់ៗមួយចំនួន

ដើម្បីឆ្លើយតបទៅនឹងវប្បធម៌អាថ៌កំបាំង និងដែនកំណត់ក្នុងការបង្ហាញព័ត៌មានសាធារណៈទៅលើបញ្ហាសំខាន់ៗនានា អង្គការ API មានគោលបំណងផ្តោតលើ៖

- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសិទ្ធិទទួលបានព័ត៌មាននិងសេចក្តីព្រាងច្បាប់ A2I និងការបង្កើនតម្រូវការសម្រាប់ការបង្ហាញព័ត៌មានជាសាធារណៈ
- លើកកម្ពស់ការយល់ដឹងអំពីច្បាប់សិទ្ធិទទួលបានព័ត៌មាននិងការបង្ហាញព័ត៌មានពីសំណាក់ស្ថាប័នរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពគ្រប់លំដាប់ថ្នាក់

តាមរយៈផែនការយុទ្ធសាស្រ្តថ្មីរបស់ខ្លួននេះ អង្គការAPI នៅតែបន្តធ្វើការនៅក្នុងតំបន់គោលដៅជនបទរបស់ខេត្តចំនួន ៧ ពីមុនៗ ដូចជា៖ បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត ក្រចេះ និងពោធិ៍សាត់ នឹងពង្រីកទៅតាមស្រុកនិងតាមខេត្តថ្មីៗ ដែលនៅជិតខាង ជាពិសេសនៅតំបន់ទីក្រុងផងដែរ។ នេះគឺជាការឆ្លើយតបទៅនឹងការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័ស ដែលត្រូវបានជម្រុញឱ្យយុវជនដែលធ្វើចំណាកស្រុក ហើយយុវជនគឺជាអ្នកជម្រុះដ៏សំខាន់ នៃការផ្លាស់ប្តូរសង្គម។ ប្រើប្រាស់ប្រព័ន្ធឌីជីថល គឺជាប្រធានបទនិងឧបករណ៍ អន្តរវិស័យនឹងត្រូវបានបញ្ចូលអនុវត្តនៅក្នុងកម្មវិធីទាំងអស់របស់API ។ ជាមួយនឹងនេះ ប្រជាជនកម្ពុជាភាគច្រើន ជាយុវជនវ័យ ប្រើប្រាស់សេវាអ៊ិនធឺណិតយ៉ាងច្រើនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ វាគឺជាឱកាស និងបញ្ហាប្រឈមថ្មី ដែលត្រូវចាប់យកអនុវត្តនិងដោះស្រាយផងដែរ។

ការបង្កើតនិងអនុវត្តកម្មវិធីជោគជ័យបានគឺអាស្រ័យលើ API ដែលត្រូវធានាថាជាស្ថាបន័ខ្លាំង រឹងមាំ មានប្រសិទ្ធភាព និងនិរន្តរភាព ដូច្នេះដើម្បីគាំទ្រនិងសម្រេចបានគោលបំណងយុទ្ធសាស្ត្រទាំងនេះ APIបានបង្កើតគោលបំណងនិងអាទិភាពទាំងបួនចំណុចរបស់ខ្លួនគឺៈ

4) ដើម្បីបង្កើនសមត្ថភាពរបស់អង្គការនិងនិរន្តរភាព
ដោយឆ្លើយតបទៅនឹងការថយចុះជំនួយអភិវឌ្ឍន៍បរទេសសម្រាប់ប្រទេសកម្ពុជា តម្រូវការក្របខ័ណ្ឌច្បាប់និងតម្រូវការអនុលោមសម្រាប់អង្គការសង្គមស៊ីវិល ដែលទាមទារកាន់តែច្រើន ហើយតម្រូវការចាំបាច់ដើម្បីបន្តភាពល្អប្រសើរនៃការរៀបចំ API បានបង្កើតនូវអាទិភាពសំខាន់ៗដូចខាងក្រោមៈ

- API ត្រូវបានគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងប្រសិទ្ធភាព
- យុទ្ធសាស្ត្ររៀបចំផែនការថវិកា ត្រូវបានអនុវត្តដោយជោគជ័យ ការប្រើប្រាស់ហិរញ្ញវត្ថុ ត្រូវបានគ្រប់គ្រងតាមស្តង់ដារអន្តរជាតិ
- ពង្រឹងការគ្រប់គ្រងធនធានមនុស្សនិងការអភិវឌ្ឍន៍ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រ
- ប្រព័ន្ធសម្រាប់ការធ្វើផែនការនិងការត្រួតពិនិត្យវាយតម្លៃគណនេយ្យភាពនិងការរៀនសូត្រ(MEAL) ត្រូវបានពង្រឹង

អង្គការ API ពិនិត្យយ៉ាងហ្មត់ចត់នូវហានិភ័យនៃការថយចុះលំហប្រជាធិបតេយ្យសម្រាប់សង្គមស៊ីវិល និង ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិ ដែលអាចធ្វើឱ្យកាន់តែពិបាកក្នុងការបន្តគោលដៅយុទ្ធសាស្ត្ររបស់ខ្លួន។ API នឹងកាត់បន្ថយ ហានិភ័យដោយកសាងទំនាក់ទំនងប្រកបដោយទំនុកចិត្តជាមួយតួអង្គរដ្ឋាភិបាលនៅគ្រប់កម្រិត និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិរួមគ្នាជាមួយសង្គមស៊ីវិល។ ដើម្បីកាត់បន្ថយហានិភ័យនៃការថយចុះការគាំទ្រលើដំណើរកែទម្រង់អភិបាលកិច្ចល្អ និងការកាត់បន្ថយជំនួយបរទេស អង្គការ API នឹងកសាងសម្ព័ន្ធភាពថ្មីៗ នៅក្នុងការងារ តស៊ូមតិរបស់ខ្លួនលើវិស័យអភិបាលកិច្ចល្អនិងស្វែងរកមធ្យោបាយថ្មីៗក្នុងការទទួលបានមូលនិធិដល់កម្មវិធីរបស់ខ្លួន។
ផែនការយុទ្ធសាស្ត្រផ្តល់ការណែនាំជាយុទ្ធសាស្ត្រដល់អង្គការ។ នៅក្នុងវិសាលភាពរបស់ខ្លួន ដែលអនុញ្ញាតិឱ្យមានអាទិភាពដោយផ្អែកលើតម្រូវការបច្ចុប្បន្ន របស់ក្រុមគោលដៅ លើការផ្លាស់ប្តូរបរិបទ និងឱកាសទទួលបានមូលនិធិនានា។ ផែនការយុទ្ធសាស្ត្រនេះភ្ជាប់ជាមួយនូវផែនការថវិកាយុទ្ធសាស្ត្រ និងក្របខ័ណ្ឌតាមដាននិងវាយតម្លៃផ្តោតលើលទ្ធផលកម្រិតខ្ពស់ផងដែរ។

# ២.លទ្ធផលប្រចាំឆ្នាំ២០១៩

## *សមិទ្ធិផលសមាសភាគទី១៖ធ្វើអោយមានឥទ្ធិពលលើគោលនយោបាយ និងការអនុវត្ត ដើម្បីដោះស្រាយសិទ្ធិ និងសេចក្តីត្រូវការរបស់ពលរដ្ឋជាពិសេសយុវជន ស្ត្រី និងក្រុមងាយរងគ្រោះ ដើម្បីអនុវត្តសិទ្ធិរបស់ពួកគេប្រកបដោយសុវត្ថិភាព*

### លទ្ធផលគម្រោងទី ១៖ សំឡេង និងសកម្មភាពរបស់ពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅប្រទេសកម្ពុជា

**គោលបំណងរួម:** ដើម្បីបំពេញសិទ្ធិ និងលើកកម្ពស់សំលេងប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

ពីឆ្នាំ ២០១៩ ដល់ ២០២១ DCA និង BfdW ផ្តល់ថវិកាស្នូលដើម្បីអនុវត្តផែនការយុទ្ធសាស្ត្ររបស់ API ដោយចំណាយថវិកាសរុប ១.៧៩៦.២៧៨ ដុល្លារអាមេរិកក្នុងនោះ ២០១,៣៧៥ ដុល្លារអាមេរិកត្រូវបានផ្តល់ថវិកាដោយ DCA ។ ថវិកាចំនួន ៥០០,០០០ ដុល្លារត្រូវបានផ្តល់មូលនិធិដោយ BfdW និង ១.០៩៤.៩០៣ ដុល្លារត្រូវបានផ្តល់មូលនិធិដោយគម្រោងផ្តួងរបស់ម្ចាស់ជំនួយទាំងអស់។

ច្បាប់ និងគោលនយោបាយចំនួន ៧ ត្រូវបានជះឥទ្ធិពលសម្រាប់ផលប្រយោជន៍យុវជនស្ត្រីនិងក្រុមដែលងាយរងគ្រោះ។ API បានបណ្តុះបណ្តាល និងសម្របសម្រួលការសន្ទនារបស់ពួកគេជាមួយរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។ អនុសាសន៍របស់អង្គការសង្គមស៊ីវិល ក្រុមយុវជន និងក្រុមស្ត្រីត្រូវបានប្រមូលដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ និងគោលនយោបាយ។ ឥទ្ធិពលនេះត្រូវបានធ្វើឡើងដោយការដាក់សេចក្តីថ្លែងការណ៍រួម និងលិខិតផ្លូវការទៅស្ថាប័នដែលពាក់ព័ន្ធ និងលិខិតផ្លូវការទៅកាន់ស្ថាប័នពាក់ព័ន្ធដល់អ្នកធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយ ការធ្វើបច្ចុប្បន្នភាពច្បាប់ និងការប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីរដ្ឋាភិបាល វេទិកាសង្គមស៊ីវិលលើកទី ២ និងទី ៣ និងយុទ្ធនាការតស៊ូមតិតាមប្រព័ន្ធផ្សព្វផ្សាយ និងវេទិកាហ្វេសប៊ុកផេក API ។

## លទ្ធផលគម្រោងទី២៖ ការពិភាក្សារបស់យុវជនអំពីការកសាងច្បាប់សិទ្ធិទទួលព័ត៌មាន

អង្គការ API បានទទួលការគាំទ្រហិរញ្ញវត្ថុពីប្រទេសស៊ុយអែត តាមរយៈទីភ្នាក់ងារដើម្បីការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ ក្នុងប្រទេសកម្ពុជា ព្រះរាជាណាចក្រដាណឺម៉ាក និងទំនប់សម្រាប់ពិភពលោក ដើម្បីគាំទ្រក្រោមគម្រោង **កិច្ចពិភាក្សារបស់យុវជនអំពីការក៏សាងច្បាប់សិទ្ធិទទួលព័ត៌មាន** ដែលចាប់ផ្ដើមអនុវត្តពីខែសីហា ២០១៩ ដល់ខែកក្កដាឆ្នាំ២០២០។

**គោលបំណង:** អង្គការ API បានបង្កើននូវចំនេះដឹងរបស់ខ្លួនពីសមត្ថផលដែលបានសម្រេចកន្លងមក និងបទពិសោធន៍ ជាប្រធានក្រុមការងារនៃសិទ្ធិទទួលបានព័ត៌មាន ដែលបានធ្វើការជាមួយអង្គការ យុវជន និងបណ្ដាញ ដើម្បីជំរុញ រាជរដ្ឋាភិបាល និងសភាជាតិ ដើម្បីអនុម័តច្បាប់សិទ្ធិទទួលបានព័ត៌មាន។ យុទ្ធិសាស្ត្រថ្មី របស់អង្គការ API គឺធ្វើការជាមួយយុវជនដើម្បីធ្វើការតស៊ូមតិ ដើម្បីឲ្យសេចក្ដីព្រៀងច្បាប់សិទ្ធិទទួលបានព័ត៌មានអនុម័តឆាប់រហ័ស។ ហេតុអ្វីបានជាត្រូវការនូវយុត្តិសាស្ត្រថ្មីនេះ? តើមកពីបរាជ័យក្នុងការបញ្ចុះបញ្ចូលរាជរដ្ឋាភិបាល ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនៃសេចក្ដីព្រៀងច្បាប់សិទ្ធិទទួលមាន(ធ្វើការកត់សម្គាល់ នៅបញ្ហាប្រឈម នៅទំព័របន្ទាប់ នៅនូវការផែកញែកនូវយុត្តិសាស្ត្រថ្មី)?

**សកម្មភាព និងលទ្ធផល:** ក្រុមការងារអង្គការសង្គមស៊ីវិលស្ដីពីសិទ្ធិទទួលព័ត៌មាន បានផលិតនូវ ការវិភាគ និងផ្ដល់អនុសាស្ត្រ លើសេចក្ដីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មាន ដែលចេញពីខែសីហា ឆ្នាំ២០១៩ និងឯកសារបច្ចុប្បន្នភាពនៃសេចក្ដីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មានចេញនៅថ្ងៃទី២០-២១ ខែវិច្ឆិកា ឆ្នាំ២០១៩។ អនុសាស្ត្រដែលបានមកពីការវិភាគទាំងនេះ បានផ្ដល់ជូនរាជរដ្ឋាភិបាល និងបានធ្វើការទាក់ទងជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ ដូចជាអង្គការយូនីស្កូ និងឧត្តមស្នងការសហប្រជាជាតិ និងដៃគូរអភិវឌ្ឍន៍ (SDC, EU, SIDA) ដើម្បីផ្ដល់ធាតុចូលបន្ថែមលើសេចក្ដីព្រៀងច្បាប់នេះឲ្យស្រមតាមស្តង់ដាអន្តរជាតិ។ ជាលិទ្ធិផល ក្រុមការងារសិទ្ធិទទួលព័ត៌មាន ដែលដឹកនាំដោយអង្គការ API បានទទួលនូវការឆ្លើយតបជាវិជ្ជមានពីក្រសួងព័ត៌មាន។ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថាច្បាប់សិទ្ធិទទួលព័ត៌មាន ត្រូវតែបញ្ចប់ និងអនុម័តដោយសភាក្នុងឆ្នាំ២០២០ ពីព្រោះថាច្បាប់នេះបានព្រៀង និងពិនិត្យអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

អង្គការ API គឺជាលេខាធិការដ្ឋាន នៃបណ្ដាញអង្គការសង្គមស៊ីវិលចំនួនពីរ (CPDD and A2IWG) និងបានរៀបចំនូវកិច្ចប្រជុំជាមួយសមាជិកចំនួន ៤០ ដើម្បីផលិត និងគាំទ្រសេចក្ដីថ្លែងការណ៍ ដែលអំពាវ

នាវដល់រដ្ឋាភិបាល និងសភា ដើម្បីអនុម័តសេចក្តីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មាននេះ។ ក្រុមការងារសិទ្ធិទទួលព័ត៌មាន បានបញ្ជូនលិខិតផ្លូវការជូននាយករដ្ឋមន្រ្តី រដ្ឋសភា ព្រឹទ្ធសភា និងក្រសួងព័ត៌មាន ដើម្បីពន្លឿនអនុម័តច្បាប់សិទ្ធិទទួលព័ត៌មាននេះបានឆាប់រហ័ស។
មានប្រព័ន្ធផ្សព្វផ្សាយចំនួន៦ បានសំភាសន៍អំពីសេចក្តីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មាន ហើយបានធ្វើការផ្សព្វផ្សាយដោយ វិទ្យុអាស៊ីសេរី សម្លេងប្រជាធិបតេយ្យ ភ្នំពេញប៉ុស្ដិ៍ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ក្នុងនោះមានអ្នកចូលមើលចំនួន មួយពាន់ ប្រាំមួយរយនាក់ នូវការផ្សាយផ្ទាល់ស្តីពីការពិភាក្សារបស់វិទ្យុសម្លេងប្រជាធិបតេយ្យ។

ការទាមទារឲ្យមានច្បាប់សិទ្ធិទទួលមាន ត្រូវបានដាក់បញ្ចូលនៅក្នុងសេចក្តីថ្លែងការណ៍ របស់អ្នកនាំពាក្យពិសេស **អ្នកស្រី រ៉ូណា ស្មីត** ស្តីភាពស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៩។ សមាជិកក្រុមការងារសិទ្ធិទទួលព័ត៌មាន បានធ្វើការយ៉ាងជិតស្និតជាមួយឧត្តមស្នងការសិទ្ធិមនុស្ស ដែលបានដាក់បញ្ចូលច្បាប់សិទ្ធិទទួលព័ត៌មាននៅក្នុងរបាយការណ៍ស្រម៉ោល កាលពីឆ្នាំ២០១៨ ហើយបានធ្វើបទបង្ហាញនៅសមាជទី៣២ នៅទីក្រុងស៊ីណែវ កាលពីថ្ងៃ៣០ ខែមករា ឆ្នាំ២០១៩។

មួយក្នុងចំណោម អង្គការសង្គមស៊ីវិលចំនួន ១២ បានទាមទារឲ្យមានច្បាប់សិទ្ធិទទួលបានព័ត៌មាន នៅក្នុង សន្និបាតភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩។ ឯកឧត្តម មាស សុភ័ណ្ឌ អនុរដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន បានបញ្ជាក់អំពីការបញ្ចប់ការពិគ្រោះយោបល់ជាមួយក្រសួងសំខាន់ៗនៅចុងឆ្នាំ២០១៩នេះ។ ថ្មីៗនេះ ឆន្ទៈនយោបាយរបស់ក្រសួងព័ត៌មាន និងក្រុមប្រឹក្សារដ្ឋមន្រ្តី គឺមិនរំពឹងធ្វើការពិគ្រោះយោបល់ និងទទួលធាតុចូលបន្ថែមទៀតពីអង្គការសង្គមស៊ីវិល ពីព្រោះរដ្ឋាភិបាលគិតថាការពិគ្រោះយោបល់បានបិទបញ្ចប់។ សេចក្តីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មាន ដែលចេញនៅខែសីហា និងខែវិច្ឆិកា ឆ្នាំ២០១៩ ចុងក្រោយនេះ មិនមានសង្គតិភាពតាមស្តង់ដាអន្តរជាតិ បើតាមរយៈការវិភាគរបស់ក្រុមការងាររបស់ API ។
ដូច្នេះ អង្គការ API បានប្រមូលផ្តុំអង្គការយុវជន បណ្តាញ និងតំណាង ចំនួន២៩ មកពីវិស័យផ្សេងៗដើម្បីធ្វើការបណ្តុះបណ្តាល ក្នុងរយៈពេល៣ថ្ងៃទៅលើសិទ្ធិទទួលបានព័ត៌មាន និងកិច្ចគាំទ្រការតស៊ូមតិ លើច្បាប់សិទ្ធិទទួលព័ត៌មាន។ ប្រធានអង្គការយុវជន នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្តីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មាន ជាមួយអ្នកជំនាញអន្តរជាតិរបស់អង្គការយូនីស្កូ ហើយយុវជនចំនួន១២ ក្នុងចំណោម ២៩ ដែលបានទទួលការបណ្ណុះបណ្តាល បានសម្តែងការព្រួយបារម្ភ និងលើក

ជាសំនួរលើអត្ថបទនៃសេចក្តីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មាន តាមរយៈសេក្ខាសាលាពីគ្រោះយោបល់ ជាមួយអ្នកជំនាយសិទ្ធិទទួលព័ត៌មាន និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន។

យុវជនបានទទួលចំណេះដឹងពីរបាយការណ៍វិភាគ នៃសេចក្តីព្រៀងច្បាប់ចុងក្រោយ ដែលត្រូវបាន វិភាគ និងផ្តល់ជាអនុសាស្រ្តជាក់ច្បាស់ ផ្អែកតាមបរិបទប្រទេសកម្ពុជា។ អង្គការ API បានគាំទ្រតំណាង យុវជន ដើម្បីធ្វើការតស៊ូមិតិ ដែលមានអ្នកចូលរួមប្រមាណជា៥០០នាក់ មកពី មន្ត្រីរដ្ឋាភិបាល និង តំណាងអង្គការសង្គមស៊ីវិល ដែលបានចូលរួមនៅក្នុងសន្និសិទតស៊ូមិតិថ្នាក់ជាតិឆ្នាំ២០១៩ ហើយ តំណាងទាំង៥០០នាក់ផ្សេងទៀត ដែលមានមន្ត្រី រដ្ឋាភិបាល ប្រធានអង្គការសង្គមស៊ីវិល និង តំណាងដៃគូរអភិវឌ្ឍន៍ បានចូលរួមវេទិការភាពជាដៃគូររវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលលើកទី ២ និងទី៣ ក្នុងឆ្នាំ២០១៩។ អ្នកចូលរួមក្នុងវេទិកា បានគាំទ្រឲ្យមានយុទ្ធនាការ ដើម្បីអនុម័តអោយមាន ច្បាប់សិទ្ធិទទួលព័ត៌មាន។

**បញ្ហាប្រឈម:** វិសាលភាព នៃនៃកិច្ចពិភាក្សាជាមួយក្រសួងសំខាន់ៗរបស់រដ្ឋាភិបាល ជាពិសេសក្រុម ការងារសិទ្ធិទទួលព័ត៌មាន របស់ក្រសួងព័ត៌មាន មានកំរិត ពីព្រោះថាដំណើរនៃកិច្ចពីគ្រោះយោបល់ បានបិទបញ្ចប់ តាមការបញ្ជាក់ដោយរដ្ឋាភិបាល។ អង្គការ API បានដាក់លិខិត សម្រាប់កិច្ចប្រជុំ ជា ផ្លូវការ និងបានដាក់របាយការណ៍វិភាគច្បាប់ លើសេចក្តីព្រៀងច្បាប់សិទ្ធិទទួលព៌ត៌មានដែលចេញ កាលពីខែសីហា ឆ្នាំ២០១៩ ដោយអង្គការមេត្រា១៩ និងចេញកាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ដោយ អង្គការ API។

ការវិភាគសេចក្តីព្រៀងច្បាប់សិទ្ធិទទួលព៌ត៌មានចុងក្រោយនៅខែវិច្ឆិកា ឆ្នាំ២០១៩ ដោយអង្គការ API គឺ បានបង្ហាញឲ្យឃើញថាសេចក្តីព្រៀងនេះមិនមានសង្គតិភាពតាមស្តង់ដាអន្តរជាតិ ហើយដែលមានកំ រិតទាបជាងសេចក្តីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មានដែលចេញកាលពីមករា ឆ្នាំ២០១៨ ដែលមានដៃគូរ សំខាន់ៗចូលរួមក្នុងនោះ ក្រុមការងាររបស់រដ្ឋាភិបាល អង្គការដៃគូរអភិវឌ្ឍន៍ និងក្រុមការងារសិទ្ធិ ទទួលព័ត៌មាន បានពីគ្រោះយោបល់ និងទទួលយក។

### ផែនការ ឆ្នាំ២០២០

- បណ្តុះបណ្តាលក្រុមយុវជន មកពី២៥ខេត្តក្រុង និងវិស័យផ្សេងៗ ដើម្បីចូលរួមក្នុងការតស៊ូមតិ លើសេចកក្តីព្រៀងច្បាប់សិទ្ធិទទួលមាន។ ជំរុញយុវជនដើម្បីចែករំលែកបន្តចំនេះដឹង និងបទ ពិសោធន៍ ទៅដល់មិត្តភក្តិរបស់ពួកគាត់ ដើម្បីស្វែងរកការគាំទ្រនូវច្បាប់សិទ្ធិទទួលព័ត៌មាន។

- ដឹកនាំយុវជន ដើម្បីធ្វើកិច្ចពិភាក្សាជាមួយក្រសួងសំខាន់ និងគណៈកម្មាធិការទី៥ នៃរដ្ឋសភា និងព្រឹទ្ធិសភា
- បង្កើនសម្លេងយុវជនដើម្បីដើម្បីទាមទារឲ្យអនុម័តច្បាប់សិទ្ធិទទួលព័ត៌មានតាមរយៈកម្មវិធីវិទ្យុ
- កិច្ចប្រជុំពីគ្រោះយោបល់ ជាមួយភាគីពាក់ព័ន្ធដើម្បីគាំទ្រ នូវរបាយការណ៍វិភាគច្បាប់សិទ្ធិទទួលព័ត៌មានចុងក្រោយដែលចេញនៅខែវិច្ឆិកាឆ្នាំ២០១៩។ ការវិភាគសង្ខេប និងអនុសាស្រ្តទៅលើសេចក្តីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មាន។

## លទ្ធផលគម្រោងទី៣៖ កិច្ចសន្ទនាយុវវ័យក្នុងគោលនយោបាយបង្កើតច្បាប់ និងការអនុវត្តច្បាប់ការងារដែលទាក់ទងទៅនឹងយុវជន

**គោលបំណង៖**គឺដើម្បីអភិវឌ្ឍសមត្ថភាពរបស់អង្គការដែលដឹកនាំដោយយុវជន និងអ្នកដឹកនាំយុវជនក្នុងការចូលរួមក្នុងការសន្ទនាគោលនយោបាយយុទ្ធសាស្ត្រជាពិសេសការបង្កើត និងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រទាក់ទងនឹងការងាររបស់យុវជនក្នុងឆ្នាំ ២០១៩ ដែលមានថវិកាចំនួន ៣៦.៨៥០ ដុល្លារ ឧបត្ថម្ភដោយUNDPឆ្នាំ ២០១៩ ។

**លទ្ធផល៖** រដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីមុខរបរដើម្បីបង្កើនឱកាសការងារសមរម្យ និងផលិតភាពដែលត្រូវបានគាំទ្រដោយកម្មវិធីរួមរបស់អង្គការសហប្រជាជាតិដូចដែលបានទាមទារដោយ API បានបណ្តុះបណ្តាលមេដឹកនាំយុវជនចំនួន ៥០នាក់ និងបានពិភាក្សាជាមួយអ្នកបង្កើតគោលនយោបាយពាក់ព័ន្ធនៅថ្នាក់ជាតិ និងខេត្តស្តីពីគោលនយោបាយទាក់ទងនឹងការងារយុវជន និងបញ្ហារបស់យុវជន។

API បានបញ្ចប់រាល់ការងារដែលបានព្រមព្រៀងនៃវិសាលភាពការងារនៃកិច្ចព្រមព្រៀងគម្រោងហើយបានផ្តល់នូវការបញ្ជូនទាំងអស់ក្នុងការអភិវឌ្ឍសមត្ថភាពរបស់អង្គការដែលដឹកនាំដោយយុវជន និងអ្នកដឹកនាំយុវជន។ ពួកគេបានចូលរួមនៅក្នុងការសន្ទនាគោលនយោបាយស្តីពីការបង្កើត និងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រទាក់ទងនឹងការងារយុវជននៅថ្នាក់ជាតិ និងខេត្តដោយផ្អែកលើវគ្គបណ្តុះបណ្តាលចំនួនពីរគឺការអភិវឌ្ឍផែនការតស៊ូមតិ និងសេចក្តីសង្ខេបគោលនយោបាយដែលគាំទ្រដោយសេវាកម្មណែនាំ និងហ្វឹកហាត់បន្ថែម។

**លទ្ធផលសំខាន់ៗ** នៃគម្រោងនេះដើម្បីលើកកម្ពស់ជំនាញរបស់អ្នកដឹកនាំយុវជនចំនួន ៥០ នាក់ក្នុងការរៀបចំ និងចូលរួមក្នុងកិច្ចពិភាក្សាទាក់ទងនឹងគោលនយោបាយការងាររបស់យុវជនរួមមាន៖ (១) របាយការណ៍វាយតម្លៃតម្រូវការសមត្ថភាពរហ័សដែលរួមមានវិធីសាស្ត្រ ការរកឃើញ ការវិភាគ និងអនុសាសន៍។ (២) វគ្គបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃជាភាសាខ្មែរ បង្កើតឡើងដោយផ្អែកលើការវាយតម្លៃតម្រូវការ ការបណ្តុះបណ្តាល ការពិភាក្សា និងកិច្ចព្រមព្រៀងជាមួយ UNDP។ (៣) ការបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃចំនួន ២ដង ដល់អ្នកដឹកនាំយុវជននៅភ្នំពេញ និងសៀមរាប។ (៤) ផែនការ

តស៊ូមតិយុវជន និងសេចក្តីសង្ខេបគោលនយោបាយចំនួន ៥ ស្តីពីការងារយុវជនលើបញ្ហាចំនួន ៥ ដែលបានជ្រើសរើស។ (៥) ការសន្ទនាគោលនយោបាយដឹកនាំដោយយុវជនចំនួន ៣ក្រុម នៅភ្នំពេញ បាត់ដំបង និងសៀមរាប និង (៦) របាយការណ៍បញ្ចប់។

API បានបណ្តុះបណ្តាលអ្នកដឹកនាំយុវជនចំនួន ៥០ នាក់ (ស្រី ២១ នាក់) លើគោលនយោបាយតស៊ូ មតិ។ ថ្នាក់ដឹកនាំ និងតំណាងយុវជនចំនួន ២៨ នាក់ (ស្រី ១១ នាក់) បានដឹកនាំកិច្ចពិភាក្សាគោលនយោបាយទាក់ទងនឹងការងាររបស់យុវជនស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់យុវជនដែលបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ទីផ្សារការងារ ឱកាសការងារ ព័ត៌មាន និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅខេត្តបាត់ដំបង សៀមរាប និងរាជធានីភ្នំពេញដោយមានតំណាង ៩៥ នាក់ (ស្រី ២៣ នាក់ មកពីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) សភាពាណិជ្ជកម្មកម្ពុជា អ្នកបង្កើតគោលនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ និងផ្នែកឯកជន។ យុវជនចំនួន ៥០ នាក់ត្រូវបានជ្រើសរើសពី ៥៧៩នាក់ (ស្រី ៤៣%) ដែលបានចូលរួមក្នុងការវាយតម្លៃតម្រូវការសមត្ថភាពបណ្តុះបណ្តាល។ រដ្ឋាភិបាល ក្រសួងដែលពាក់ព័ន្ធបានបញ្ជាក់ពីការឆ្លើយតបជាវិជ្ជមានក្នុងអំឡុងពេលនៃកិច្ចសន្ទនានេះ ក៏ប៉ុន្តែសកម្មភាពរបស់ពួកគេនឹងត្រូវបានត្រួតពិនិត្យជាបន្តបន្ទាប់។

យុវជនបានបញ្ជាក់ថាពួកគេទទួលបាននូវសមត្ថភាពថ្មីៗ បង្កើតផែនការតស៊ូមតិរបស់ពួកគេដោយផ្តោតលើបញ្ហាសំខាន់ៗទាក់ទងនឹងការងារយុវជន និងមានឱកាសជួបពិភាក្សាជាមួយតំណាងមកពីរដ្ឋាភិបាល វិស័យឯកជន និងភាគីពាក់ព័ន្ធ។ ពួកគេបានលើកបញ្ហារបស់ពួកគេទាក់ទងនឹងការងារជាពិសេសលើព័ត៌មានការងារខ្សោយ។ កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈមានកំណត់ដែលមានភាពទាក់ទាញសម្រាប់យុវវ័យ។ ទទួលបានឱកាសការងារសមរម្យជាមួយនឹងប្រាក់ខែអប្បបរមាសម្រាប់យុវជន និងនិស្សិតជំនាញបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ។ ការកាត់បន្ថយវិសមភាពសម្រាប់ក្រុមដែលជួបការលំបាក និងក្រុមងាយរងគ្រោះ និងធានាថាស្ត្រី និងបុរសវ័យក្មេងមានលទ្ធភាពបំពេញតំរូវការពលកម្មជំនាញនៅក្នុងប្រទេស។

បញ្ហាគោលនយោបាយសំខាន់ៗចំនួនបី និងអនុសាសន៍ជាក់លាក់ស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់យុវជនដែលបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ទីផ្សារការងារ ឱកាសការងារ និងការផ្សព្វផ្សាយព័ត៌មាន និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់យុវជនត្រូវបានជជែកពិភាក្សាគ្នារវាងអ្នកបង្កើតគោលនយោបាយមកពីក្រសួងចំនួន១០ វិស័យឯកជន និងយុវជនដែលបានបណ្តុះ

បណ្ដាលដោយAPI ។ ស្ថាប័នរដ្ឋ និងឯកជនទទួលយកអនុសាសន៍ដើម្បីកែលម្អការអនុវត្ត និងឱកាសរបស់ពួកគេសម្រាប់យុវជន។ (សូមមើលសេចក្តីសង្ខេបគោលនយោបាយយុវជនដែលភ្ជាប់មកជាមួយ)

យុវជនបានវាយតម្លៃការចូលរួមរបស់ពួកគេនៅក្នុងគម្រោងហើយបានបញ្ជាក់ពីការពេញចិត្តខ្ពស់របស់ពួកគេចំពោះការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពគម្រោងដើម្បីដោះស្រាយបញ្ហារបស់ពួកគេ។ ពួកគេបានផ្ដល់អនុសាសន៍យ៉ាងមុតមាំ សម្រាប់ប្រទេសកម្ពុជាក្នុងការទទួលបានឱកាសការងារសមរម្យ និងធានាថាស្ត្រី និងបុរសវ័យក្មេងអាចបំពេញបាននូវតម្រូវការការងារជំនាញ។

បញ្ហាប្រឈម៖ តំណាងរដ្ឋាភិបាល មន្ទីរជុំវិញខេត្ត បានទទួលស្គាល់បញ្ហាយុវជន និងអនុសាសន៍ដែលយុវជនបានលើកឡើង ការព្រមព្រៀងបើកឱកាសការងារ និងការស្ម័គ្រចិត្តសំរាប់យុវជន។ តំណាងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានទទួលស្គាល់ថាបញ្ហាយុវជនគឺខ្វះជំនាញទន់និងជំនាញបច្ចេកទេសទោះយ៉ាងណាតំណាងរដ្ឋាភិបាលឆ្លើយតប បែបការពារខ្លួនជាជាងស្វែងរកដំណោះស្រាយ។

**ផែនការ៖ API** នៅតែបន្តដឹកនាំ និងចូលរួមជាមួយយុវជនដែលបានទទួលការបណ្តុះបណ្តាលដើម្បីតាមដានសកម្មភាពឆ្លើយតបរបស់រដ្ឋាភិបាល និងចូលរួមជាមួយពួកគេនៅក្នុងការសន្ទនាគោលនយោបាយផ្សេងទៀតដែលផ្តល់ផលប្រយោជន៍ដល់ពួកគេ។

## លទ្ធផលគម្រោងទី៩៖ ដឹកនាំលេខាធិការដ្ឋាន អង្គការសម្ព័ន្ធភាពដៃគូការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

លេខាធិការដ្ឋានអង្គការCPDD ត្រូវបានគាំទ្រដោយBftW, DCA, UNDEF ដែលជាផ្នែកនៃគម្រោងមួយរបស់អង្គការ API ។

**គោលបំណង៖** បេសកម្មអង្គការCPDD ធ្វើលើការលើកកម្ពស់សម្លេង និងការចូលរួមប្រកបដោយអត្ថន័យរវាងអង្គការសង្គមស៊ីវិល និងគ្រប់កម្រិតនៃរដ្ឋាភិបាល ដោយមានគោលបំណងចម្បងក្នុងការពង្រឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។

**លទ្ធផល៖** API បានដើរតួសំខាន់ក្នុងការពង្រឹងជំនាញការតស៊ូមតិ និងការចូលរួមតស៊ូមតិជាមួយអង្គការសង្គមស៊ីវិល(អង្គការCPDD) និងសមាគមរដ្ឋាភិបាលនៃក្រុមប្រឹក្សាមូលដ្ឋានអស់រយៈពេលជាច្រើនឆ្នាំ។ នៅទីបំផុតពួកគេជោគជ័យក្នុងការតស៊ូមតិជាមួយរដ្ឋាភិបាល ក្នុងការអនុម័តអនុក្រឹត្យស្តីពីការផ្ទេរមុខងារពីថ្នាក់ជាតិមកថ្នាក់ក្រោមជាតិនៅចុងឆ្នាំ២០១៩។ រដ្ឋាភិបាលក៏បានអនុម័តអនុក្រឹត្យស្តីពី ការផ្ទេរមុខងារ និងផែនការថវិកា សម្រាប់ឆ្នាំ ២០២០ ដែលថវិកាកើនឡើងសម្រាប់ថ្នាក់ក្រោមជាតិចាប់ពីថ្ងៃ២ ខែមករា ឆ្នាំ២០២០ តាមគោលការណ៍កំណត់។

អង្គការAPI គឺជាលេខាធិការដ្ឋានក្នុងការដឹកនាំអង្គការCPDD។ អង្គការAPI បានធ្វើការគាំទ្រដល់អង្គការCPDD ក្នុងការចេញសេចក្តីថ្លែងការណ៍រួមទៅរដ្ឋាភិបាលជាមួយអង្គការCCC និងបណ្តាញអង្គការក្រៅរដ្ឋាភិបាលតាមវិស័យ ដោយធ្វើការផ្តល់ធាតុចូលនៅក្នុងផែនការការងារ និងគម្រោងថវិការប្រចាំឆ្នាំ២០២០។ បានធ្វើការចូលរួមជាមួយអង្គការសង្គមស៊ីវិលក្នុងការផ្តល់អនុសាសន៍គោលនយោបាយ និងធាតុចូលក្នុងវេទិកាភាពជាដៃគូរបស់រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលក្នុងឆ្នាំ២០១៩ (អនុសាសន៍១២) ហើយរដ្ឋាភិបាលបានឆ្លើយតបជាវិជ្ជមាន។

អង្គការសម្ព័ន្ធភាពដៃគូការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(CPDD) ជាអតីតក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ (WGPD) គឺជាអង្គការដែលមិនរកប្រាក់ចំណេញ និងមិនចូលបក្សសម្ព័ន្ធណាមួយនៅក្នុងប្រទេសកម្ពុជាធ្វើការដោយឯករាជ្យភាពទៅលើបញ្ហាកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា។ ចក្ខុវិស័យគឺ សង្គមកម្ពុជាទាំងអស់ត្រូវបានចូលរួមយ៉ាងពិតប្រាកដក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការទទួលបាននូវសេវាកម្មសាធារណៈប្រកបដោយគុណភាព និងការឆ្លើយតប។

អង្គការCPDD បានចុះបញ្ជីជាផ្លូវការជាមួយក្រសួងមហាផ្ទៃ នៅខែកក្កដា ឆ្នាំ២០១៧។ អង្គការCPDD គឺជាអង្គការបណ្តាញតែមួយ(ដែលមានសមាជិកអង្គការមិនមែនរដ្ឋាភិបាលចំនួន១២០) ដែលផ្តោតសំខាន់លើកំណែទម្រង់វិមជ្ឈការ ហើយបានបង្កើតទំនាក់ទំនងការងារល្អជាមួយរដ្ឋាភិបាលជាពិសេសលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(គ.ជ.អ.ប) ទីភ្នាក់ងារម្ចាស់ជំនួយ សមាគមក្រុមប្រឹក្សា ថ្នាក់ក្រោមជាតិ(ASAC) និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងប្រទេស។

លេខាធិការដ្ឋានអង្គការCPDD បានធ្វើបច្ចុប្បន្នភាពសមាជិក និងបានរៀបចំកិច្ចប្រជុំផែនការអភិវឌ្ឍទៀងទាត់ ហើយបានសិក្សាពីបញ្ហាប្រឈមដល់ដៃគូអភិវឌ្ឍន៍តាមរយៈកិច្ចប្រជុំផែនការអភិវឌ្ឍប្រចាំត្រីមាស ដែលគាំទ្រដោយសហភាពអឺរ៉ុប និងធនាគារអភិវឌ្ឍន៍អាស៊ី។ តាមរយៈផែនការអភិវឌ្ឍគឺមានគោលបំណងស្វែងរកការគាំទ្រហិរញ្ញវត្ថុ ដល់អង្គការសង្គមស៊ីវិលក្នុងការចូលរួមរបស់ពលរដ្ឋ និងបញ្ហាដែលធ្វើអោយមានភាពរាំងស្ទះក្នុងការអនុវត្តការងាររបស់អង្គការសង្គមស៊ីវិល។

លេខាធិការដ្ឋានCPDD បានចូលរួមដោះស្រាយបញ្ហាប្រឈម និងអនុសាសន៍ របស់អង្គការសង្គមស៊ីវិលក្នុងការធ្វើឱ្យប្រសើរឡើងនូវសូចនាករត្រួតពិនិត្យរួមគ្នាក្នុងការផ្ទេរមុខងារពីថ្នាក់ជាតិមកថ្នាក់ក្រោមជាតិតាមរយៈផែនការអភិវឌ្ឍ។ គ.ជ.អ.ប បានធ្វើការចែករំលែកព័ត៌មានពីការផ្ទេរមុខងារថ្មីរបស់រដ្ឋាភិបាលទៅឲ្យសមាជិកអង្គារCPDD។ អង្គការCPDD បានរៀបចំដំណើរការឡើងវិញគេហទំព័ររបស់អង្គារ និងធ្វើបច្ចុប្បន្នភាពសមាជិកក្រុម Telegraph សម្រាប់ទំនាក់ទំនងប្រចាំថ្ងៃ។

សមាជិកអង្គការCPDD កំពុងអនុវត្តគម្រោងជាច្រើនដើម្បីគាំទ្រដល់ការអនុវត្តគម្រោង៣ឆ្នាំរំកិល ដូចជាក្របខ័ណ្ឌគណនេយ្យភាពសង្គម(ISAF) ការិយាល័យច្រកចេញចូលតែមួយ និងការកសាងសមត្ថភាពអ្នកផ្តល់សេវា និងអ្នកទទួលសេវា; ពង្រឹងសមត្ថភាពស្ថាប័ន និងប្រតិបត្តិការរបស់សមាគមក្រុមប្រឹក្សាមូលដ្ឋាន។ ធ្វើឲ្យប្រសើរឡើងនូវគណនេយ្យភាព និងតម្លាភាពរបស់ពួកគេ និងលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋ។ លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសិទ្ធិទទួលបានព័ត៌មាននិងតំរូវការសំរាប់ការទទួលបានច្បាប់ព័ត៌មាន។ ល។

## *សមទ្ធិផលសមាសភាគទី២៖លើកកម្ពស់ភាពអង់អាចរបស់ប្រជាពលរដ្ឋ ជាពិសេសយុវជនក្រុមស្ត្រីនិងក្រុមដែលងាយរងគ្រោះ ចង់ឱ្យរដ្ឋាភិបាលមានគណនេយ្យភាពចំពោះការសម្រេចចិត្ត និងសកម្មភាពឆ្លើយតប ដើម្បីកែលម្អសេវាកម្ម សាធារណៈនិងការអនុវត្តគោលនយោបាយនៅថ្នាក់ក្រោមជាតិ។*

### លទ្ធផលគម្រោងទី៥៖ លើកកម្ពស់ សិទ្ធិ សម្លេង ជម្រើស និងការសម្រេចចិត្តរបស់ប្រជាពលរដ្ឋ

គម្រោងចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៦ដល់ឆ្នាំ២០១៩

**គោលបំណងនៃគម្រោង៖**គឺដើម្បីអភិវឌ្ឍអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋតាមបែបប្រជាធិបតេយ្យ ថវិកាសរុប ៥៣០,០០០ អឺរ៉ូ គាំទ្រថវិកាដោយអង្គ Bread for the World (BfdW) និងជំនួយរបស់វិហារដាណឺម៉ាក (DCA)។

### លទ្ធផល

បានបង្កើត និងពង្រឹង CBOs៖ ចំនួនសរុប ១៦អង្គការសហគមន៍មូលដ្ឋានដែលមានយុវជន និងសមាជិក៣២៣នាក់ (ស្រី៦០%)ត្រូវបានជ្រើសរើស បានបង្កើត និងពង្រឹងស្ថាប័ន និងសមត្ថភាពសហប្រតិបត្តិការណ៍ និងបច្ចេកទេសរបស់ពួកគេ ហើយនិងជំនាញតស៊ូមតិនៅក្នុងការត្រួតពិនិត្យគោលនយោបាយ និងការបម្រើសេវាសាធរណៈនៃរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។
អង្គការ ចំនួន១៦ ដែលបានបញ្ជូនបុគ្គលិក ៣៨នាក់(ស្រី ១៥នាក់) ដែលជាអ្នកដឹកនាំ ត្រូវបានអភិវឌ្ឍជំនាញក្នុងការគៀងគរថវិកានៅមូលដ្ឋាន និងការស្វែងរកការគាំទ្រមតិ របស់អង្គការ និងការគ្រប់គ្រងគម្រោង ដើម្បីពង្រឹងស្ថាប័ន និងសមត្ថភាពសហប្រតិបត្តិការរបស់ពួកគេ។(សូមមើលនៅក្នុងឯកសាររបស់អ្នកចូលរួម)។

API តាមដាន និងគាំទ្រ ៤០ CBOs ដើម្បីធ្វើឲ្យប្រសើរឡើងនូវមុខងារ និង១៦CBOs ថ្មីទៀតដែលទើបតែបង្កើតឡើងនៃក្រុមយុវជន និងជនដែលមានពិការភាពត្រូវបានជ្រើសរើស សម្រាប់កំណែទម្រង់ និងពង្រឹងសមត្ថភាព។ មានដូនជា៖ ១). CBOs ដែលមានក្រុមយុវជន ១៣នាក់នៅក្នុងខណ្ឌសែនសុខ យុវជន៣ក្រុមមានគ្នា ៥០នាក់នៅក្នុងស្រុកថ្មពួក យុវជន ២ក្រុមមានគ្នា ២៥នាក់នៅក្នុងស្រុកប្រាសាទបាល័ង្គ យុវជន ៣ក្រុមមានគ្នា ៥០នាក់នៅក្នុងខេត្តបាត់ដំបង សៀមរៀប ភ្នំពេញ និង៧ CBOs នៃជន

ដែលមានពិការភាព (PwD) នៅក្នុង ឃុំចំនួន៧ ក្នុងស្រុកត្រាំកក់។

ក្រុមទាំង១៦របស់យុវជន និងជនមានពិការភាពត្រូវបានបណ្តុះបណ្តាល បង្ហាត់បង្រៀន និងត្រួតពិនិត្យលើការបម្រើសេវាសាធារណៈនៅទូទាំង២២ បឋមសិក្សា ៨មណ្ឌលសុខភាព ៣៦ឃុំ/សង្កាត់ មកពី ៣ស្រុក និង១ខណ្ឌ ហើយនិងប៉ុស្តិ៍រដ្ឋបាលនគរបាល៤ ដើម្បីអនុវត្តសិទ្ធិ និងលើកកម្ពស់ការរស់នៅរបស់ប្រជាពលរដ្ឋ។

តំណាងCBOs យុវជន និងអជ្ញាធរមូលដ្ឋាននៅក្នុងចំនួន៥៥នាក់(ស្រី២៧នាក់)បានយល់ដឹងយ៉ាងទូលំទូលាតាមរយៈសកម្មភាពវគ្គបណ្តុះបណ្តាល២លើកស្តីពីទូនាទី និងសិទ្ធដើម្បីចូលរួមក្នុងដំណើរការត្រួតពិនិត្យព័ត៌មានលើដំណើរការរៀបចំកញ្ចប់ថវិកាឃុំ និងការអនុវត្តសិទ្ធិទទួលបានព័ត៌មាន និងការតស៊ូមតិ។ បន្ទាប់មក៦ក្រុមដែលទើបតែបង្កើតឡើងនៃយុវជន និងស្រ្តីត្រូវបានបណ្តុះបណ្តាលនិងបង្ហាតបង្រៀនពីការចូលរួមជាមួយក្រុមប្រឹក្សាឃុំ និងការត្រួតពិនិត្យលទ្ធផលនៃសកម្មភាពដែលទាក់ទងជាមួយនការបម្រើសេវាសាធារណៈនៅក្នុងឃុំរបស់ពួកគេ។

**សកម្មភាពតស៊ូមតិនៅថ្នាក់មូលដ្ឋានៈ** បន្ទាប់ពីធ្វើការបណ្តុះបណ្តាលដល់ក្រុមយុវជន មាន១៣សកម្មភាពតស៊ូមតិ និង៣សកម្មភាពជាការផ្សព្វផ្សាយ យល់ដឹងដែលគាំទ្រដល់ ១៣CBOs និងយុវជន៥ក្រុមដែលហ៊ានធ្វើការតស៊ូមតិ និងលើកឡើងពីបញ្ហារបស់ពួកគេទៅកាន់ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិនិងផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ។ ជាលទ្ធផលមាន៨នៃ១៣គម្រោងតស៊ូមតិត្រូវបានបានទទួលយក និងប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីដាក់ចូលទៅក្នុងកម្មវិធីវិនិយោគឃុំបីឆ្នាំរំកិល។

ចំនួន ៤២បញ្ហាត្រូវបានលើកឡើងដោយ 9 CBOs និងថ្នាក់ដឹកនាំយុវជនតាមរយៈការគាំទ្រពីតំណាង៥៩CBOs (ស្រី៤៥%)ដែលបានចូលរួមការប្រជុំទៀងទាត់ជាមួយឃុំ និងស្រុករៀងរាល់ខែ ដូនជាវេទិកាសាធារណៈជាដើម។ ចុងបញ្ចប់នៃគម្រោង មាន ៣២បញ្ហាត្រូវបានដោះស្រាយនិង១០ករណីផ្សេងទៀតដែលទាក់ទងទៅ និងគម្រោងថវិកា និងហេដ្ឋារចនាសម្ព័ននៅតែបន្តអនុវត្ត។

លើសពីនេះទៀត តំណាងសហគមន៍ ៥៩នាក់(ស្រី៣៨នាក់) បានចូលរួមត្រួតពិនិត្យ លើការអនុវត្តនៃគម្រោង ១). ការជួសជុលបង្គន់នៅសាលាបឋមសិក្សាតាម៉ាំងក្នុងឃុំគោករមៀត ២). ការចាក់ដីបំពេញនៅសាលាបឋមសិក្សាសាលាវិស័យ ៣). ការផ្តល់សម្ភារៈសិក្សាដល់សិស្សក្រីក្រនៅសាលាបឋសិក្សាទួលគ្រើល ៤). និងផ្តល់ឯកសណ្ឋានដល់ប្រជាការពារភូមិនៅក្នុងឃុំទួលគ្រើល។

**បានរៀបចំកិច្ចប្រជុំជាមួយដៃគូពាក់ព័ន្ធ** រវាងអាជ្ញាធរមូលដ្ឋាននៃស្រុកថ្មពួកនៅក្នុងខេត្តបន្ទាយមានជ័យ និងស្រុកប្រាសាទបាល័ង្កក្នុងខេត្តកំពង់ធំជាមួយ និងសង្គមស៊ីវិល CBOs និងវិស័សឯកជនបានបង្កើត និងធ្វើឲ្យប្រសើឡើងក្នុងកិច្ចប្រជុំពហុភាគីចំនួន ១០។ ដៃគូពាក់ព័ន្ធបានបដិភាគថវិកា៧,៤០៦ ដុល្លាចូលទៅក្នុង១៨ គម្រោង។

**ការតស៊ូមតិថ្នាក់ជាតិ៖** API បានសម្របសម្រួលគោលនយោបាយចំនួន៥ ការអនុវត្តករណីសិក្សា ការពិភាក្សាជាមួយក្រសួងមហាផ្ទៃ និងNCDD-S, អាជ្ញាធរមូលដ្ឋានមកពីខេត្តគោលដៅ និងតំណាងអ្នកដឹកនាំជាន់ខ្ពស់ (ប្រធានលេខាធិការដ្ឋាន) មានមនុស្សប្រហែលជា ២០-៤០ នាក់ចូលរួមកិច្ចប្រជុំជាមួយក្រសួង រួមមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល និងនាយកដ្ឋាននគរបាលជាតិ ដើម្បីពិភាក្សាពីការស្វែងរកការអភិវឌ្ឍគោលនយោបាយ និងតម្រូវការ ដើម្បីធ្វើឲ្យប្រសើរ(១)ការចូលរួមជាសាធារណៈនៅក្នុងដំណើការរៀបចំផែនការ និងថវិកា (២) សុខភាព និងសន្តសុខ (៣) ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន រួមបញ្ចូលគ្នាជាមួយ និងគុណភាពនៃការបម្រើសេវាសាធារណៈលើសេវាអប់រំ សុខភាព រដ្ឋបាលឃុំ ស្រុក ប៉ុស្តិ៍រដ្ឋបាលនគរបាល។

រាល់ករណីសិក្សាខាងលើនេះគឺត្រូវធ្វើឡើងដោយ API នៅក្នុងកិច្ចសហប្រតិបត្តិការណ៍ជាមួយអង្គការសហគមន៍(CBOs) ក្រុមជួយខ្លួនឯងនៃជនមានពិការភាព ក្រុមយុវជន ក្រុមស្ត្រី និងអាជ្ញាធរថ្នាក់ក្រោមជាតិ។ មានដូចជា៖

(១)ការចូលរួមរបស់ស្ត្រីក្នុងដំណើរការនៃការរៀបចំផែនការថវិកានៅក្នុងស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ

(២)ការចូលរួមជាសាធារណៈក្នុងការរៀបចំផែនការមូលដ្ឋាននៅក្នុងស្រុកត្រាំកក់ ខេត្តពោធិ៍សាត់

(៣)ការរួមបញ្ចូលគ្នានៅក្នុងក្នុងការរៀបចំផែនការមូលដ្ឋាននៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់

(៤)ការអនុវត្តតួនាទីនៃរដ្ឋបាលស្រុកក្នុងការលើកកម្ពស់ សុខមាលភាព និងសន្តិសុខនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ

(៥)ការអនុវត្តតួនាទីនៃរដ្ឋបាលស្រុកក្នុងការលើកកម្ពស់ ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាននៅក្នុងស្រុកប្រាសាទបាល័ង្ក ខេត្តកំពង់ធំ

(៦)ការស្ទង់មតិរបស់ជនមានពិការភាពនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ

(៧)ប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋនៅក្នុងខណ្ឌសែនសុខ

(៨)របាយការណ៍ប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋលើកទី១ ក្នុងឆ្នាំ២០១៨ នៅក្នុងស្រុកថ្មពួកនិង ស្រុកប្រសាទបាល័ង្គ

(៩)របាយការណ៍ប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋលើកទី២ ក្នុងឆ្នាំ២០១៩ នៅក្នុងស្រុកថ្មពួកនិង ស្រុកប្រសាទបាល័ង្គ

ក្រសួងអភិវឌ្ឍជនបទបានយល់ព្រមទទួលយកអនុសាសន៍ និងធ្វើសកម្មភាពលើប្រតិភូកម្មមុខងារនៃអនាម័យជនបទ ទៅរដ្ឋបាលថ្នាក់ស្រុក/ក្រុងអាស្រ័យលើករណីសិក្សាគោលនយោបាយនៅក្នុងស្រុក សំរោងទង ខេត្តកំពង់ស្ពឺ។

ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បានស្វាគមន៍យ៉ាងកក់ក្តៅ និងបានទទួលយកអនុសាសន៍ យោងទៅលើករណីសិក្សាក្នុងស្រុកថ្មពួក ហើយពួកគេបាបធ្វើសកម្មភាពក្នុងការផ្តល់ខាងផ្នែកបច្ចេកទេស និងកម្មវិធីបណ្តុះបណ្តាលជំនាញចិញ្ចឹមជីវិត ទៅជនមានពិការភាព(PwD) នៅស្រុកថ្មពួក។ API បានចូលរួមក្នុងដំណើការជ្រើសរើសជនមានពិការភាព។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលស្គាល់ពីគោលនយោបាយសិក្សា និងអនុសាសន៍លើអ្នកចំណាកស្រុកនៅក្នុងខេត្តបន្ទាយមានជ័យ។

ក្រសួងរៀបចំដែនដីនគរូបនីយកម្មសំណង់និងនគរូបនីយកម្មបានទទួលស្គាល់អនុសាសន៍គោលនយោបាយស្តីពីបញ្ហាចុះបញ្ជីដីធ្លីនៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងហើយពួកគេបានធ្វើសកម្មភាពលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន លើការចុះបញ្ជីកម្មសិទ្ធិដីធ្លី ព្រោះអ្នកភូមិរាប់ពាន់នាក់រស់នៅតាមតំបន់ទន្លេសាបរាប់ជំនាន់មកហើយ ដែលមិនទាន់ចុះឈ្មោះ និងប័ណ្ណកម្មសិទ្ធដីធ្លីនៅឡើយទេ។ បច្ចុប្បន្ននេះ នេះគឺជាបញ្ហាក្តៅគគុកមួយនៅក្នុងខេត្តកំពង់ឆ្នាំង កន្លែងដែលរដ្ឋាភិបាលមិនទាន់បានចុះឈ្មោះធ្វើប័ណ្ណកម្មសិទ្ធឲ្យអ្នកភូមិនៅឡើយទេ ពីព្រោះពួកគេកំពង់រស់នៅក្នុងតំបន់អភិរក្សរបស់រដ្ឋ នៃដងទន្លេសាប។

NCDDS, MoYES, MoH បានយល់ព្រមនៃការរកឃើញ និងអនុសាសន៍សម្រាប់ការបង្កើនការរួមបញ្ចូលអ្នកចូលរួមនៅក្នុងដំណើការរៀបចំផែនការនៅថ្នាក់មូលដ្ឋាន និងរួមបញ្ចូលគុណភាពនៃការបម្រើសេវាសាធារណៈលើការអប់រំ សុខភាព រដ្ឋបាលឃុំ/សង្កាត់ ស្រុក និងប៉ុស្តិ៍រដ្ឋបាលនគរបាល អាស្រ័យទៅលើកប័ណ្ណដាក់ពិន្ទុដោយជនមានពិការភាពដែលរៀបចំដោយ API នៅក្នុងស្រុកត្រាំកក់

ខេត្តតាកែវ របាយការណ៍នៅក្នុងខណ្ឌសែនសុខ និងរបាយការណ៍ប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋលើកទី១ និងទី២នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងស្រុកប្រាសាទបាល្ល័ង្គ ខេត្តកំពង់ធំ។

យោងទៅលើផ្នែកចុងក្រោយនៃការវាយតម្លៃគម្រោងនៃការលើកកម្ពស់សិទ្ធ សម្លេង ជម្រើស និងការសម្រេចចិត្តរបស់ប្រជាពលរដ្ឋ អនុវត្តក្នុងឆ្នាំ ២០១៦-២០១៩ បានវាយតម្លៃដោយ Real Time Evaluation អ្នកប្រឹក្សាយោបល់នៅខែ មករា ឆ្នាំ២០២០។ លទ្ធផលនៃការវាយតម្លៃមានដូចជា៖

គោលបំណង ១៖ សមត្ថភាពបុគ្គល(ស្ត្រី បុរស យុវជន) និងអង្គការសហគមន៍មូលដ្ឋាន បានធ្វើឲ្យប្រសើឡើង ធ្វើឲ្យពួកគេអាចចូលរួមក្នុងដំណើរការសម្រេចចិត្តនៅក្នុងដំណើរការអភិវឌ្ឍឃុំ/សង្កាត់។

**សូចនាករ ១៖** បានកើនឡើង ២០% នៅក្នុងបន្ទាត់កម្រិតនៃតម្រូវការដោយប្រជាពលរដ្ឋ( បានបែងចែកដោយ ភេទ និងក្រុម( ស្ត្រី បុរស យុវជន) នៅក្នុង ៤០ ឃុំសង្កាត់បានដឹងលឺ និងដាក់ចូលទៅក្នុងការអនុវត្ត។

ការស្នើសុំទូទៅសម្រាប់ព័ត៌មានបានកើនឡើងពី ៣៣% នៅក្នុងមធ្យមភាគ ៥២% នៅចង់បញ្ចប់នៃគម្រោង។ការឆ្លើយតបភាគច្រើននិយាយថាពួកគេបានស្នើសុំព័ត៌មានពីអាជ្ញាធរមូលដ្ឋានទាក់ទនទៅនិង សំបុត្រកំណើត សៀវភៅគ្រួសារ សំបុត្រអាពាហ៍ពិពាហ៍ និងអត្តសញ្ញាណប័ណ្ណ។ លើសពីនេះទៅទៀត ពួកគេមួយចំនួនបានស្នើសុំព័ត៌មានអំពី ប័ណ្ណក្រីក្រ សំបុត្រមរណៈភាព ប័ណ្ណកម្មសិទ្ធិដីធ្លី។

ប្រជាពលរដ្ឋទូទៅ ធ្លាប់រអ៊ូរទាំអំពីអាជ្ញាធរ បានកើនឡើងពី ១២% ពាក់កណ្តាល ១៧%នៅចុងបញ្ចប់គម្រោង។ ភាគច្រើននៃប្រជាពលរដ្ឋបានលើកឡើងពីការរអ៊ូរទាំអំពីការយឺតយ៉ាវនៃការឆ្លើយតបឬក៏ខ្វះការឆ្លើយតប នៅពេលដែលប្រជាពលរដ្ឋទៅទទួលសេវា សុំជំនួយឬព័ត៌មាន។

ប្រជាពលរដ្ឋមួយចំនួនទៀតបានរអ៊ូរទាំអំពីការបំពេញតួនាទីរបស់អាជ្ញាធរមូលដ្ឋាន(LA) ដូចជាខ្វះថវិកាចំណាយទៅលើការសាងសងហេដ្ឋារចនាសម្ព័ននៅមូលដ្ឋាន ផ្លូវគ្មានគុណភាពហើយជាក់ស្តែងអាជ្ញាធរមូលដ្ឋានមិនបានយកចិត្តទុកដាក់ទៅលើការសាងសងឬជួសជុលផ្លូវទាំងអស់នោះឡើយ។ មានការរអ៊ូរទាំផ្សេងទៀតទៅលើការយកលុយលើសតម្លៃសេវា និងសន្តិសុខសង្គមឧទាហរណ៍ដូចជាក្មេងទំនើង គ្រឿងញៀនឬក៏ល្បែងស៊ីសងជាដើម អាជ្ញាធរមូលដ្ឋានមិនសូវរស់រាយរាក់ទាក់ និងប្រើប្រាស់ពាក្យសម្តីអសុរោះពេលពលរដ្ឋទៅសួរព័ត៌មាន។

ក្រៅពីនោះអ្នកដែលមិនបានរអ៊ូរទាំ ពួកគេបានផ្តល់ជាអនុសាសន៍ដែរថាមិនមានបញ្ហាឬរឿងរ៉ាវអីធំដុំនោះទេហើយអាជ្ញាធរមូលដ្ឋានបានបំពេញតួនាទីរបស់ពួកគាត់បានយ៉ាងល្អ។ បន្ថែមពីនេះទៅទៀតប្រជាពលរដ្ឋនៅមូលដ្ឋានបានបញ្ជាក់ដែរថាពួកគេចង់រស់នៅក្នុងសហគមន៍ពោលពេញដោយសន្តិភាព ខណៈពេលដែលអ្នកខ្លះទៀតបាននិយាយថាពួកគេភ័យខ្លាចក្នុងការត្អូញត្អែរទៅកាន់អាជ្ញាធរ។

ជាទូទៅប្រជាពលរដ្ឋដែលធ្លាប់ទៅទទួលសេវាពីអាជ្ញាធរបានកើនឡើង ៣៩%នៅពាក់កណ្តាលទៅ ៦៨%នៅចុងក្រោយនៃគម្រោង។ ភាគច្រើនអ្នកដែលទៅទទួលសេវាទាក់ទងទៅនឹង សំបុត្រកំណើត សៀវភៅគ្រួសារ/សៀវភៅស្នាក់នៅ សំបុត្រអាពាហ៍ពិពាហ៍ អត្តសញ្ញាណប័ណ្ណ ប័ណ្ណក្រីក្រ សំបុត្រមរណៈភាព ប័ណ្ណម្ចាស់កម្មសិទ្ធិដីធ្លី។ ប្រជាពលរដ្ឋខ្លះទៅទទួលសេវាលើការសាសង់ និងជួសជុលផ្ទះសម្បែង ផ្លូវថ្នល់ សាលារៀន និងប្រព័ន្ធធារាសាស្រ្ត និងអណ្តូងទឹកជាដើម។ ៧៣% នៃស្រ្តីងាយរងគ្រោះបានស្នើសុំការផ្តល់សេវាពីអាជ្ញាធរមូលដ្ឋាន។

**សូចនាករ ២៖** បានកត់សម្គាល់ឃើញពីក្តីព្រួយបារម្ភ និងបញ្ហាគឺត្រូវបានរួមបញ្ចូលទៅក្នុងគម្រោងអភិវឌ្ឍឃុំ និងគម្រោងវិនិយោគឃុំ (CIP) ហើយនិងគម្រោងអភិវឌ្ឍថ្នាក់ស្រុក (DDP)

CBOs ដែលបានលើកឡើងពីក្តីព្រួយបារម្ភ និងបញ្ហាជាមួយ និងអាជ្ញាធរមូលដ្ឋានរបស់ពួកគេបានតិចតួចប៉ុណ្ណោះ ពី៩២%នៅពាក់កណ្តាលគម្រោង ទៅ៩១%នៅចុងក្រោយនៃគម្រោង។ ទោះជាយ៉ាងនេះក៏ដោយសមាមាត្រនៃសមាជិក CBOs ដែលជាស្រីក្នុងការលើកឡើងពីបញ្ហាបានកើនឡើងពី ៧១% នៅពាក់កណ្តាលគម្រោងទៅ ៨៦% នៅចុងក្រោយនៃគម្រោង។
ក្តីព្រួយបារម្ភចម្បងបានលើកឡើងដោយ CBOs គឺបញ្ហាគុណភាពផ្លូវថ្នល់ ស្នើសុំឲ្យសាងសងសាលារៀន និងមន្ទីរពេទ្យ ភូមឃុំមានសុវត្ថិភាព ឯកសារទូទៅ(សំបុត្រកំណើត សៀវភៅគ្រួសារ សំបុត្រអាពាហ៍ពិពាហ៍ និងអត្តសញ្ញាណប័ណ្ណ សំបុត្រមរណៈភាព ) និងបញ្ហាដែលទាក់ទងទៅ និងកង្វះខាតទឹកស្អាត និងកាជួយដោះស្រាយបញ្ហាឲ្យបានឆាប់រហ័ស។

CBOs បានចង្អុលបង្ហាញថា បញ្ហាសរុប ៨០ត្រូវបានរាប់បញ្ចូលនៅគម្រោងឃុំ និងស្រុកផ្សេងគ្នា ជាមធ្យមភាគ CBOs ម្នាក់មានមួយទៅ២ បញ្ហា។

**គោលបំណង ២៖** សមត្ថភាពអ្នកប្រឹក្សាយោបល់ថ្នាក់មូលដ្ឋានគឺត្រូវបានពង្រឹងជាមួយនិងអង្គការសហគមន៍និង NGOs ដើម្បីឆ្លើយតបនិងតម្រូវការសាធារណៈ។

**សូចនាករ ៣៖** បានកើនឡើងពី ៧៦%ទៅ៨៥%នៃប្រជាពលរដ្ឋ ក្នុងការបង្ហាញការពេញចិត្តទៅលើការបំពេញតួនាទីរបស់អាជ្ញាធរ (ការដោះស្រាយបញ្ហា ការផ្តល់សេវានិងការបើកចំហរព័ត៌មានថវិកា) នៃអាជ្ញាធរដែលជាប់ឆ្នោតនិងរដ្ឋាភិបាល។

សរុបមកការពេញចិត្តរបស់ប្រជាពលរដ្ឋលើអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយបញ្ហាបានកើនឡើងពី ៦៨%នៅពាក់កណ្តាលគម្រោងទៅ ៩៥%នៅចុងក្រោយនៃគម្រោង។ ទាំងអស់នេះគឺជាការពេញចិត្តនៃការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋានដែលបានជួយដោះស្រាយជម្លោះនិងបញ្ហាដែលតែងតែកើតមាននៅក្នុងសហគមន៍បានយ៉ាងល្អ។ ទោះបីជាយ៉ាងណាក៏ដោយប្រជាពលរដ្ឋដែលមិនពេញចិត្តបាននិយាយថាពួកគេត្រូវការផ្តល់ថវិកាបន្ថែមសម្រាប់សេវាសាធារណៈហើយពេលខ្លះពួកគេមើលឃើញការឆ្លើយតបយឺតយ៉ាវឬក៏មិនមានការគាំទ្រពីអាជ្ញាធរ។ ១០០% នៃស្ត្រីដែលងាយរងគ្រោះបានពេញជាមួយនិងការដោះស្រាយបញ្ហារបស់អាជ្ញាធរជូនពួកគាត់។

ជារួមមកការពេញចិត្តដោយប្រជាពលរដ្ឋលើអាជ្ញាធរក្នុងការផ្តល់សេវាសាធារណៈបានកើនឡើងពី ៧៨% នៅពាក់កណ្តាល់គម្រោងទៅ ៩៧%នៅចុងក្រោយគម្រោង។ ការពេញចិត្តទាំងអស់នេះចំពោះការឆ្លើយតបដែលអាជ្ញាធរបានផ្តល់ឲ្យពួកគេស្មើរភាពគ្នាឬការតម្លៃសាវាសមរម្យ ហើយនិងធ្វើឯកសារៀងលឿននិងឆាប់រហ័សជាងមុន។ តែទោះបីជាយ៉ាងណាក៏ដោយប្រជាពលរដ្ឋដែលមិនបានពេញចិត្តជាមួយនិងអាជ្ញាធរ បានស្នើសុំថវិការសម្រាប់បម្រើក្នុងសេវាសាធារណៈបន្ថែមទៀត ដោយសារពេលខ្លះការឆ្លើយតបរៀងយឺតយ៉ាវនិងផ្លូវថ្នល់គ្មានគុណភាព។ ១០០%នៃស្ត្រីដែលងាយរងគ្រោះបានពេញចិត្តជាមួយនិងការផ្តល់សេវាសារធារណៈរបស់អជ្ញាធរមូលដ្ឋាន។

សរុបមកការពេលចិត្តដោយប្រជាពលរដ្ឋជាមួយអាជ្ញាធរមូលដ្ឋានក្នុងការចែករំលែងព័ត៌មានថវិកាបានថយចុះពី ៦១%នៅពាក់កណ្តាលគម្រោង ទៅ៤២%នៅចុងក្រោយនៃគម្រោង។ បន្ទាប់ពីការវាយតម្លៃ ៥៤%នៅចុងក្រោយនៃគម្រោងនៃប្រជាពលរដ្ឋដែលបានឆ្លើយតបដែលថាពួកគេមិនដែលបានដឹងពីអំពីព័ត៌មានថវិការរបស់ឃុំ/សង្កាត់ពីមុនមកនោះទេ ហើយអ្នកដេលពេញចិត្ត ៤២%បានផ្តល់អនុសាសន៍ថាព័ត៌មានថវិការដែលពួកគេបានដឹងតាមរយៈការប្រជុំភូមិឬតាមរយៈមេភូមិជារៀងរាល់ខែនៅ

តាមវេទិការសាធារណៈ ហើយនិងវេទិកានានានៅក្នុងសហគមន៍។ លើសពីនេះទៅទៀតប្រជាពលរដ្ឋមួយចំនួនបាននិយាយថាពួកគេបានដឹងពីព័ត៌មានថវិការពេលដែលក្រុមយុវជនចុះមកផ្សព្វផ្សាយព័ត៌មាននៅតាមផ្ទះ។ កំឡុងពេលដែលមនុស្សពីរបីនាក់បាននិយាយថាពួកគេមិនបានខ្វល់ខ្វាយអំពីថវិកានិងជាជាទុកឲ្យឃុំសម្រេចបែងចែកថវិកាទាំងនោះ ។២៧%នៃស្ត្រីដែលងាយរងគ្រោះបានពេញចិត្តចំពោះការចែករំលែកព័ត៌មានថវិការបស់អាជ្ញាធរ។

គួរឱ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថាពលរដ្ឋដែលបានទៅទស្សនាសាលសហគមន៍កាលពីឆ្នាំកន្លងមកបានធ្លាក់ចុះពី 45% នៅពាក់កណ្តាលគម្រោងដល់ 36% នៅចុងបញ្ចប់នៃគម្រោង។ (ការស្ទង់មតិពលរដ្ឋក្នុងតំបន់ Q៧) ក្នុងចំណោមអ្នកដែលបានទៅទស្សនាសាលសហគមន៍ភាគច្រើនបាននិយាយថាពួកគេបានទៅទស្សនាសាល" ពេលខ្លះ" ។ ក្នុងចំណោមអ្នកដែលមិនបានមកទស្សនាសាលសហគមន៍ភាគច្រើនបាននិយាយថាពួកគេមិនមានបញ្ហា រឺមានអ្វីស្នើសុំរឺក៏រវល់ហើយមិនមានពេលទៅ។ ខណៈពេលដែលប្រជាពលរដ្ឋមួយចំនួនបានលើកឡើងថាពួកគេទៅតែការិយាល័យភូមិតែប៉ុណ្ណោះ។ ពលរដ្ឋពីបីនាក់បាននិយាយថាពួកគេមិនហ៊ានទៅសាលាឃុំទេ។

ដោយសារប្រជាពលរដ្ឋភាគច្រើនមិនបានទៅសាលាឃុំរបស់ពួកគេ ដែលអាចជឿបានថាពួកគេប្រហែលជាមិនដឹងថាព័ត៌មានថវិកានៅសាលាឃុំឡើយ។ ទោះយ៉ាងណាក៏ដោយ អាជ្ញាធរមូលដ្ឋានខាងក្រោមនៅក្នុងសូចនាករ ៥.៣ ផ្តល់យោបល់ថាពួកគាត់ មិនត្រឹមតែបង្ហាញនៅលើក្តារព័ត៌មានប៉ុណ្ណោះទេក៏ផ្សព្វផ្សាយព័ត៌មានថវិកានៅក្នុងវេទិកាសាធារណៈផង។

ចំនួនអាជ្ញាធរដែលបានចូលរួមប្រជុំជាមួយ CBO ដើម្បីដោះស្រាយបញ្ហាក្នុងមូលដ្ឋានបានកើនឡើងពី ៧៣% នៅពាក់កណ្តាលទៅ ១០០ ភាគរយនៅចុងបញ្ចប់គម្រោង។ បញ្ហាដែលអាជ្ញាធរបានលើកឡើងរួមមាន៖ ប័ណ្ណកម្មសិទ្ធិដីធ្លី ផ្លូវថ្នល់ឬគុណភាពហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខសហគមន៍និងឯកសារផ្សេងៗ (កំណើតមរណភាព សំបុត្រអាពាហ៍ពិពាហ៍និងអត្តសញ្ញាណប័ណ្ណ) ការឆ្លើយតបនឹងគ្រោះមហន្តរាយ (ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ) សៀវភៅគ្រួសារ / សៀវភៅស្នាក់នៅ បញ្ហាសុខភាព និងសត្វ (ការការពារជំងឺឆ្លង) ការស្នើសុំឱសថនិងការអនុញ្ញាតឱ្យសាងសង់ឬជួសជុលផ្ទះ។

អាជ្ញាធរបានផ្តល់អនុសាសន៍ថាការចូលរួមជាមួយCBOពិតជាមានសារៈសំខាន់និងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន។ជាការឆ្លើយតបកិច្ចប្រជុំបានផ្តល់ឱកាសដល់ប្រជាពលរដ្ឋក្នុងការលើកឡើងនូវ

បញ្ហានិងកង្វល់នានានិងដើម្បីអោយអាជ្ញាធរស្វែងយល់អំពីបញ្ហាក្នុងមូលដ្ឋានអោយបានទាន់ពេលវេលា។

**សូចនាករ ៤៖** យ៉ាងហោចណាស់ ៣០% (បង្កើនលើមូលដ្ឋាន) នៃក្រុមប្រឹក្សាមូលដ្ឋានទាំងអស់បានបង្កើនការចូលរួម និងសហការជាមួយ CBOs និង CSOs

ចំនួនអាជ្ញាធរដែលបានចូលរួមប្រជុំជាមួយ CBO ដើម្បីដោះស្រាយបញ្ហាក្នុងមូលដ្ឋានបានកើនឡើងពី ៧៣% នៅពាក់កណ្តាលទៅ ១០០%នៅចុងបញ្ចប់។ បញ្ហាដែលអាជ្ញាធរបានលើកឡើងរួមមាន៖ ប័ណ្ណកម្មសិទ្ធិដីធ្លី ផ្លូវថ្នល់ឬគុណភាពហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាពសហគមន៍ ឯកសារស៊ីវិល (សំបុត្រកំណើត សំបុត្រមរណៈភាព សំបុត្រអាពាហ៍ពិពាហ៍និងអត្តសញ្ញាណប័ណ្ណ) ការឆ្លើយតបនឹងគ្រោះមហន្តរាយ (ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ) សៀវភៅ គ្រួសារ / សៀវភៅស្នាក់នៅ បញ្ហាសុខភាពមនុស្សនិងសត្វ (ការការពារជំងឺឆ្លង) ការស្នើសុំឱសថ និងការអនុញ្ញាតឱ្យសាងសង់ឬជួសជុលផ្ទះ។

អាជ្ញាធរបានផ្តល់អនុសាសន៍ថាការចូលរួមជាមួយCBOពិតជាមានសារៈសំខាន់ និងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន។ជាការឆ្លើយតបកិច្ចប្រជុំបានផ្តល់ឱកាសដល់ប្រជាពលរដ្ឋក្នុងការលើកឡើងនូវបញ្ហានិងកង្វល់នានានិងដើម្បីអោយអាជ្ញាធរស្វែងយល់អំពីបញ្ហាក្នុងមូលដ្ឋានអោយបានទាន់ពេលវេលា។
"ពួកយើងចង់ដឹងអំពីបញ្ហាដែលកើតមានឡើងនៅក្នុងសហគមន៍ ដូច្នេះទើបពួកយើងអាចដោះស្រាយបញ្ហាទាំងអស់នោះបាន។កន្លងមកប្រជាពលរដ្ឋមិនហ៊ានលើកឡើងពីបញ្ហានានាដែលពួកគាត់ជួបប្រទះនៅឡើយទេ ប៉ុន្តែបន្ទាប់ពីការចុះទៅផ្សព្វផ្សាយ [យោងលើសកម្មភាពគម្រោង] ពលរដ្ឋបានលើកឡើងពីបញ្ហានិងតម្រូវការនានានៅក្នុងឃុំហើយពួកគាត់ចាប់អារម្មណ៍ចង់ដឹងពីព័ត៌មានថវិការរបស់ឃុំ។ ឥឡូវនេះពួកយើងដឹងពីតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍". [អាជ្ញាធរមូលដ្ឋនា FGD]

**សូចនាករទី ៥៖** ការបើកចំហរព័ត៌មានត្រូវបានកើនឡើងពី ៣៩% ទៅ ៦០% នៅឆ្នាំ ២០១៩ សម្រាប់សេវាធារណៈ គោលនយោបាយ បទដ្ឋាននិងព័ត៌មានថវិកាហើយអាចផ្សព្វផ្សាយបានជាសាធារណៈ

អាជ្ញាធរទាំងអស់ដែលត្រូវបានសម្ភាសទាំងពាក់កណ្តាលនិងចុងបញ្ចប់នៃគម្រោងបានឆ្លើយតបថាពួកគេបានបង្ហាញថ្លៃសេវាសាធារណៈដល់ប្រជាជននៅក្នុងសហគមន៍របស់ពួកគេ។ អាជ្ញាធឬមូលដ្ឋានបានលើកឡើងទៀតថាពួកគេបានបង្ហាញបញ្ជីតម្លៃសេវាសាធារណៈនៅលើក្តារព័ត៌មាននៅសាលាឃុំ

និងនៅការិយាល័យភូមិនីមួយៗ។ ព័ត៌មានបញ្ជីថ្លៃសេវាលើឯកសារទូទៅដូចជាសំបុត្រកំណើតមរណភាពនិងសំបុត្រអាពាហ៍ពិពាហ៍។ អ្នកចុះបញ្ជីក្នុងកំឡុងពេលការវាយតម្លៃបានផ្ទៀងផ្ទាត់ថាព័ត៌មានដែលជាប់ពាក់ព័ន្ធទាំងនេះត្រូវបានបង្ហាញនៅសាលាឃុំ។

"យើងមិនត្រឹមតែបិទផ្សាយព័ត៌មានជាសាធារណៈប៉ុណ្ណោះនោះទេ ប៉ុន្តែយើងក៏បានបិទនៅគ្រប់ការិយាល័យភូមិទាំងអស់ផងដែរ។ យើងក៏បានបិទពីកញ្ចប់ថវិកាឃុំនៅលើក្តាខៀនព័ត៌មានហើយនិងចុះទៅផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋនៅតាមទីសាធារណៈអំពីការផ្តល់សេវាសាធារណៈ ដូចជាសៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រមរណៈភាព សំបុត្រអាពាហ៍ពិពាហ៍ហើយនិងព័ត៌ពលរដ្ឋចំណាកស្រុក" ។ [អាជ្ញាធរមូលដ្ឋាន FGD]

អាជ្ញាធរទាំងអស់ដែលត្រូវបានសម្ភាសទាំងពាក់កណ្តាលនិងចុងបញ្ចប់នៃគម្រោងបានប្រាប់ថាពួកគេចែករំលែកឬលើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយ / ច្បាប់ / ច្បាប់មូលដ្ឋានដល់ប្រជាជននៅក្នុងសហគមន៍របស់ពួកគេ។ អាជ្ញាធរបានប្រាប់ថាពួកគេបានផ្សព្វផ្សាយព័ត៌មានទាំងនោះក្នុងពេលប្រជុំឃុំនិងវេទិកាសាធារណៈ ហើយថែមទាំងបង្ហាញព័ត៌មាននៅលើក្តារខៀនព័ត៌មានជាសាធារណៈថែមទៀតផង។ ប្រធានបទ / បញ្ហាដែលពួកគេចែករំលែករួមមាន៖ សិទ្ធិកុមារ ច្បាប់ចរាចរណ៍ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ គ្រឿងញៀននៅក្នុងសហគមន៍និងច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍។

អាជ្ញាធរទាំងអស់ដែលត្រូវបានសម្ភាសទាំងពាក់កណ្តាលនិងចុងបញ្ចប់នៃគម្រោងបានប្រាប់ថាពួកគេបានបង្ហាញរបាយការថវិកាដល់ពលរដ្ឋដែលរស់នៅក្នុមូលដ្ឋាន។ អាជ្ញាធរក៏បានប្រាប់ថាពួកគេបានបង្ហាញរបាយស្តីពីព័ត៌មានថវិកា (ដូចជាចំនួនលុយដែលប្រើប្រាស់សម្រាប់ការសាងសងហេដ្ឋារចនាសម្ព័ន) ហើយកញ្ចប់ថវិកាឃុំក៏ត្រូវបានបើបង្ហាញនៅការមានការប្រជុំឃុំផងដែរ។ អាជ្ញាធរមូលដ្ឋានបានសុំឲ្យមេភូមិជួយចែករំលែកព័ត៌មានថវិកាដល់បងប្អូនប្រជាពលរដ្ឋនិងយុវជនដែលបានជួយចុះផ្សព្វផ្សាយសកម្មភាពនៅក្នុងសហគមន៍ផងដែរ ព្រោះពួកគេមានច្រើទំនេរច្រើនជាងមន្ត្រីរដ្ឋាភិបាល។

ពួកយើគិតថាពេលដែលបើកចំហរព័ត៌មានថវិកានៅសាលាឃុំ ប្រជាពលរដ្ឋនឹងមិនមកមើលវាឡើយដូច្នេះពួកយើងបានចុះផ្សព្វផ្សាយព័ត៌ស្តីពីរបាយការមានថវិកា កំឡុងពេលកិច្ចប្រជុំដូចជាការបិទតារាងព័ត៌មាននៅសាលាឃុំផងដែរ។ [អាជ្ញាធរមូលដ្ឋាន FGD]

**គោលបំណង ៣៖** លើកកម្ពស់ភាពជាដៃគូរវាងរដ្ឋាភិបាលនិងសង្គមស៊ីវិលដើម្បីឆ្លើយតបតម្រូវការនិងក្តីព្រួយបារម្ភដល់ធារណៈជន

**សូចនាករទី ៦៖** យ៉ាងហោចណាស់មានគម្រោងរួមគ្នាចំនួន ២ ក្នុងមួយស្រុកត្រូវបានអនុវត្តដោះស្រាយសេវា សង្គម ធនធានធម្មជាតិ  ការគ្រប់គ្រងបរិស្ថាននិងអនាម័យនិងបញ្ហាអនាម័យ

មន្ត្រីគម្រោងនិងរបាយការណ៍សង្ខេបអំពីគម្រោងបានបង្ហាញថាយ៉ាងហោចណាស់មានគម្រោងរួមគ្នាចំនួន២ ក្នុងមួយស្រុកត្រូវបានអនុវត្ត។ ពីរបាយការណ៍សង្ខេបពីខែមករាដល់ខែមិថុនាឆ្នាំ ២០១៩ (BfdW)៖ៈគម្រោងរួមគ្នាចំនួន ១៨ ត្រូវបានអនុវត្តឬត្រូវបានអនុវត្តដោយដោះស្រាយសេវាសង្គម ធនធានធម្មជាតិ ការគ្រប់គ្រងបរិស្ថាន អនាម័យនិងបញ្ហាអនាម័យជាមួយភាពជាដៃគូនិងការចូលរួមចំណែកសរុប ៧.៤០៦ ដុល្លារអាមេរិកដោយអាជ្ញាធរ វិស័យឯកជន CBOs និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។

**សូចនាករទី ៧៖** សមាជិកអង្គការសង្គមស៊ីវិល / CBOs បានបង្កើនការចូលរួមនិងការចូលរួមរបស់ពួកគេតាមរយៈមុខងារនិងឆ្លើយតបយន្តការសម្របសម្រួលក្នុងតំបន់ដែលមានកម្រិតខុសគ្នាពី ៨% ទៅ ៣៥%

ចំនួន CBOs ដែលបានចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំបានកើនឡើងពី ៨% នៅដើមគម្រោងទៅ ៨៨%នៅពាក់កណ្តាលគម្រោងដល់ ៩១% ភាគរយនៅចុងបញ្ចប់គម្រោង។ CBOs បានលើកឡើងថាពួកគេភាគច្រើនបានជួបគ្នា ដើម្បីពិភាក្សាពីសុវត្ថិភាព អំពើហឹង្សាក្នុងសហគមន៍ ការអភិវឌ្ឍសហគមន៍ គុណភាពផ្លូវថ្នល់ឬសំណង់ហេដ្ឋារចនាសម្ព័ន្ធនិងថវិកាឃុំ (ចំណូលនិងចំណាយ) ដំណើរការឯកសាររបស់ពលរដ្ឋកង្វះទឹកស្អាតនិងអនាម័យ។  អង្គការសហគមន៍ដែលមិនបានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ភាគច្រើនបានផ្តល់យោបល់ថាពួកគេមិនត្រូវបានគេអញ្ជើញឱ្យចូលរួមក្នុងការប្រជុំទេ។

៨៨% នៃ CBOs ចាប់ពីផ្តើមនិងបញ្ចប់គម្រោងបានាប្រាប់ថាពួកគេមិនមានភស្តុតាងដើម្បីបញ្ជាក់ពីការរួមចំណែករបស់ពួកគេជាមួយនិងក្រុមប្រឹក្សាឃុំ ក្នុងការដោះស្រាយបញ្ហារបស់ពួកគេនៅក្នុងសហគមន៍។ ភស្តុតាងនោះរួមមានបញ្ជីឈ្មោះការចូលរួម ការអញ្ជើញពីក្រុមប្រឹក្សាឃុំ របៀបវារៈកំណត់ហេតុប្រជុំនិងរូបថតនៃកិច្ចប្រជុំ។
យោងទៅលើការវាយតម្លៃបញ្ចប់គម្រោងនៅខែមករា ២០២០ គម្រោងវាយតម្លៃសម្រាប់ថ្ងៃទី ២៣/២៥ ។ សម្រេចបាន ៩២%

**ជាប់ពាក់ព័ន្ធ៖** ផ្អែកលើឯកសារវាយតម្លៃនៃការស្រាវជ្រាវនៅមូលដ្ឋាន ការវាយតំលៃបានរកឃើញថា គម្រោងនេះមានភាពស៊ីគ្នាទៅនឹងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការថ្នាក់ជាតិ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ។ ទាំងពីរនេះគឺមានគោលបំណងលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងអភិបាលកិច្ចមូលដ្ឋាននិងការធ្វើសេចក្តីសម្រេចចិត្ត។ លើសពីនេះទៅទៀតទោះបីមានការផ្លាស់ប្តូរបរិបទនយោបាយនិងការផ្លាស់ប្តូរសកម្មភាពគម្រោងក៏ដោយក៏គម្រោងនៅតែអាចមានភាពពាក់ព័ន្ធនិងស្របតាមការកែទម្រង់របស់រដ្ឋាភិបាលនៅក្នុងមូលដ្ឋាននិងតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិរបស់ពួកគេ ដើម្បីទាមទារការបម្រើសេវានិងការបំពេញតួនាទីនៅក្នុងមូលដ្ឋានឲ្យកាន់តែល្អប្រសើរ ហើយចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៃការអភិវឌ្ឍសហគមន៍។ ការវាយតម្លៃ ៥/៥ ។

ប្រសិទ្ធភាព៖ ខណៈដែល API នឹងបញ្ចប់គម្រោងដោយចំណាយថវិកាត្រឹមតែ ៩៥% នៃថវិកាគម្រោងសម្រាប់សកម្មភាពគម្រោងភាគច្រើនត្រូវបានបញ្ចប់ទាន់ពេលវេលានិងការគ្រប់គ្រងគម្រោងរបស់ API អាចកាត់បន្ថយកត្តាខាងក្រៅដែលជាបុព្វហេតុរួមចំណែកដល់ការពន្យារពេលក្នុងសកម្មភាពគម្រោង។ និងការចំណាយ។ ការវាយតម្លៃ ៤/៥ ។

**ប្រសិទ្ធភាព៖** គម្រោងសម្រេចបានទាំងស្រុងនូវសូចនាករចំនួន ៦ ក្នុងចំណោមសូចនាករទាំង ៧ ដែលមានសូចនាករតែមួយប៉ុណ្ណោះដែលសម្រេចបានដោយផ្នែក (៦៦%) ។ នេះគឺជាសមិទ្ធិផលគួរឱ្យកត់សម្គាល់ជាពិសេសដែលគម្រោងត្រូវការផ្លាស់ប្តូរសកម្មភាពរបស់ខ្លួនបន្ទាប់ពីប្រតិបត្តិការ ឆ្នាំទី១។ កត្តាដែលបានរួមចំណែកដល់សមិទ្ធិផលនេះរួមមានការផ្តោតអារម្មណ៍ជាបន្តបន្ទាប់របស់គម្រោងទៅលើការគាំទ្រផ្អែកតម្រូវការនៃគណនេយ្យភាពសង្គម ការបន្តគាំទ្ររបស់រដ្ឋាភិបាលសម្រាប់ការចូលរួមរបស់ពលរដ្ឋនិងភាពបត់បែនរបស់ម្ចាស់ជំនួយក្នុងការផ្លាស់ប្តូរសកម្មភាពរបស់គម្រោង។ ការវាយតម្លៃ ៥/៥ ។

ផលប៉ះពាល់:គម្រោងបានផ្តល់លទ្ធផលល្អវិជ្ជមានដល់ក្រុមគោលដៅ។ ការបង្កើនសមត្ថភាពរបស់ CBOs ការបង្កើនការចូលរួមរបស់ស្ត្រីក្នុងអភិបាលកិច្ចមូលដ្ឋាន ការបង្កើនការចូលរួមរបស់អាជ្ញាធរនិងការលើកកម្ពស់ដំណើរការអភិវឌ្ឍន៍សហគមន៍។ ការវាយតម្លៃ ៥/៥ ។

និរន្តរភាព៖ គម្រោងមានកម្រិតនិរន្តរភាពខ្ពស់ដែលត្រូវបានបង្កើតឡើងក្នុងការរចនារបទរបស់ខ្លួនដែលសកម្មភាពគម្រោងមានគោលបំណងបង្កើនចំណេះដឹង សមត្ថភាពនិងជំនាញរបស់អ្នកទទួលផល

គោលដៅ។ គម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ អភិបាលកិច្ចមូលដ្ឋាននិងអ្នកជាប់ពាក់ព័ន្ធក្នុងគម្រោង (អាជ្ញាធរ ប្រជាពលរដ្ឋនិងដំណើរការអភិវឌ្ឍន៍សហគមន៍) ដែលនឹងនៅតែមានដំណើរការបន្ទាប់ពីបញ្ចប់គម្រោង។ គុណវិបត្តិតែមួយគត់ចំពោះនិរន្តរភាពនៃគម្រោងគឺថា CBOs ខ្លួនឯងមិនអាចនៅគង់វង្សបានដោយគ្មានការផ្តល់មូលនិធិជួយជាប្រចាំទេនោះ។ ការវាយតម្លៃ ៤/៥ ។

**មេរៀនដែលបានរៀន៖**

- នៅពេលដែលគម្រោងនេះជះឥទ្ធិពលដល់ក្រុមជនជាតិភាគតិច គម្រោងមិនត្រូវបានបង្កើតឡើងជាពិសេសសម្រាប់តែភាគីពាក់ព័ន្ធមាន (យុវជន ស្ត្រី ស្ត្រីងាយរងគ្រោះ មនុស្សចាស់និង PWD) នោះ។ សកម្មភាពដែលត្រូវបានរៀបចំឡើងសម្រាប់អ្នកពាក់ព័ន្ធទាំងនេះអាចផ្តល់នូវលទ្ធផលស៊ីជម្រៅ។ សម្រាប់គោលដៅនៅថ្ងៃអនាគត អ្នកដឹកនាំយុវជនដែលបានទទួលការបណ្តុះបណ្តាលអាចមានសក្តានុពលក្នុងការនាំមុខ CBOs, NGOs ឬ LAs ។

- CBOs នឹងមិនអាចនៅស្ថិតស្ថេរបន្តរទៅមុខទៀតដោយប្រើប្រាស់ហិរញ្ញវត្ថុរបស់ជាប្រចាំបានទេ។ អាចមានប្រយោជន៍ក្នុងការដាក់បញ្ចូលទៅក្នុងសកម្មភាពគំរោងនាពេលអនាគតនិងជំនួយអភិវឌ្ឍន៍សំរាប់អង្គការសម្រាប់ CBOs។ជំនួយបែបនេះអាចរួមបញ្ចូលទាំងការបង្កើតយុទ្ធសាស្ត្រផ្តល់មូលនិធិ និងការធ្វើការកែទម្រង់រចនាសម្ព័ន្ធរបស់អង្គការ ហើយធ្វើការជាមួយ CBOs ផ្សេងទៀតដើម្បីស្វែងរកនិងកេងចំណេញលើការរួមបញ្ចូលគ្នា។

- ការយល់ដឹងអំពីព័ត៌មានហិរញ្ញវត្ថុនិងថវិកាឃុំសង្កាត់នៅតែមានកម្រិតទាបក្នុងចំណោមប្រជាពលរដ្ឋមូលដ្ឋាន ដោយមានប្រជាពលរដ្ឋជាច្រើនជឿជាក់ថាព័ត៌មានថវិកាមិនពាក់ព័ន្ធនឹងពួកគេនិងជាទំនួលខុសត្រូវដែលជាកម្មសិទ្ធិរបស់អាជ្ញាធរមូលដ្ឋាន។ លើសពីនេះទៀតអាចមានពលរដ្ឋដែលមិនចេះអក្សរហើយមិនយល់ពីព័ត៌មានថវិកា ដូច្នេះហើយទើបពួកគេមិនគិតថាវាសំខាន់សម្រាប់ពួកគេទេ។ អន្តរាគមន៍នាពេលអនាគតចាំបាច់ត្រូវផ្តោតលើថវិកានេះ (បង្កើនចំណេះដឹងការយល់ដឹងនិងតម្រូវការ) ដើម្បីធានាថាអាជ្ញាធរឬមានគណនេយ្យភាពថវិកា។

- បីមានការចលាចលនយោបាយក្នុងឆ្នាំ ២០១៧ ដែលបញ្ឈប់សកម្មភាពគម្រោងជាបណ្តោះអាសន្នក៏ដោយក៏រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែបន្តគាំទ្រគណនេយ្យភាពសង្គម។ ការគាំទ្រ

របស់រដ្ឋាភិបាលចំពោះការចូលរួមរបស់ពលរដ្ឋនៅក្នុងរដ្ឋាភិបាលមូលដ្ឋានបានជួយឱ្យគម្រោងនេះនៅតែមានជាប់ទាក់ទងនិងនៅតែមានផលប៉ះពាល់ដដែល។

- ម្ចាស់ជំនួយគម្រោង BfdW និង DCA មានភាពបត់បែនខ្លាំង (ទាក់ទងនឹងការធ្វើរបាយការណ៍ថវិកានិងផែនការការងារ) និងបានបង្ហាញនូវការជឿទុកចិត្តនិងទំនុកចិត្តខ្ពស់ទៅលើការងាររបស់ API ។ ទំនាក់ទំនងការងារប្រភេទនេះមិនអាចកាត់ថ្លៃបាននិងជួយដល់ការគ្រប់គ្រងគម្រោងជាពិសេសនៅពេលមានតម្រូវការផ្លាស់ប្តូរគម្រោង។

- ខណៈពេលដែលគម្រោងនេះអាចសម្រេចបានសូចនាកររបស់ខ្លួនគម្រោងអាចទទួលបានអត្ថប្រយោជន៍ពីការមានសូចនាករនិងវិធីសាស្ត្រដែលបានកំណត់ច្បាស់លាស់ជាងមុនដើម្បីគណនា។ ប្រការនេះអាចជួយឱ្យមានការវិភាគនិងការប្រៀបធៀបកាន់តែស៊ីជម្រៅរវាងទិន្នន័យវាយតម្លៃ (ផ្តើម ពាក់កណ្តាលនិងចុងបញ្ចប់) ពេញមួយគម្រោង។

- នៅពេលដែលប្រជាពលរដ្ឋក្នុងតបន់ត្រូវបានគេសួរថាតើពួកគេដឹងថាAPI បានអនុវត្តសកម្មភាពគម្រោងនៅក្នុងស្រុករបស់ពួកគេដែរទេពួកគេទាំងអស់បានឆ្លើយថា"ទេ" ទោះយ៉ាងណានៅពេលដែលបានស៊ើបអង្កេតបន្ថែមទៀតវាបានបង្ហាញថាពួកគេបានចូលរួមសកម្មភាពជាមួយ API យ៉ាងពិតប្រាកដ គ្រាន់ពួកគេមិនបានដឹងថាវាត្រូវបានរៀបចំឡើងដោយ API ។ នេះប្រហែលជាការឆ្លុះបញ្ចាំងពីបញ្ហាផ្សេងៗគ្នា។ ទីមួយពលរដ្ឋមើលមិនឃើញពីភាពលេចធ្លោរបស់ API ក្នុងកំឡុងពេលធ្វើសកម្មភាព ហើយទី ២ វាបង្ហាញថាសកម្មភាពរបស់គម្រោងភាគច្រើនត្រូវបានគេផ្តោតលើនិងយកចិត្តទុកដាក់ថ្នាក់ឃុំសង្កាត់ (LAs) និងនៅ CBOs ។ ការវាយតំលៃទាំងពីនេះផ្តោតកម្រិតភូមិ (ប្រជាពលរដ្ឋ) និងថ្នាក់ឃុំ (LAs និង CBOs) ។ ប្រសិនបើ API ចង់ពង្រីកឬពង្រីកសកម្មភាពពួកគេអាចពិចារណាលើការកំណត់គោលដៅកម្រិតភូមិ។

## ផែនការៈ

- API នឹងកែលម្អសកម្មភាពគម្រោងនាពេលអនាគតដើម្បីចូលរួមជាមួយម្ចាស់កម្មសិទ្ធិជនជាតិដើមភាគតិច ដូចជាយុវជន មនុស្សចាស់និងស្ត្រីងាយរងគ្រោះ។ ខណៈពេល

ដែលគម្រោងនេះជះឥទ្ធិពលដល់ក្រុមជនជាតិភាគតិច គោលដៅរបស់គម្រោងនឹងត្រូវបានរៀបចំឡើងជាពិសេសដើម្បីចូលរួមដោយផ្ទាល់ជាមួយអ្នកពាក់ព័ន្ធទាំងនេះដើម្បីទទួលបានផលប៉ះពាល់កាន់តែស៊ីជម្រៅលើគណនេយ្យភាពសង្គម។

- ដើម្បីធានានិរន្តរភាពនៃសកម្មភាពគម្រោងនាពេលអនាគតជាមួយ CBOs, API នឹងរួមបញ្ចូលនៅក្នុងសកម្មភាពគម្រោងនាពេលអនាគត ក្នុងជំនួយអភិវឌ្ឍន៍របស់អង្គការសម្រាប់ CBOs ។ ជំនួយបែបនេះអាចរួមបញ្ចូលទាំងការបង្កើតយុទ្ធសាស្រ្តផ្តល់មូលនិធិការធ្វើកំណែទម្រង់រចនាសម្ព័ន្ធរចនាសម្ព័ន្ធរបស់ខ្លួនជាផ្លូវការ និងធ្វើការជាមួយ CBOs ផ្សេងទៀតដើម្បីស្វែងរកនិងកេងចំណេញលើការរួមបញ្ចូលគ្នា។

- ការយល់ដឹងអំពីព័ត៌មានហិរញ្ញវត្ថុនិងកញ្ចប់ថវិកាឃុំសង្កាត់នៅតែមានកម្រិតទាបក្នុងចំណោមប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដោយមានប្រជាពលរដ្ឋជាច្រើនជឿជាក់ថាព័ត៌មានថវិកាមិនពាក់ព័ន្ធនឹងពួកគេ ហើយវាជាទំនួលខុសត្រូវ របស់របស់អាជ្ញាធរ។ លើសពីនេះទៀតអាចមានពលរដ្ឋដែលមិនចេះអក្សរ មិនអាចអានឬយល់ពីការបិទផ្សាយព័ត៌មានស្តីពីហិរញ្ញវត្ថុ ដូច្នេះហើយទើពួកគេមិនគិតថាវាសំខាន់សម្រាប់ខ្លួនរបស់ពួកគេទេ។ គោលដៅនៅថ្ងៃអនាគត API ចាំបាច់ត្រូវផ្តោតលើផ្នែកថវិកា (បង្កើនចំណេះដឹងការយល់ដឹងនិងតម្រូវការសម្រាប់ប្រជាជនក្នុងតំបន់និង CBOs) ដើម្បីធានាថាអាជ្ញាធរ មានគណនេយ្យភាពថវិកា។
- នៅពេលបរិបទនយោបាយបង្ខំ API ឱ្យប្តូរសកម្មភាពឆ្ងាយពីផ្នែកផ្គត់ផ្គង់គណនេយ្យភាពសង្គម គម្រោងនឹងទទួលបានអត្ថប្រយោជន៍ពីវិធីសាស្រ្តដែលមានតុល្យភាពរវាងការគាំទ្រទាំងផ្នែកផ្គត់ផ្គង់និងតម្រូវការ។ ការបង្រួបបង្រួមភាគីទាំងពីរនឹងបើកឲ្យមានការទំនាក់ទំនង បង្កើតការជឿទុកចិត្តនិងកិច្ចសហប្រតិបត្តិការនិងកែលម្អគណនេយ្យភាពសង្គមនិងប្រកបដោយនិរន្តរភាព។
- ការប្រើប្រាស់បណ្តាញសង្គម ព័ត៌មាន ទំនាក់ទនងនិងបច្ចេកវិទ្យា (ICT)នឹងរួមបញ្ចូលទៅក្នុងសកម្មភាពគម្រោង។ មានកម្មវិធីជាច្រើនដែល APIមាននិងដែល API អាចប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាដូចជាយន្តការបណ្តឹងតវ៉ា វេទិកាផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ភូមិរួមជាមួយការជូនដំណឹងតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សេចក្តីប្រកាសថ្មីពីអាជ្ញាធរមូលដ្ឋាន។

- API នឹងពិចារណាក្នុងការមានបុគ្គលិកនៅតាមបណ្តាខេត្ត រាល់គម្រោងរបស់API ពីមុន បុគ្គលិកភាគច្រើនរបស់API មានតែនៅភ្នំពេញ។ ខណៈពេលដែលត្រូវបានជួយដោយអ្នកស្ម័គ្រចិត្តនៅតាមបណ្តាខេត្ត។ ពេលនេះសាខាកណ្តាលនេះបានធ្វើការសម្រាប់គម្រោង (ទាក់ទងនឹងការសម្រេចគោលដៅ) ប្រហែលជាអត្ថប្រយោជន៍នៃការមានបុគ្គលិកនៅតាមខេត្តអាចត្រូវបានរកធ្វើឡើងនៅថ្ងៃខាងមុខ ដើម្បីកសាងទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយអ្នកទទួលផល។
- នឹងកំណត់សូចនាករគម្រោងច្បាស់លាស់បន្ថែមទៀតជមួយនិងការកំណត់យ៉ាងច្បាស់ទៅលើគោលដៅច្បាស់លាស់ពីរបៀបគណនានិងវាស់គម្រោង។ នេះនឹងជួយឱ្យមានការវិភាគនិងការប្រៀបធៀបកាន់តែស៊ីជម្រៅរវាងទិន្នន័យវាយតម្លៃ (ផ្តើម ពាក់កណ្តាល និងចុងបញ្ចប់) ពេញពេញមួយគម្រោងនាពេលអនាគត។

## លទ្ធផលគម្រោងទី ៦៖ ការលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យមូលដ្ឋាននៅ កម្ពុជា ២០១៨ - ២០២០

***គោលបំណង:*** ការដាក់ពន្ធដោយពលរដ្ឋដើម្បីពង្រឹងអាភិបាលកិច្ច និង គណនេយ្យភាពសង្គម ជាគោលបំណងរួមគឺដើម្បី ពង្រឹងការចូលររួមប្រជាពលរដ្ឋ និងគណនេយ្យភាពសង្គមដើម្បីលទ្ធផលអភិបាលកិច្ចនៅក្នុងស្រុកចំនួន២ ដែលមានបួនឃុំ នៅក្នុងប្រទេសកម្ពុជា ដែលគាំទ្រ មូលនិធិដោយមូលនិធិអង្គការសហាប្រជាជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ (UNDEF) ដែលមានទឹកប្រាក់សរុប ១៦៥,០០០ ដុល្លារអាមេរិច។

**ដៃគូរអនុវត្តៈ** អង្គការទ្រទ្រង់ស្ត្រីខ្មែរខេត្តកំពង់ធំ (COWS) អង្គការទ្រទ្រង់ភូមិ) VSG( និ អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ )CPDD( ជាសម្ព័ន្ធសមាជិក។

### លទ្ធផល

- មុននិង ប្រជាពលរដ្ឋអាចតាមដានពីការផ្តល់សេវា។ ជាដំបូង ពួកគាត់ត្រូវមានចំនេះដឹងពីការបែងចែកថវិកា។ ដូចនេះហើយ គម្រោងនេះបានបង្កើនសមត្ថភាពប្រជាពលរដ្ឋក្នុងការតាមដាន និងមានឥទ្ធិពលទៅលើអជ្ញារធរក្នុងផ្តល់សេវា ធ្វើផែនការអភិវឌ្ឍ និងផែនការថវិកា។ មានប្រជាជនសរុប៣៣៥៤ (២៣១២ជាស្ត្រី ) ដែលបានទទួលកូនសៀវភៅដែលជួយពន្យល់ និងអាចអោយពួកគាត់យល់ពីដំនើរការដាក់ពន្ធ និងពីសារៈសខាន់ពីតួនាទី និងកាតព្វកិច្ចពលរដ្ឋ និង អជ្ញាធរ។ ការងារនេះបានធ្វើ តាមរយៈការគាំទ្រមូលនិធិខ្នាតតូចដល់អង្គការសហាគមន៍ចំនួន ៣៥ តាមរយៈសកម្មភាពចុះផ្សព្វផ្សាយព័ត៌មានតាមផ្ទះ និងចែកកូនសៀវភៅស្តី ថវិការ (កម្រិតឃុំ និងស្រុក)។ កូនសៀវភៅទាំងនេះផលិតដោយ វិទ្យាស្ថានតស៊ូមិតិ និងគោលនយោបាយ (API) អង្គការតម្លាភាពកម្ពុជា(TI) និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍនតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។

- អង្គការសហាគមន៍ត្រូវមានផែនការច្បាស់លាស់ បន្ទាប់ពីបានទទួលវគ្គបណ្តុះបណ្តាល ដើម្បីអោយពួកគាត់អាចតាមដាន និងមានឥទ្ធិពលទៅលើការផ្តល់សេវាក្នុងការរៀបចំផែនការអភិវឌ្ឍ និងថវិការប្រកបដោយប្រសិទ្ធភាព។ បន្ទាប់ពីអង្គការសហាគមន៍បានផែនការច្បាស់លាស់ពួកគាត់ ពួកគេនិងទទួលបានមូលនិធិគាំទ្រខ្នាតតូច។ អង្គការសហាគមន៍ត្រូវបានតាមដាន និងផ្តល់បច្ចេកទេសដោយបុគ្គលិកគម្រោងចំនួន១៦ដង ដល់អង្គការសហាគមន៍ចំនួន

៩៥ ដែលមានក្រុមយុវជន និងស្ត្រី និងមានការប្រជុំតស៊ូមតិចំនួន៩ដង រវាងតំណាងអង្គការសហគមន៍ និងអជ្ញាធរជាពិសេសក្រុមប្រឹក្សាស្ត្រីថ្នាក់ឃុំ និងស្រុក។ មានការប្រជុំ១៦ផ្សេងទៀត ដែលមានតំណាងអជ្ញាធរ និង តំណាងក្រុមយុវជន និងស្ត្រី ដែលមានអ្នកចូលរួមចំនួន ៦៣ នាក់។

- មានមនុស្សសំខាន់ៗ ចំនួន៣៨នាក់ ដែលមានអជ្ញាធរ តំណាងក្រុមយុវជន និងស្ត្រី មណ្ឌលសុខភាព នគរបាល សាលាបឋមសិក្សា និងមន្ត្រីរដ្ឋបាលឃុំ និងស្រុកដែលបាន ទទួលចំនេះដឹង និងបទពិសោធន៍ក្នុងការអនុវត្តការដាក់ពន្ទុដោយប្រជាពលរដ្ឋ អនុវត្តគម្រោងខ្នាត់តូច និងផែនការសកម្មភាពក្នុងអភិវឌ្ឍ និងអនុវត្តតាមរយៈការចុះទស្សនៈ កិច្ចសិក្សារយៈពេល៣ថ្ងៃ និងការរំលឹកមេរៀនរយៈពេល២ថ្ងៃ។ ពួកគេអានមានលទ្ធភាពក្នុងការអនុវត្តប័ណ្ណដាក់ ពិន្ទុលើកទីមួយ និងទី២នៅឃុំចំនួន៤ មាន១០ភូមិ ដែលមានអ្នកឆ្លើយចំនួន ៦១១ (ស្ត្រី៣៩២)។ លទ្ធផលដែលបានរកឃើញពីការដាក់ពន្ទុ និង អនុសាសាន៍បានប្រើជាសកម្មភាពអនុវត្តដើម្បីកែលំអ មណ្ឌលសុខភាព ប៉ុស្តិ៍នគរបាល សាលាបឋមសិក្សា និងរដ្ឋបាលឃុំ និងស្រុក។
- គម្រោងក៏បានគាំទ្រដល់អង្គការសហគមន៍ និងអជ្ញាធរមូលដ្ឋានអនុវត្តគម្រោងខ្នាតតូច ចំនួន ១៦ ដែលអនុវត្តតាមការរកឃើញ និងអនុសាសន៍ពីការប័ណ្ណដាក់ពន្ទុដែលចំណាយទឹកប្រាក់ ១000 ដុល្លារអាមេរិច។ ៥0% នៃមូលនិធិ ជាបដិភាគពីអង្គការសហគមន៍ និងអជ្ញាធរមូលដ្ឋាន និង៥0% ជាមូលនិធិគម្រោង។ គម្រោងខ្នាតតូច១៦ ដែលអនុវត្តដោយឃុំចំនួន២0 និង ក្រុមប្រឹក្សាដែលមានក្រុមប្រឹក្សាជាស្ត្រី ចំនួន៦ និងតំណាងយុវជនចំនួន ៥៥នាក់។ គម្រោងខ្នាតតូចចំនួន ៨ នៅក្នុងខេត្តកំពង់ធំទទួលបានការគាំទ្រពី UNDEF ចំនួន៤000 ដុល្លារអាមេរិច (ឃុំនីមួយៗ៥00 ដុល្លារអាមេរិច) ដោយមានការចូលរួមពីវិស័យឯកជន និង អជ្ញាធរមូលដ្ឋាន អង្គការក្នុងតំបន់ និងអង្គការសហគមន៍ដែលជួយបដិភាគចំនួន ៣000 ដុល្លារ សម្រាប់គម្រោងចំនួន៨ និងផែនការសកម្មភាពតាមរយៈសិក្ខាសិលាថ្នាក់ស្រុកចំនួន២ថ្ងៃ ដែលមានភាគីពាក់ពន្ធចូលរួមចំនួន ៩៦។ គម្រោងខ្នាតតូចទាំង១៦គឺ ផ្តោលទៅលើសេវាសារធារណៈ គម្រោងក៏បានចូលរួមជំរុញអោយមានអ្នកចូលរួមប្រហែល៨0នាក់(ស្ត្រី៣៣នាក់) ដែលជាអ្នកទទួលផលផ្ទាល់មានឧកាសឆ្លុះបញ្ចាំងពីការអនុវត្តនិងការរៀនសូត្រពីគម្រោងដែលកែលំអវា។
- ជាសរុបគម្រោងបានទទួលលទ្ធផលដូចជាៈ **លទ្ធផលទី១** សមត្ថភាពប្រជាពលរដ្ឋក្នុងការតាមដាន និងឥទ្ធិពលលើការផ្តល់សេវារបស់អជ្ញាធរ ក្នុងការធ្វើផែនការអភិវឌ្ឍ និង ផែនការថវិការត្រូវបានបង្កើន។ អ្នកទទួលបានវគ្គបណ្តុះបណ្តាល ដែលបានអនុវត្តប័ណ្ណដាក់ពន្ទុលើទី១និងទី២ ៩១.៥% (៤៣ក្នុងចំណោម៤៧ដែលបានទទួលវគ្គបណ្តុះបណ្តាល) អាចកត់យកពី តម្រូវការរបស់ប្រជាជនយ៉ាងច្បាស់លាស់ និងអនុសាសាន៍ទាក់ទងនិងការផ្តល់សេវាសាធារណៈ ហើយ

លទ្ធផលក៏ត្រូវបានបែងចែកទៅតាម អាយុ និងភេទ [យុវជន]។ តាមលទ្ធផលនៃការស្ទាប់ស្ទង់មតិចំនួន ៦១០នាក់ ដែលបានចូលរួមជាមួយសកម្មភាពផ្សព្វផ្សាយពីគម្រោង ៨៧.៤% នៃអ្នកចូលរួមទាំងអស់បាននិយាយថាពួកគេមានការកើនឡើងចំណេះដឹងពីដំណើរការដាក់ពន្ធ និងសារៈប្រយោជន៍របស់វា។ ពួកគេគេបានយល់ដឹងកាន់តែច្បាស់ពី តួនាទី និងកាតព្វកិច្ចប្រជាពលរដ្ឋ និងអជ្ញាធរមូលដ្ឋាន និងសៀវភៅស្តីពី ដំណើរការវិមជ្ឈការ និងសហវិមជ្ឈការ និងយន្តការក្នុងផ្តល់សេវា។

- **លទ្ធផលទី២៖** ពង្រឹងសម្ថភាពអជ្ញាធរមូលដ្ឋានក្នុងការកំណត់តម្រូវការរបស់ប្រជា ពលរដ្ឋ។ មានអជ្ញាធរមូលដ្ឋានដែលទទួលបានការបណ្តុះបណ្តាលពីការដាក់ពន្ធចំនួន ៩៥% [៤៨ក្នុងចំណោម៤៨] បានបង្ហាញថាមានការកែប្រែអកប្បកិរិយាក្នុងការផ្តល់សេវា។ មានអ្នកចូលរួម ៩៥% ដែលជាស្ត្រីក្រុមប្រឹក្សាឃុំ និងស្រុកបានជួយយ៉ាងសកម្មកក្នុងផែនការដាក់ពន្ធ និងចូលរួមចំណែងយ៉ាងច្រើនក្នុងការផ្លាស់ប្តូរក្នុងការផ្តល់សេវាក្នុងតំបន់របស់ពួកគេ។
- **លទ្ធផលទី៣៖** បង្កើនភាពជាដៃគូររវាងរដ្ឋភិបាល និង អង្គការសង្គមស៊ីវិលក្នុងឆ្លើយតបតម្រូវ និងក្តីកង្វល់សាធារណៈ តាមរយៈការអនុវត្តគម្រោងខ្នាតតូចចំនួន១៦ ដែលមានគម្រោងសំខាន់ ៨ ក្នុងឆ្នាំ២០១៩។ ផែនការសកម្មភាពនៅក្នុងឃុំចំនួន៤ ត្រូវបានរៀបចំឡើង និងអនុវត្តយ៉ាងជោគជ័យ ដែលមានអ្នកទទួលផលចំនួណ៣៤,៣៩៣នាក់ក្នុងតំបន់ឃុំគោលដៅ។

បញ្ហាប្រឈម

- អាជ្ញាធរមានការរវល់ការងារច្រើនទាំងការងារស្នូល ទាំងការងារជាមួយអង្គការ ដែលសកម្មគម្រោងខ្លះត្រូវការមានសហការយ៉ាងជិតស្និទ្ធ ជាមួយអជ្ញាធរក្នុងការអនុវត្តគម្រោងត្រូវពន្យាពេល។
- សកម្មភាពគម្រោងមួយចំនួនត្រូវបានពន្យាលពេលក្នុងការអនុវត្តដោយសារអជ្ញាធរស្រុក និងឃុំរវល់ជាមួយយុទ្ធនាការពីខែមេសា ដល់ កក្កដា២០១៩។

*ផែនការ*

- បង្កើនសកម្មភាពផ្សព្វផ្សាយតាមវិទ្យុចំនួន ២០ភូមិនៅឃុំគោលដៅតាំង៤ ក្នុងខែមករាឆ្នាំ ២០២០។
- បញ្ចាប់ឯកសារយល់ដឹង និងបទពិសោធន៍រៀនសូត្រនៅខែមករាឆ្នាំ២០២០
- រៀបចំសន្និសិទ្ធថ្នាក់ជាតិ ពីការរៀនសូត្រពីគម្រោង នៅខែកុម្ភៈ ឆ្នាំ២០២០។

## លទ្ធផលគម្រោងទី៧ ៖ ប្រជាពលរដ្ឋក្នុងក្របខណ្ឌគនេយ្យភាពសង្គម " ២០១៩ដល់២០២០

**គោលបំណងគម្រោង៖** គម្រោងនេះមានគោលបំណងដើម្បីធ្វើឲ្យប្រសើរឡើងនៃការបំពេញតួនាទីរបស់អ្នកផ្តល់សេវានៅក្នុងរាជធានីភ្នំពេញ ដែលផ្តោតសំខាន់ទៅលើការធ្វើឲ្យប្រសើរឡើងនៃតម្លាភាព ការចូលរួមរបស់ប្រជាជន ជាពិសេសយុវជន និង ក្រុមដែលបានងាយរងគ្រោះគ្រប់ប្រភេទទាំងអស់ និងសកម្មភាពទទួលខុសត្រូវដោយមានគុណភាពនៃសាវាអប់រំ សុខភាព រដ្ឋបាលសាធារណៈ របស់សង្កាត់ និងច្រកចេញចូលតែមួយ (OWSO) នៅក្នុងខ័ណ្ឌសែនសុខ រាធានីភ្នំពេញ ២០១៩ ដែលមានថវិកាសរុបចំនួន ៥៣,៨៣៨ ដុល្លាអាមេរិច ក្រោមជំនួយរបស់អង្គការអុកស្វាមកម្ពុជា (Oxfam Cambodia)។ ដូចច្នេះគម្រោងនឹងត្រូវបន្តសកម្មភាពទៀតនៅឆ្នាំ២០២០។

**លទ្ធផលគម្រោង៖** គម្រោង **សម្លេងប្រជាពលរដ្ឋក្នុងគណីភាពសង្គម** នឹងត្រូវបន្តដើម្បីធ្វើឲ្យមាន ការប្រសើរឡើងនៃសេវាសាធារណៈក្នុងទីក្រុងភ្នំពេញ បន្ទាប់ពីទទួលបានជោគជ័យក្នុងការអនុវត្តគម្រោងនៅតាមខេត្តដាច់ស្រយាលមួយចំនួន។ វាពិតជាមានសារៈសំខាន់ណាស់ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីតួនាទីនៃអ្នកដឹកនាំក្នុងរដ្ឋាភិបាលនៃអ្នកតំណាងមណ្ឌលសុខភាព ការប្រើប្រាស់វិន័យរបស់សាលាបឋមសិក្សា ក្រុមព្រឹក្សាភិបាលខ័ណ្ឌសែនសុខ ការិយាល័យប្រជាពលរដ្ឋ និងខ័ណ្ឌផ្សេងៗទៀតឲ្យបានយល់ច្បាស់និងចូលរួមសហការទាំងអស់គ្នាជាមួយអង្គការ API តាមរយៈការរៀបចំដើម្បីចាប់ផ្តើមអនុវត្តគម្រោង។ អ្នកសហការនៅក្នុងខ័ណ្ឌសែនសុខ និងបុគ្គលិកគម្រោងទាំងអស់ត្រូវតែយល់ដឹងឲ្យច្បាស់អំពីគោលបំណង និង គោលគំនិតរបស់គម្រោង ដែលបានយល់ព្រមតាមលក្ខខណ្ឌសម្រាប់ការចូលរួម ដោយយោងទៅតាមអនុស្សរណៈនៃការយោគយល់ជាមួយខណ្ឌ និងរដ្ឋបាលខណ្ឌដែលបានចុះហត្ថលេខា និងចូលរួមពិភាក្សាធ្វើផែនការសកម្មភាពជាមួយគ្នា។ តាមអនុស្សរណៈនៃការយោគយល់បានបញ្ជាប់យ៉ាងច្បាស់អំពីការសហការ និងភាពជាដៃគូជាមួយអាជ្ញាធរ និងក្រសួងដែលពាក់ព័ន្ធមានដូចជា៖ ក្រសួងអប់រំ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងមហាផ្ទៃ ដែលបានយល់ព្រមក្នុងការជួយគាំទ្រគោលបំណងកម្មវិធី និងសកម្មភាព និងជាដៃគូនៃក្របខ័ណ្ឌគម្រោង។

ដើម្បីអនុវត្តគម្រោងនេះ អង្គការ API ត្រូវចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាពបន្ថែមរបស់មន្ត្រីរដ្ឋាភិបាល (អ្នកផ្តល់សេវា) និងជ្រើសរើស និងបណ្តុះបណ្តាលអ្នកសម្របសម្រួលផ្នែកគណនេយ្យភាពសហគម និងបុគ្គលិក API (អ្នកទទួលសេវា)។ សមត្ថភាពរបស់អ្នកផ្តល់សេវាទាំងអស់ (អ្នកផ្តល់សេវាសាធារណៈ ឬមន្ត្រីរដ្ឋាភិបាល ឬអ្នកកាន់កាតព្វកិច្ច) ២៩អ្នកចូលរួម(ស្ត្រី០៩នាក់) មកពីក្រុមគោលដៅរបស់ខណ្ឌ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព ដែលបានកសាង

សមត្ថភាព និងជំនាញបច្ចេកទេសដែលទាក់ទងទៅនឹងការអនុវត្តក្របខណ្ឌគណិភាពសង្គម (ISAF) តាមរយៈការបណ្តុះបណ្តាលរយៈពេល៣ថ្ងៃ និង២ថ្ងៃរំលឹកឡើងវិញនូវវគ្គបណ្តុះបណ្តាលពីមុន។

បន្ទាប់មកយើងនឹងធ្វើការជ្រើសរើសអ្នកសម្របសម្រួលផ្នែកគណនេយ្យភាពសហគមន៍ (CAFs) ដូចជាក្រុមយុវជនស្ម័គ្រចិត្តតាមរយៈប្រព័ន្ធផ្សព្វផ្សាយ (API Facebook) និងក្រុមហ៊ុនផ្តល់សេវាផ្សេងៗ។ ចំនួនសរុបអ្នកដែលបានដាក់ពាក្យមកមាន៦៣នាក់ និង២៧ជាបេក្ខជនត្រូវបានជ្រើសរើសទុកជាមុន និងយុវជន១៣នាក់ទៀតដែលត្រូវបានជ្រើសរើស(៦នាក់ជាស្ត្រី)យោងទៅតាមលក្ខណៈវិនិច្ឆ័យ និងការទទួលខុសត្រូវផ្សេងៗ។ ពួកគេទាំងអស់នោះនឹងទទួលបានវគ្គបណ្តុះបណ្តាលចំនួន២ ទៅលើចំណេះដឹង និងជំនាញបច្ចេកទេសដែលទាក់ទងទៅនឹងដំណើរការ ISAF (**ម៉ូឌែល១** ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) **ម៉ូឌែល២** ការដាក់ពិន្ទុករបស់ប្រជាពលរដ្ឋ **ម៉ូឌែល៣** កិច្ចប្រជុំពិគ្រោះយោបល់ **ម៉ូឌែល៤** ផែនការចូលរួមក្នុងសកម្មភាពគណនេយ្យភាពសង្គម)

បន្ទាប់ពីភាគីទាំងពីរបានទទួលនូវជំនាញបច្ចេកទេសក្នុងការផ្តល់កញ្ចប់ព័ត៌មានសាមញ្ញ និងងាយស្រួលសម្រាប់ប្រជាពលរដ្ឋ ពួកគេនឹងផ្តល់កញ្ចប់សេវាព័ត៌មានចំនួនបួនច្បាប់សម្រាប់ប្រជាពលរដ្ឋ (I4Cs) លើបួនវិស័យរបស់សេវាសាធារណៈនៃ រដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ មណ្ឌលសុខភាព សាលាបឋមសិក្សា និងសេវាផ្សព្វផ្សាយជាសាធារណៈ។ មាតិការបស់(I4Cs)ត្រូវបានដាក់បញ្ចូលទៅក្នុងគណៈកម្មការថ្នាក់ជាតិ សម្រាប់ការអភិវឌ្ឍនបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប័ណ្ណផ្សព្វផ្សាយរបស់(I4Cs) ត្រូវបានប្រើប្រាស់សម្រាប់សេវាផ្សព្វផ្សាយរបស់ភូមិ នៅក្នុង៣សង្កាត់។ គម្រោងបានផលិតកូនសៀវភៅព័ត៌មានអំពីសេវាសាធារណៈចំនួន៤ក្បាល មួយសម្រាប់ខណ្ឌនិងសង្កាត់ ដោយរួមបញ្ចូលជាមួយសេវាទាំងបី ព័ត៌មានដែលបានបង្កើតជាកញ្ចប់សេវា I4Cs លទ្ធផលប័ណ្ណដាក់ពិន្ទុករបស់ប្រជាពលរដ្ឋ ផែនការចូលរួមសកម្មភាពគណនេយ្យភាពសង្គម (JAAP) ព័ត៌មានថវិកា តួនាទីនិងសិទ្ធិរបស់ប្រជាពលរដ្ឋ និងតួនាទីរបស់អ្នកផ្តល់សេវា និងអ្នកបំពេញតួនាទីជាអ្នកផ្តល់សេវាសាធារណៈតាមស្តង់ដាជូនប្រជាពលរដ្ឋ និងការវាយតម្លៃខ្លួនឯងជាដើម។ ទាំងអស់នេះនឹងត្រូវយកមកធ្វើវឌ្ឍនភាពលើការវាយតម្លៃនៃស្ថានភាពនៃការអនុវត្តគម្រោង និងការត្រួតពិនិត្យជាសាធារណៈនៃផែនការJAAP ។

ប័ណ្ណប្រកាស និងកូនសៀវភៅដែលបានបោះពុម្ពផ្សាយលើវិស័យទាំងបួននៃសេវាសាធារណៈរបស់រដ្ឋបាលខណ្ឌ សង្កាត់ និងសាលារៀន សម្រាប់ការលើអំពីការយល់ដឹងជាសាធារណៈ និងសកម្មភាពផ្សព្វផ្សាយ តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយទៅតាមភូមិទាំង១២ ជាមួយនឹងអ្នកចូលរួម៧៨៦នាក់(៣២៩

នាក់ជាស្ត្រី អ្នកក្រីក្រ២៧នាក់ ៥នាក់ជាជនពិការ យុវជន៥២នាក់ ស្ត្រីម៉េមាយ១៩នាក់)។ នេះជាលើកដំបូងសម្រាប់ប្រជាជនក្នុងរាជធានីភ្នំពេញដែលបានយល់ដឹងអំពីការចំណាយថវិកា សាធារណៈ ការបង្រៀនអំពីសិទ្ធិក្នុងការចូលរួមជាមួយកិច្ចការអភិបាលកិច្ចមូលដ្ឋាន និងត្រួតពិនិត្យការផ្តល់សេវាសាធារណៈ។ ឧទាហរណ៍៖ តាមរយៈកិច្ចប្រជុំប័ណ្ណដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ វាគឺជាលើកដំបូងសម្រាប់មន្ត្រីរដ្ឋាភិបាល អ្នកផ្តល់សេវាសាធារណៈដើម្បីធ្វើការវាយតម្លៃដោយខ្លួនឯង ឬការវាយតម្លៃតួនាទីខ្លួនឯង និងការយល់ដឹងអំពីគោលគំនិតរបស់ប្រជាពលរដ្ឋ និងតម្រូវការក្នុងការផ្តល់សេវាឲ្យកាន់ប្រសើរឡើង។

កិច្ចប្រជុំអំពីការវាយតម្លៃដោយខ្លួនឯងទាំង១៥លើកត្រូវបានធ្វើឡើងនៅថ្នាក់សង្កាត់ និងខណ្ឌ មណ្ឌលសុខភាព និងសាលារៀន ដែលមានការចូលរួមពីថ្នាក់ដឹកនាំឬអ្នកតំណាងសេវាសាធារណៈចំនួន៣១២នាក់ (ស្ត្រី១៦១នាក់)។ការវាយ តម្លៃខ្លួនឯងហាក់ដូចជាសកម្មភាពថ្មីមួយសម្រាប់អ្នកផ្តល់សេវានៅក្នុងទីក្រុងភ្នំពេញ។ មានក្រុមប្រឹក្សាមួយចំនួនមាន អារម្មណ៍ថាការវាយតម្លៃខ្លួនឯងគឺអាចនឹងអនុញ្ញាតឱ្យពួកគេវាយតម្លៃការបំពេញតួនាទីរបស់ពួកគាត់ និងធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវា ប៉ុន្តែអ្នកខ្លះបែជាមានអារម្មណ៍ស្ទាក់ស្ទើរក្នុងការចូលរួមឬលើកឡើងពីលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃរបស់ខ្លួនទៅវិញបីទោះជាទាំងអស់នោះជាផលប្រយោជន៍រួមរបស់ខណ្ឌក៏ដោយ។

សម្លេងរបស់អ្នកផ្តល់សេវាសាធារណៈចំនួន៣១២នាក់ ដែលបានចូលរួមក្នុងវាយតម្លៃខ្លួនឯង និងប្រជាពលរដ្ឋចំនួន៤២៣នាក់ (១៩៨នាក់ជាស្ត្រី ប្រជាពលរដ្ឋក្រីក្រ១០នាក់ យុវជន១៨នាក់) ដែលបានចូលរួមកិច្ចប្រជុំប័ណ្ណដាក់ពិន្ទុសហគមន៍ ដែលបានរៀបចំដោយអ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAFs) ។ ឧបករណ៍ទាំងអស់នេះមានប្រសិទ្ធភាពបំផុតក្នុងការឆ្លើយតបទៅរដ្ឋាភិបាលជាមួយនឹងភស្តុតាងយ៉ាងជាក់លាក់ អំពីចំណុចខ្លាំង និងខ្សោយដែលត្រូវធ្វើឲ្យប្រសើជាងមុន។ ប័ណ្ណដាក់ពិន្ទុ និងកិច្ចប្រជុំការវាយតម្លៃខ្លួនឯងក៏ត្រូវបានលើកឡើងក្នុងការបង្កើនការយល់ដឹង អំពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិទទួលសេវាសាធារណៈសំខាន់ៗ និងអំពីថវិកាបម្រុងទុក និងការបំពេញតួនាទីតាមថ្នាក់មូលដ្ឋាន(សាលាបឋមសិក្សា មណ្ឌលសុខភាព សង្កាត់ និងខណ្ឌ)។

គម្រោងបានប្រើប្រាស់លទ្ធផលការដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ និងការវាយតម្លៃខ្លួនឯងរបស់អ្នកផ្តល់សេវា និងការបង្ហាញនៅក្នុងកម្រិតខ្ពស់នៃបួនកិច្ចប្រជុំពិភាគក្សា ដែលមានអ្នកចូលរួមចំនួន១១០នាក់ (៥១នាក់ជាស្ត្រី) ថ្នាក់ដឹកនាំនៃស្ថាប័នរដ្ឋទាំងអស់ និងតំណាងប្រជាជន បានអភិវឌ្ឍ និងយល់ព្រមទៅលើផែនការចូលរួមសកម្មភាពស្តីអំពីក្របខណ្ឌគណនេយ្យភាព (JAAP) និងការបង្កើតគណៈកម្មការ

ផែនការចូលរួមសកម្មភាពស្តីអំពីក្របខណ្ឌគណនេយ្យភាព (JAAP-C) ។ កិច្ចប្រជុំពិភាក្សារវាងអ្នកផ្តល់សេវា និងតំណាងប្រជាពលរដ្ឋ ដែលអ្នកទាំងអស់នោះត្រូវបានជ្រើសរើសដោយគម្រោង។ គោលបំណងដើម្បីអភិវឌ្ឍការយល់ដឹងរួមគ្នា និងចែករំលែកបញ្ហាប្រឈមក្នុងការផ្តល់សេវាមូលដ្ឋាន និងការឆ្លើយតបពីខាងអ្នកផ្តល់សេវា និងអ្នកទទួលសេវា។

នៅក្នុងផែនការ JAAP យើងឃើញមានការអភិវឌ្ឍខ្លះៗជាមួយនឹងការយល់ព្រមក្នុងការអភិវឌ្ឍជាមួយអ្នកផ្តល់សេវា និងអ្នកទទួលសេវា ដូច្នេះយ៉ាងតិចបំផុត៥០ភាគរយនៃផែនការសកម្មភាព JAAP ដែលបាននឹងកំពុងអនុវត្ត ដូចជាកិច្ចប្រជុំជាមួយ មន្ត្រី និងគ្រូបង្រៀនដើម្បីពង្រឹងតួនាទី និងក្រមសីលធម៌នៃការផ្តល់សេវានៅក្នុងចុងឆ្នាំ២០១៩ ដូចដែលបានយល់ព្រមនៅក្នុងគម្រោងកិច្ចប្រជុំឆ្លុះបញ្ចាំងជាមួយនឹងដៃគូសហការ៤៩នាក់(៧នាក់ជាស្ត្រី) ដែលពួកគាត់ជា CAFs មន្ត្រីខណ្ឌ មន្ត្រី សង្កាត់ ហើយនឹងអ្នកតំណាងមកពីសាលារៀន និងមណ្ឌលសុខភាព។ អ្នកចូលរួមក៏បានធ្វើការឆ្លុះបញ្ចាំងអំពីបទពិសោធន៍ និងបញ្ហាប្រឈមរបស់ពួកគេផងដែរ។ សិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនហើយបានអនុញ្ញាតឱ្យ CAFsនិងអ្នកផ្តល់សេវាអាចចែករំលែកពីបទពិសោធន៍រៀនសូត្រទាក់ទងនឹងដំណើរការ ISAF ទាំងមូល ។ ប៉ុន្តែអ្នកចូលរួមភាគច្រើនហាក់ដូចជាមិនមានគំនិតផុសផុលអំពីវិធីកែលម្អក្នុងការអនុវត្តគម្រោងក្របខណ្ឌគណនេយ្យភាពសង្គមនៅឡើយ។ បន្ទាប់មកមានកិច្ចប្រជុំពិគ្រោះយោបល់គ្នាបន្ថែមមួយទៀតត្រូវបានរៀបចំឡើងម្តងទៀតដោយមានអ្នកចូលរួមចំនួន ១៧ នាក់ (ស្រី ៧ នាក់) ដើម្បីពិភាក្សាអំពីវិធីសាស្ត្រស្តីពីវិធីលើកកម្ពស់ក្នុងការចូលរួមរបស់ស្ត្រី និងក្រុមដែលងាយរងគ្រោះនៅក្នុងសកម្មភាពរបស់ ISAF ។ កិច្ចប្រជុំនេះបានស្នើឡើងដើម្បីនឹងជួយឱ្យមានកិច្ចសហប្រតិបត្តិការល្អ និងជិតស្និទ្ធជាមួយបុគ្គលិកបង្គោលរបស់ ISAF ក្នុងសង្កាត់ និងខណ្ឌ។ នៅក្នុងកិច្ចប្រជុំនេះក៏បានជូនដំណឹងដល់ជនបង្គោលរបស់ ISAF ប្រចាំសង្កាត់ និងខណ្ឌឱ្យយកចិត្តទុកដាក់បន្ថែមទៀតដល់ក្រុមដែលងាយរងគ្រោះដើម្បីលើកកម្ពស់ដល់ការចូលរួមក្នុងសកម្មភាព ISAF ។ បុគ្គលិកបង្គោលរបស់ ISAF ត្រូវការកែលំអការសហការរបស់ពួកគេជាមួយមេភូមិដើម្បីកំណត់អត្តសញ្ញាណ និងឲ្យបានទៅដល់អ្នកដែលងាយរងគ្រោះដើម្បីឱ្យពួកគេបានចូលរួមការក្នុងកិច្ចប្រជុំអភិវឌ្ឍនថ្នាក់មូលដ្ឋាន។

ការសន្និដ្ឋានថាអំពីការស្ទង់មតិនេះទទួលបានភាពជោគជ័យក្នុងការសាកល្បង ISAF នៅក្នុងរាជធានីភ្នំពេញ។ លទ្ធផលដែលទទួលបាន / **គោលបំណងជាក់លាក់ទី ១៖** ការពង្រឹងសមត្ថភាព និងសកម្មភាពជាលទ្ធផលរបស់តំណាងពលរដ្ឋ និងអ្នកផ្តល់សេវាក្នុងក្របខណ្ឌ ISAF នៅតំបន់ទីក្រុង។ គម្រោងនេះ

បានធ្វើឱ្យប្រសើរឡើងនូវតម្លាភាពរបស់អ្នកផ្តល់សេវាសាធារណៈ និងកែលម្អការអប់រំប្រកបដោយគុណភាពរបស់សាលាបឋមសិក្សា សេវាសុខភាពរបស់មណ្ឌលសុខភាពចំនួន៣ សេវារបស់រដ្ឋបាលសង្កាត់ចំនួន៣ និងការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌសែនសុខ និងសេវាកម្មអាទិភាពផ្សេងៗនៅក្នុងខណ្ឌសែនសុខផងដែរ។ នៅក្នុងគម្រោងដែលបានចូលរួមជាមួយមន្ត្រីអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាជាង ៣០០ នាក់សម្រាប់ការវាយតម្លៃខ្លួនឯង និងធ្វើអន្តរកម្មជាមួយប្រជាជនដើម្បីធ្វើឱ្យប្រសើរឡើងសម្រាប់វិស័យនីមួយៗ។ អ្នកផ្តល់សេវាបានបង្កើនចំណេះដឹង និងការយល់ដឹងអំពីការអនុវត្តសកម្មភាពក្នុងក្របខណ្ឌគណនេយ្យភាពសង្គម។

វគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ CAFs សហគមនយុវជនចំនួន ១៣ នាក់ ស្រី ៦ នាក់បានសម្រេចជោគជ័យក្នុងការសម្របសម្រួលសកម្មភាពរបស់ ISAF ដូចជាការផ្សព្វផ្សាយព័ត៌មានសម្រាប់ប្រជាពលរដ្ឋក្នុងការប្រជុំដាក់ពិន្ទុសហគមន៍។ CAFs គឺភាគច្រើនជាយុវជនដែលចាប់អារម្មណ៍ទៅនឹងការងារសហគមន៍។ CAFs បានទទួលចំណេះដឹងអំពីអភិបាលកិច្ចល្អក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន និងព័ត៌មានថវិកា។ គម្រោងបានធ្វើឱ្យប្រសើរឡើងនូវជំនាញរបស់ពួកគេដូចជាជំនាញសម្របសម្រួល ភាពជាអ្នកដឹកនាំ ឬជំនាញទំនាក់ទំនង។យ៉ាងហោចណាស់មានពលរដ្ឋចំនួន ៨០០ នាក់ ក្នុងនោះមានស្ត្រី ៥២% ដែលដឹងច្បាស់អំពីស្តង់ដារនៃការផ្តល់សេវា និងថវិកាចូលរួមដោយផ្ទាល់នៅក្នុងការប្រជុំផ្សព្វផ្សាយព័ត៌មានក្នុងការប្រជុំដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ និងកិច្ចប្រជុំពិភាក្សា ។ តំណាងពលរដ្ឋជាង ៤០០ នាក់ (៦៥ ភាគរយ) បានផ្តល់កន្លែង និងឆ្លៀតឱកាសដើម្បីវាយតម្លៃពីលទ្ធផលនៃការផ្តល់សេវាសាធារណៈ និងបានទទួលបានការចូលរួមពីសំណាក់ពលរដ្ឋផងដែរ។

**គោលបំណងទី ២៖** ការរាប់បញ្ចូលក្នុងសង្គមនៃក្រុមអ្នកដែលងាយរងគ្រោះត្រូវបានធ្វើឱ្យប្រសើរឡើងនៅក្នុងគោលនយោបាយ និងការអនុវត្តជំហានទី ២ របស់ ISAF ដោយផ្អែកលើការតស៊ូមតិរួមគ្នាជាមួយក្រុមគោលដៅ។

នៅក្នុងគោលនយោបាយដំណាក់កាលទី ២ របស់ ISAF ត្រូវបានរួមបញ្ចូលយ៉ាងច្បាស់នូវការដាក់បញ្ចូលក្រុមអ្នកដែលងាយរងគ្រោះចូលទៅក្នុងសង្គម ។ ប៉ុន្តែការអនុវត្តហត្ថកម្មនៅក្នុងគម្រោងថ្មីនៃដំណាក់កាលទី២របស់ISAFក្នុងឆ្នាំ២០១៩គឺជាឆ្នាំទី១ហើយ និងជាឆ្នាំដំបូងសម្រាប់ការអនុវត្តគម្រោងនៅក្នុងរាជធានីភ្នំពេញ។ ការដាក់បញ្ចូលក្រុមអ្នកដែលងាយរងគ្រោះនៅក្នុងដំណើរការនេះគឺជាបញ្ហាប្រឈមមួយពីព្រោះការរចនា និងការអនុវត្តគម្រោងត្រូវបានកំណត់ឡើងដើម្បីអនុវត្តទៅតាមដំណើរការនិងប្រតិទិនស្តង់ដាររបស់ ISAF តែប៉ុណ្ណោះ។ទោះយ៉ាងណាក៏ដោយវាត្រូវបានចាប់ផ្តើមនៅពី

ក្រោយកាលវិភាគសកម្មភាពគម្រោងដែលមិនបានរាប់បញ្ចូលការធ្វើផែនទីដើម្បីកំណត់អត្តសញ្ញាណក្រុមអ្នកងាយរងគ្រោះនោះឡើយ។ ខណ្ឌសែនសុខគឺជាតំបន់សាកល្បងថ្មីសម្រាប់APIនិងOxfam។ ការកសាងទំនុកចិត្ត និងទំនាក់ទំនងរវាង API និងអាជ្ញាធរមូលដ្ឋានគឺជាសកម្មភាពអាទិភាពមួយក្នុងចំណោមសកម្មភាពអាទិភាពចំបង ។ ក្រុមការងារគម្រោងបានព្យាយាមកំណត់និងកៀងគរក្រុមអ្នកដែលងាយរងគ្រោះដើម្បីឲ្យពួកគាត់បានចូលរួមក្នុងសកម្មភាពនេះផងដែរ ប៉ុន្តែវាមិនងាយក្នុងការកំណត់អត្តសញ្ញាណរបស់ពួកគាត់បានច្រើនឡើយ។ ប្រជាពលរដ្ឋទូទៅបានចូលរួម និងមានការចាប់អារម្មណ៍ទៅលើព័ត៌មានដែលស្តីអំពីការអនុវត្ត និងការផ្តល់សេវាជាស្តង់ដារ ។ ខណៈពេលដែលប្រជាពលរដ្ឋភាគច្រើនបានលើកឡើងថាពួកគាត់ពិតជារីករាយក្នុងការទទួលបានព័ត៌មាននៅថ្នាក់ភូមិ ប៉ុន្តែពួកគាត់កម្រនឹងបានទទួលព័ត៌មានអំពីសេវាកម្មរបស់សង្កាត់ និងខណ្ឌទៅវិញ។ ពលរដ្ឋខ្លះប្រហែលជាមានច្រើនគិតថាថវិកាសង្កាត់ និងខណ្ឌគឺជាព័ត៌មានសម្ងាត់ហើយពួកគាត់សង្កេតឃើញថាការផ្សព្វផ្សាយព័ត៌មានថវិការបស់សង្កាត់និងខណ្ឌគឺនៅមានកម្រិតនៅឡើយ។ ស្មៀនសង្កាត់បានចូលរួមក្នុងការផ្សព្វផ្សាយ និងពន្យល់អំពីថវិការបស់សង្កាត់ និងខណ្ឌគឺនៅមានភាពពិបាកយល់ដោយពួកគាត់ប្រើប្រាស់ពាក្យបច្ចេកទេសដែលធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនមានការនឹងពិបាកយល់។

កិច្ចប្រជុំដាក់ពិន្ទុសហគមន៍ក៏បានអនុញ្ញាតឱ្យតំណាងពលរដ្ឋជាង ៤០០ នាក់ក្នុងការបញ្ចេញមតិវាយតម្លៃក្នុងការផ្តល់សេវាសាធារណៈសំខាន់ៗ និងកំណត់បញ្ហាអាទិភាព និងស្នើជាដំណោះស្រាយផងដែរ។ ពួកគេបានទទួលស្គាល់ថាវាជាមធ្យោបាយដ៏ល្អមួយក្នុងការផ្តល់យោបល់ទៅដល់អ្នកផ្គត់ផ្គង់សេវាជាពិសេស សាលាបឋមសិក្សាដែលធ្លាប់ទាមទារការបង់ថ្លៃសាលាដែលជាមធ្យោបាយក្រៅផ្លូវការក្នុងកំឡុងពេលបង្រៀន។ មតិកែលម្អរបានរួមចំណែកទៅដល់សកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងផ្តល់តម្លាភាពនៅក្នុងសហគមន៍មូលដ្ឋាន។ ពេលខ្លះទោះបីជាពលរដ្ឋដែលរស់នៅទីក្រុងចង់ផ្តល់យោបល់ត្រឡប់ទៅខាងផ្នែកផ្គត់ផ្គង់សេវាវិញ ប៉ុន្តែពលរដ្ឋហាក់ដូចជាមិនសូវដឹងអំពីរបៀបឬវិធីក្នុងការផ្តល់យោបល់ ត្រឡប់ទៅខាងអ្នកផ្តល់សេវានៅឡើយ។ ឥឡូវនេះមន្ត្រីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាទាំងអស់ត្រូវបានជូនជាដំណឹងអំពីអាទិភាព និងទស្សនៈរបស់ប្រជាពលរដ្ឋដែលទាក់ទងទៅនឹងអភិបាលកិច្ច និងសេវាកម្មសាធារណៈ។ មន្ត្រីរដ្ឋាភិបាលថ្នាក់ក្រោមជាតិជាអ្នកផ្តល់សេវានិងចែករំលែកការយល់ដឹងរួមគ្នាអំពីសកម្មភាពអាទិភាពទៅប្រជាពលរដ្ឋ ដែលត្រូវការការកែលម្អតាមថ្នាក់មូលដ្ឋានផ្តល់សេវាដែលយោងទៅលើផែនការសកម្មភាព JAAP ។ សកម្មភាពអាទិភាពដែលបានព្រមព្រៀងជារួមដើម្បីលើកកម្ពស់គុណភាពសេវាសាធារណៈត្រូវបានអនុវត្ត។ រហូតមកដល់

បច្ចុប្បន្ននេះ ៥០% នៃសកម្មភាព JAAP ត្រូវបានអនុវត្ត។ អាជ្ញាធរមូលដ្ឋានបានទទួលស្គាល់ថាមានការកើនឡើងជាលំដាប់ប្រហែល ១០% នៃអ្នកប្រើប្រាស់សេវាដែលចង់ចូលប្រើប្រាស់សេវាសាធារណៈ។

**មេរៀនដែលបានរៀនសូត្រ៖**

- នៅថ្នាក់ខណ្ឌនិងសង្កាត់មានធនធានជាច្រើន ដែលទាំងអស់នោះមានភាពខុសគ្នារវាងតំបន់ជនបទនិងទីក្រុង។ ដូច្នេះការអនុវត្ត ISAF នៅតាមទីប្រជុំជនគឺមានភាពខុសគ្នាពី ISAF នៅតាមជនបទដែលអ្នកផ្តល់សេវានីមួយៗត្រូវទទួលខុសត្រូវចំពោះការដាក់បញ្ចូលទិន្នន័យ ហើយមិនមែនជាជនបង្គោលរបស់ ISAF នៅថ្នាក់ខណ្ឌ / ស្រុក នោះទេ។
- CAFs ដែលនៅទីក្រុងចង់ទទួលបានបទពិសោធន៍ជាជាងទទួលបានការលើកទឹកចិត្តផ្សេងៗ ហើយពួកគាត់ក៏ចង់រៀនបន្ថែមទៀតពីការងារសង្គម។ ទោះយ៉ាងណាក៏ដោយគម្រោងនៅមិនទាន់អាចទៅដល់ក្រុមដែលបាត់បង់ ឱកាសដូចជាអ្នកក្រីក្រ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីធ្វើការស្ម័គ្រចិត្តសម្រាប់ការងារសហគមន៍នៅឡើយទេ។ ទោះបីជានៅក្នុងជំហាននេះយើងមិនទាន់អាចសាកល្បងលើការដឹកនាំរបស់ CAFs ទាំងស្រុងបានមែន ប៉ុន្តែ CAFs មួយចំនួនអាចដឹកនាំសកម្មភាពយ៉ាងសកម្មបាន។
- ជាមួយនឹង ISAF នៅទីក្រុងអ្នកដែលបានចូលរួមក្នុងការផ្សព្វផ្សាយតាមរយៈ IC4s នៃទីប្រជុំជនគឺមានភាពខុសគ្នាពីតំបន់ជនបទដែលស្ត្រីភាគច្រើនបានចូលរួម នៅតំបន់ទីក្រុងក៏មានអ្នកចូលរួមដែលជាបុរសប្រហែលជា ៥០% ។
- មេភូមិគឺជាជនបង្គោលក្នុងការកៀងគរប្រជាពលរដ្ឋ ប៉ុន្តែពេលខ្លះប្រជាពលរដ្ឋគឺមិនបានចាប់អារម្មណ៍រៀនសូត្រអំពីក្របខណ្ឌគណនេយ្យភាពសង្គមនៅឡើយទេ។ សម្រាប់ការអនុវត្តគម្រោងរយៈពេលបន្ទាប់មកទៀតមេភូមិនឹងត្រូវដាក់បញ្ចូលជាចាំបាច់ ទៅក្នុងវគ្គបណ្តុះបណ្តាលរបស់ ISAF ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងការចូលរួមអោយបានកាន់តែច្រើនឡើងក្នុងគម្រោងក្របខណ្ឌគណនេយ្យភាពសង្គម ។
- ការិយាល័យរដ្ឋបាលខណ្ឌ និងការិយាល័យច្រកចេញចូលតែមួយក៏បានផ្សព្វផ្សាយព័ត៌មានទៅដល់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការយល់ដឹងអំពីថវិកាការអនុវត្ត និងការផ្តល់សេវានៅខណ្ឌផងដែរ។ លើសពីនេះទៅទៀត ការិយាល័យប្រជាពលរដ្ឋបានបញ្ជ្រាបយន្តការបណ្តឹងថ្មីមួយសម្រាប់ប្រជាពលរដ្ឋដែលអាចផ្តល់ជាមតិយោបល់អំពីការផ្តល់សេវាជាពិសេសការផ្តល់សេវាការិយាល័យច្រកចេញចូលតែមួយ។

- ប័ណ្ណដាក់ពិន្ទុសហគមនគួរតែអញ្ជើញអ្នកប្រើប្រាស់សេវានីមួយៗឱ្យចូលរួមកិច្ចប្រជុំដើម្បីផ្តល់ជាយោបល់ត្រឡប់ទៅវិញ។ ការធ្វើការប្រមូលពិន្ទុពីផ្ទះមួយទៅផ្ទះមួយអាចនឹងទៅដល់សង្កាត់ទាំងមូលហើយបន្ទាប់មកទិន្នន័យទាំងនោះអាចត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងកិច្ចប្រជុំពិភាក្សាដើម្បីជួយបង្កើនការអនុវត្តផ្នែកផ្តត់ផ្គង់។
- វាជាការប្រសើរណាស់ក្នុងការអនុវត្តICTក្នុងការវាយតម្លៃខ្លួនឯងព្រោះអ្នកផ្គត់ផ្គង់សេវាមួយចំនួនមិនចង់វាយតម្លៃលក្ខណៈវិនិច្ឆ័យរបស់ខ្លួនឡើយ ហើយត្រូវប្រាកដឲ្យបានថាពួកគេអាចផ្តល់នូវមតិរិះគន់ដែលមានប្រយោជន៍ត្រឡប់មកវិញ។
- វាមិនត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងប្រកាសឬបទបញ្ជាណាមួយដើម្បីរួមបញ្ចូលតួនាទីរបស់ប្រធានការិយាល័យប្រជាពលរដ្ឋក្នុងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គមឡើយទេ។
- ការិយាល័យប្រជាពលរដ្ឋគួរដើរតួនាទីយ៉ាងសកម្ម និងអព្យាក្រឹតក្នុងការសម្របសម្រួលការវាយតម្លៃខ្លួនឯងក្នុងតារាងពិន្ទុសហគមន៍ និងកិច្ចការប្រជុំរួមគ្នានៅថ្នាក់ខណ្ឌ។

**បញ្ហាប្រឈម៖**

ភាគច្រើននៃសកម្មភាពត្រូវបានធ្វើឡើងនៅចុងសប្តាហ៍ដោយសារ CAFs មួយចំនួនមមារញឹកនឹងការសិក្សានៅសាកលវិទ្យាល័យ។ ការជ្រើសរើស CAFs (ជាពិសេសអ្នកនៅក្នុងតំបន់ផ្ទាល់និងបរិយាប័ន) មិនត្រូវបានសម្រេចដូចការរំពឹងទុកនោះទេ។ CAFs ដែលត្រូវបានជ្រើសរើសភាគច្រើនជានិស្សិតសាកលវិទ្យាល័យ ហើយពួកគាត់ត្រូវការពេលវេលាបន្ថែមទៀតក្នុងការបង្វឹកហាត់ និងរៀនសូត្រលើផ្នែកយល់ដឹង និងទិដ្ឋភាពរបស់រដ្ឋាភិបាល។ ដូច្នេះមន្ត្រីរដ្ឋាភិបាលគួរតែដើរតួយ៉ាងសកម្មក្នុងការអប់រំអ្នកចូលរួម (ពលរដ្ឋ) អំពីការគ្រប់គ្រងស្ថាប័នរបស់ពួកគេ អំពីទិដ្ឋភាពបច្ចេកទេស និងថវិកា។

អ្នកចូលរួមរបស់មណ្ឌលសុខភាពដូចជាមិនសូវជាសកម្មជាងអ្នកផ្តល់សេវាផ្សេងៗទៀត។ ប្រជាជននៅទីក្រុងមានភាពស្ទាក់ស្ទើរ ឬមានភាពប្រុងប្រយ័ត្នជាងមុនក្នុងការផ្តល់បទសម្ភាសន៍អំពីការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនដែលបានប្រើប្រាស់របស់ពួកគាត់ទៅកាន់សេវាសាធារណៈ:

ជាមួយយុវជនស្ម័គ្រចិត្ត (CAFs) ឬក្រុមការងារគម្រោង ។ ពួកគាត់មានអារម្មណ៍ភ័យខ្លាច [ស្ទាក់ស្ទើរ] ក្នុងការផ្តល់បានសម្ភាសទៅ CAFs ។

នេះជាលើកទី ១ ហើយសម្រាប់កិច្ចប្រជុំដាក់ពិន្ទុក្នុងតារាងសហគមន៍នៅតំបន់ទីក្រុងគឺមានភាពរសើបយ៉ាងខ្លាំងចំពោះមន្ត្រីរដ្ឋាភិបាល។ វាត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់ពីអាជ្ញាធរ ដូចជាៈ ស្នើសុំលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសម្រាប់ប័ណ្ណដាក់ពិន្ទុសហគមនដែលទាក់ទងនឹងការអភិវឌ្ឍសេវាសង្គមព្រោះវាត្រូវបានគេផ្តល់អាទិភាពតិចជាងការកសាងហេដ្ឋារចនាសម្ព័ន្ធ។

ក្នុងវប្បធម៍នៃការផ្តល់យោបល់ត្រឡប់ដោយផ្ទាល់ជាមួយនឹងអ្នកផ្តល់សេវាក្នុងប្រទេសកម្ពុជាគឺនៅកម្រិតនៅឡើយ ដោយសារភាគច្រើនវិធីសាស្រ្តនេះគឺមិនត្រូវបានយកមកអនុវត្តនៅក្នុងតំបន់ទីក្រុង ដូច្នេះដើម្បីកំណត់អត្តសញ្ញាណអ្នកតំណាង ពលរដ្ឋក្លាហានគឺនៅតែបញ្ហាប្រឈមនៅឡើយ។

ការលាតត្រដាងអំពីថវិកាសាធារណៈមិនត្រូវបានបង្ហាញជាពិសេសដោយអ្នកទទួលខុសត្រូវឡើយ។ មន្ត្រីខ្លះបានគិតថាព័ត៌មានអំពីថវិការបស់ស្ថាប័នពួកគេគឺជាព័ត៌មានដែលសម្ងាត់ ដែលមិនអាចបញ្ចេញទៅជាសាធារណៈបាន។មិនមានប្រកាសស្តីពីការបង្កើត JAPP-C នៅថ្នាក់ខណ្ឌទេ ហើយក៏គ្មានជនបង្គោលណាធ្វើការតាមដានការអនុវត្តផែនការ JAAP ដែរ។

## លទ្ធផលគម្រោងទី៨៖ សម្លេងរបស់ជនមានពិការភាពក្នុងសកម្មភាពគណនេយ្យភាពសង្គម»

**គោលបំណង:** ពង្រឹកសម្លេងជនមានពិការភាព ដើម្បីបង្កើនការទទួលបានសេវាសាធារណៈប្រកបដោយគុណភាព និងស្មើភាពគ្នា នៅតាមស្រុកគោលដៅ ដែលគាំទ្រថវិកាដោយកម្មវិធី វ៉យ របស់អុកស្វាមកម្ពុជា សរុប 156,858ដុល្លារ អាមេរិក។

**លទ្ធផលរំពឹងទុក:**

១.បង្កើនតំណាងនិងសម្លេងជនមានពិការភាពក្នុងការអនុវត្តគណនេយ្យភាពសង្គម

២.បង្កើនការឆ្លើយតបចំពោះសម្លេង និងការទាមទាររបស់ជនមានពិការភាព

៣.តម្រូវការរបស់ជនមានពិការភាពត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយគណនេយ្យភាពសង្គម និងការអនុវត្តឲ្យបានប្រសើរឡើង។

**ដៃគូអនុវត្តគម្រោង:** អង្គការ Epic Arts & CADDP

**លទ្ធផល:**

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API), អង្គការ CADDP និង អង្គការ Epic Arts ស្នើឲ្យមានការអង្កេតប្រកបដោយភាពច្នៃប្រឌិត ក្នុងការសាកល្បង និងសិក្សាពីវិធីសាស្ត្រដែលជនមានពិការភាពអាចប្រើប្រាស់បានកាន់តែមានប្រសើរនូវលទ្ធភាពដែលបានផ្តល់តាមការអនុវត្ត ក្របខណ្ឌគណនេយ្យភាពសង្គម ដើម្បីធ្វើឲ្យសម្លេងរបស់ពួកគេត្រូវបានឆ្លើយតបបានរហ័សក្នុងការទទួលបានសេវាកម្ម និងការចូលរួមកាន់តែប្រសើរឡើងនៅក្នុងអភិបាលកិច្ច មូលដ្ឋាន ក្នុងឃុំគោលដៅទាំង៧ ឃុំលាយបូរ ឃុំគុស ឃុំត្រាំកក់ ឃុំជាងទង ឃុំញ៉ែងញ៉ង ឃុំសំរោង និងឃុំតាភេម ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។

សិក្ខាសាលា "ការចាប់ផ្តើម " ត្រូវបានធ្វើឡើងដោយអនុស្សារណៈយោគយល់គ្នាបានព្រមព្រៀងគ្នាដោយមានការចូលរួមពីគម្រោងចំនួន២ គឺ: គម្រោង "សម្លេងរបស់ជនមានពិការភាពក្នុងសកម្មភាពគណនេយ្យភាពសង្គម " និង គម្រោង "សម្លេង និងសកម្មភាពរបស់ពលរដ្ឋក្នុងគណនេយ្យភាពសង្គម "សិក្ខាសាលាបានបង្ហាញពីការរួមបញ្ចូលគ្នានៃគម្រោងទាំង២។ សិក្ខាសាលានេះផ្តោតលើការផ្តល់សិទ្ធិអំណាចដល់តម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសយុវជន ស្ត្រីនិងក្រុមដែលជួបការលំបាក ដើម្បីលើកកំពស់គណនេយ្យភាពសង្គម ដោយផ្តោតលើវិស័យនានា សម្រាប់ការកែលំអរ ការផ្តល់សេវាសាធារណៈ សុខភាព អប់រំ និងសេវាឃុំសង្កាត់ ។ល។

ការចាប់ផ្តើមគម្រោងជាផ្លូវការនេះ មានអ្នកចូលរួមចំនួន ៨៦នាក់ (ស្ត្រី២២នាក់) មកពី៖ អាជ្ញាធរមូលដ្ឋានគោលដៅ ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ (គ.ជ.អ.ប) អ្នកទទួលផល និងអង្គការសង្គមស៊ីវិល។ សិក្ខាសាលាត្រូវបានធ្វើឡើងក្នុងលក្ខណៈមួយដើម្បី ផ្តល់ភាពងាយស្រួល និងភាសាសញ្ញា និងការសម្តែងរបស់ជនមានពិការភាពគ្រប់ប្រភេទ ដើម្បីសង្កត់ធ្ងន់លើការផ្តល់ សិទ្ធិអំណាច ដល់ក្រុមជួបការលំបាក។

សិក្ខាសាលានេះមានការចូលរួមពីថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធមូលដ្ឋាន ព្រមទាំងបើកកម្មវិធីដោយតំណាង គ.ជ.អ.ប វាគ្មិនមកពីអង្គការ ទស្សនៈពិភពលោក ក្រសួងអប់រំយុវជននិងកីឡា ក្រសួងសុខាភិបាល អង្គការអុកស្វាម សមាជិក សម្ព័ន្ធទាំង២ និងអាជ្ញាធរមូលដ្ឋាន។ ពួកគេបានប្តេជ្ញាលើកកំពស់សម្លេង និងសកម្មភាពរបស់ជនមានពិការភាពនៅក្នុង ក្របខណ្ឌគណនេយ្យភាពសង្គម ក្នុងវិស័យរៀងៗខ្លួន ដោយមានការសហការជាមួយការព្រមព្រៀងរបស់គម្រោង។

ដើម្បីអនុវត្តគម្រោងនេះបាន ត្រូវធ្វើការបណ្តុះបណ្តាលជាពិសេសអំពីក្របខណ្ឌគណនេយ្យភាពសង្គមទៅដល់អ្នក ពាក់ពន្ធ័គ្រប់កម្រិត។ សំណើរនេះត្រូវបានស្នើឡើងនៅក្នុងកិច្ចប្រជុំអង្គការសង្គមស៊ីវិល និងភាពជាដៃគូរបស់ រដ្ឋាភិបាលក្នុងក្របខណ្ឌគណនេយ្យភាពសង្គម ដែលមាន **ឯកឧត្តម ងី ចន្ទ័ផល** រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការក្របខណ្ឌគណនេយ្យភាពសង្គម។ អង្គការ អុកស្វាម និង API បានយល់ព្រម និងគាំទ្រការចំណាយលើវគ្គបណ្តុះបណ្តាលចំនួន២ ដល់អ្នកពាក់ពន្ធ័ក្នុងការ អនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម ចំនួន១៣៩នាក់ (ស្ត្រី៣០នាក់) ដែលជាអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីឲ្យពួកគេអាចដឹកនាំការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម និងធានាបានថាការ បញ្ចូលជនមានពិការភាពទៅក្នុងក្របខណ្ឌគណនេយ្យភាពសង្គម។

វគ្គបណ្តុះបណ្តាលនេះត្រូវបានសម្របសម្រួលដោយអាជ្ញាធរខេត្តតាកែវ អង្គការទស្សនៈពិភពលោកអន្តរជាតិនិងAPI។

បន្ទាប់មកអ្នកចូលរួមដែលបានទទួលការបណ្តុះបណ្តាលអាចបំពេញព័ត៌មាន និងប្រមូលទិន្នន័យដើម្បីផលិត "ប្រកាសនៅលើ" វិបសាយ គ.ជ.អ.ប សម្រាប់សេវាកម្មសាលាបឋមសិក្សា មណ្ឌលសុខភាព និងឃុំក្នុងស្រុកត្រាំកក់។

ការបញ្ចូលសម្លេងរបស់ជនមានពិការភាពនៅក្នុងក្របខណ្ឌគណនេយ្យភាពសង្គម ការស្ទង់មតិតាមរបៀប Snowball ត្រូវបានធ្វើឡើងកំណត់ និងវាយតម្លៃស្ថានភាពរស់នៅ បទពិសោធន៍ និងការយល់ឃើញ របស់ពួកគេក្នុងការទទួល បានសេវាសាធារណៈ និងចូលរួមក្នុងសកម្មភាពគម្រោង ព្រមទាំងសកម្មភាពស្តង់ដាររបស់ក្របខណ្ឌគណនេយ្យភាពសង្គម ដែលអនុវត្តដោយដៃគូទី៣ របស់អង្គការទស្សនៈពិភពលោក និងស្ថាប័ន២ទៀតគឺអង្គការ CADDP និង អង្គការ Sovann Phum។ របាយការណ៍ស្ទង់មតិ Snowball ឆ្នាំ២០១៩ បានបង្ហាញថា ជនមានពិការភាព ពេញចិត្ត សេវាសាធារណៈបច្ចុប្បន្ននៅមានភាគរយទាប។

ជនមានពិការភាព និងក្រុមជនងាយរងគ្រោះសរុបនៅក្នុងស្រុកត្រាំកក់មានចំនួន ៥១៤នាក់ ត្រូវបានគេកំណត់ អត្តសញ្ញាណ ហើយពួកគេបានវាយតម្លៃតាមបទពិសោធន៍ និងការបញ្ចេញយោបល់របស់ពួកគេលើសេវាសាធារណៈ ការស្ទង់មតិ Snowball បានរកឃើញ និងសន្និដ្ឋានថានៅមានភាគរយទាបនៃការទទួលបានសេវាសាធារណៈ ពីជនមានពិការភាព ហើយថែមទាំងនៅមានភាគរយទាបដែលពេញចិត្តនឹងការផ្តល់សេវានាពេលបច្ចុប្បន្ន។
ការស្ទង់មតិនេះធ្វើឡើងដោយអ្នកស្មគ្រ័ចិត្តដែលមានពិការភាពចំនួន០៤នាក់ (ស្ត្រី០២នាក់) ។ ក្នុងចំណោមបញ្ហាដែលត្រូវបានលើកឡើងក្នុងពេលស្ទង់មតិបង្ហាញថាជនមានពិការភាពទូទាត់ប្រាក់បន្ថែមសម្រាប់ការថែរទាំសុខភាព ហើយប្រឈមនឹងការរើសអើង ឧទាហរណ៍ការផ្តល់យោបល់របស់ជនមានពិការភាពមិនត្រូវបានគេយកមកពិចារណាក្នុងពេលប្រជុំដើម្បីឲ្យពួកគេមានភាពងាយស្រួលឡើយ។

ការប្រជុំពិគ្រោះយោបល់មួយបានធ្វើឡើងនៅរាជធានីភ្នំពេញ បានចែករំលែកការរកឃើញ និងលទ្ធផលនៃការស្ទង់មតិ Snowball ក្នុងឃុំគោលដៅទាំង៧ ក្នុងស្រុកត្រាំកក់។ ការស្ទង់មតិ Snowball ទាក់ទងទៅនឹងបញ្ហាប្រឈមក្នុងការទទួលបានសេវាសាធារណៈ ការផ្តល់អំណាច និងការតស៊ូមតិដោយខ្លួនឯងពីជនមានពិការភាព ហើយការប្រជុំពិគ្រោះយោបល់នេះមានអ្នកចូលរួមសរុបចំនួន ៧៩ នាក់ (ស្ត្រី២៧នាក់) ព្រមទាំងបានពិភាក្សាអំពីការតស៊ូមតិថ្នាក់ជាតិនូវបញ្ហា ប្រឈមរបស់ជនមានពិការ

ភាពក្នុងការទទួលបានសេវាសាធារណៈ តំណាងជនមានពិការភាពមានអារម្មណ៍ជឿជាក់ក្នុងការចែករំលែកបញ្ហាប្រឈម និងផ្តល់យោបល់ដល់អាជ្ញាធរមូលដ្ឋាន និងតំណាងក្រសួង។

តំណាង គ.ជ.អ.ប នៅក្នុងកិច្ចប្រជុំបានទទួលស្គាល់ គ.ជ.អ.ប បានរៀបចំបញ្ចូលឯកសារបច្ចេកទេសសម្រាប់ការលើក កំពស់ការចូលរួមប្រកបដោយគុណភាព នៅក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន។ ក្នុងកិច្ចពិភាក្សានេះ អង្គការមួយចំនួនដែលធ្វើការលើវិស័យពិការភាព គឺកំពុងតែជួបនូវការលំបាកមួយចំនួនក្នុងការគាំទ្រជនមានពិការភាពក្នុងសេវាអប់រំ និងសេវាសង្គម តាមរយៈកង្វះមធ្យោបាយងាយស្រួល កង្វះសម្ភារៈរួមបញ្ចូលក្នុងផ្នែកអប់រំ។

ដើម្បីធានាថាតំណាងជនមានពិការភាពត្រូវបានកំណត់អត្តសញ្ញាណ និងជ្រើសរើសមានសមត្ថភាពមានទំនុកចិត្ត ដើម្បីចូលរួមក្នុងដំណើរការក្របខណ្ឌគណនេយ្យភាពសង្គម និងការតស៊ូមតិនៅថ្នាក់ជាតិ សិក្ខាសាលាជាស៊េរីក្នុងចំណោម៧ ស្តីពីការផ្តល់សិទ្ធិអំណាចដោយមានលក្ខណៈច្នៃប្រឌិត "សម្លេងរបស់ខ្ញុំ" ក្នុងខេត្តតាកែវ ធ្វើឡើងសម្រាប់ទាំងជនមាន ពិការភាព និងអ្នកគាំទ្រនៅសហគមន៍ ដើម្បីពង្រឹងសមត្ថភាពអ្នកចូលរួម ឲ្យមានទំនុកចិត្ត និងមានការគោរពខ្លួនឯង ក៏ដូចជាលើកទឹកចិត្តឲ្យពួកគេជឿថាសម្លេងរបស់ពួកគេក៏សំខាន់ដែរ។ សិក្ខាសាលាទាំងនេះ សម្របសម្រួលដោយមានការសម្តែងសិល្បៈដោយអង្គការ Epic Arts ហើយសិក្ខាសាលាដែលបណ្តុះជំនាញវិជ្ជាជីវៈ និងមានគុណភាពខ្ពស់ដើរតួជាការលើកទឹកចិត្តយ៉ាងសំខាន់សម្រាប់អ្នកទទួលផលពីសិក្ខាសាលា។ ការវាយតម្លៃសិក្ខាសាលាស្តីពីការផ្តល់សិទ្ធិអំណាចបានបង្ហាញថា៩៩%នៃអ្នកចូលរួម៨៥ នាក់មានភាពពេញចិត្តនឹងសិក្ខាសាលា ហើយពួកគាត់មានអារម្មណ៍ថាវាបានជួយពួកគាត់ក្នុងការចែករំលែកសំលេងរបស់ពួកគាត់ផងដែរ។

ការបណ្តុះបណ្តាលដែលបានបញ្ចូលសម្រេងជនពិការត្រូវបានដាក់បង្ហាញនៅក្នុងសកម្មភាពបណ្តុះបណ្តាលរយៈពេល ០២ ថ្ងៃដល់មនុស្សចំនួន ២៥ នាក់ (ស្ត្រី០៩នាក់) វគ្គបណ្តុះបណ្តាលនេះបានរកឃើញពីរបៀបដែលបុគ្គលម្នាក់ៗនៅក្នុងដំណើរការក្របខណ្ឌគណនេយ្យភាពសង្គម អភិវឌ្ឍក្នុងការដាក់បញ្ចូលវិធីសាស្ត្រឲ្យបានកាន់តែច្រើនលើកការងាររបស់ពួកគាត់ និងមនុស្សដែលពួកគាត់មានទំនាក់ទំនងជាមួយ។

## លទ្ធផលគម្រោងទី៩ ៖ លើកកម្ពស់ការចូលរួមរបស់យុវជន ដំណើរការរៀបចំផែនការ និងថវិការដ្ឋបាលឃុំសង្កាត់ ២០១៩ - ២០២១

**គោលបំណងនៃគម្រោង:** ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការផែនការ និងថវិកា ដើម្បីអោយអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ឃុំសង្កាត់កាន់តែប្រសើរ ជាពិសេសការឆ្លើយតបតម្រូវការរបស់យុវជនស្ត្រី កុមារ និង ជនងាយរងគ្រោះ។

**លទ្ធផលចុងឆ្នាំ: អជ្ញាធរមូលដ្ឋាន (ឃុំ និងសង្កាត់) ចាត់បញ្ហា តម្រូវការរបស់យុវជន និងកុមារជាអទិភាពទៅក្នុង** ដំណើរការផែនការ និងបែងចែកធនធានបន្ថែមសំរាប់សេវាសង្គមដើម្បីសុខមាលភាពយុវជន។

**លទ្ធផល**

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយAPI បានសហការជាមួយរដ្ឋបាលស្រុកគោលដៅក្នុងការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងប្រកាសបើកគម្រោង «លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងថវិកានៅរដ្ឋបាលឃុំសង្កាត់»។ កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណង៖

- ដើម្បីផ្សព្វផ្សាយពីគោលបំណង និងសកម្មភាពរបស់គម្រោង និងស្វែងរកការសហការពីអ្នកពាក់ព័ន្ធ
- ដើម្បីសិក្សា និងកំណត់យកតំណាងក្រុមយុវជន ពីសហគមន៍ និងក្រុមនានាក្នុងឃុំ សង្កាត់គោលដៅក្នុងការចូលរួមរាល់ដំណើរអនុវត្តគម្រោង

**កិច្ចប្រជុំនេះបានអនុវត្តនៅស្រុកគោលដៅដូចខាងក្រោម៖**

- សាលាស្រុកស្អាង ខេត្តកណ្តាល ដែលមានអ្នកចូលរួមចំនួន៨០នាក់ (ស្ត្រី២០នាក់)
- សាលាស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានអ្នកចូលរួមចំនួន៣៣នាក់ (ស្ត្រី១៣នាក់)
- សាលាស្រុកចិត្របុរី ខេត្តក្រចេះ ដែលមានអ្នកចូលរួមចំនួន៥៣នាក់ (ស្ត្រី២០នាក់)
- សាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានអ្នកចូលរួមចំនួន២៧នាក់ (ស្ត្រី៦នាក់)

**បញ្ហាប្រឈម**

- ខ្វះក្លឹបយុវជនសកម្មនៅតាមឃុំគោលដៅ
- អាជ្ញាធរថ្នាក់ក្រោមជាតិនៅតែទាមទារឯកសាររដ្ឋបាលបន្ថែមទោះជាមានលិខិតអនុញ្ញាគម្រោងពីគ.ជ.អ.ប

**ផែនការ**

- ផ្តល់វគ្គបណ្តុះបណ្តាល និង កសាងសមត្ថភាពសម្រាប់យុវជន (៥វគ្គ ក្នុង១វគ្គ ៣ថ្ងៃ) ពីតួនាទី និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងយុវជន ការធ្វើផែនការអភិវឌ្ឍ និងថវិការឃុំ ការតស៊ូមតិ និង សិទ្ធទទួលព័ត៌មាន។
- គាំទ្រការទំនាក់ទំនងរបស់ក្រុមយុវជន តាមរយៈប្រព័ន្ធសេវាសង្គមហ្វេសប៊ុក (Facebook) ជាមួយសមាជិករបស់ពួកគេក្នុងដំណើររៀបចំផែនការ កាលវិភាគ និងសេវាព័ត៌មានសេវាសាធា រណៈ លើបញ្ហាថវិកា និងសេវាសង្គម។
- គាំទ្រតំណាងក្រុមយុវជន និងសមាជិកអោយចូលរួម និងតាមដានដំណើរការធ្វើផែនការអភិវឌ្ឍ និងថវិការឃុំ (ផ្តែកលើសកម្មភាពគម្រោង) ។
- រៀបចំប្រជុំប្រចាំត្រីមាសក្នុងតំបន់គោលដៅ ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផល នៃការចូលរួមរបស់ក្រុមតំណាងយុវជនក្នុងដំណើរការធ្វើផែនការអភិវឌ្ឍ និងថវិការឃុំ។

## លទ្ធផលគម្រោងទី១០ ៖ គំរោង៖ពង្រឹងគណនេយ្យភាពការិយាល័យច្រកចេញចូលតែមួយ )OWSO-PEA) ២០១៩- ២០២២

**គោលបំណង៖** បង្កើនសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការចូលរួមក្នុងដំណើរការនយោបាយ។

អង្គការ API បានទទួលកិច្ចសន្យាដែលបានចុះហត្ថលេខាពីទីភ្នាក់ងារ USAID ដោយគម្រោង Nickol Global Solutions LLC (NGS) នៅថ្ងៃទី ១ ខែតុលាឆ្នាំ ២០១៩។ ដើម្បីអនុវត្តការិយាល័យសេវាកម្មច្រកចេញចូលតែមួយ - វេទិកាដើម្បីលើកកម្ពស់កម្មវិធីគណនេយ្យភាព (កិច្ចសន្យាលេខ # 72044219C00001) ។ ការិយាល័យរបស់ការិយាល័យច្រកចេញចូលតែមួយ - វេទិកាដើម្បីលើកកម្ពស់គណនេយ្យភាព (OWSO-PEA) គោលដៅរបស់គម្រោងគឺដើម្បីបង្កើនសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការចូលរួមក្នុងដំណើរការនយោបាយតាមរយៈការធ្វើអន្តរាគមន៍សាកល្បងរួមទាំង ការរចនានិងការអនុវត្តឧបករណ៍បច្ចេកវិទ្យាស៊ីវិលសកម្មភាពផ្សព្វផ្សាយ /សកម្មភាពចូលរួម។ សកម្មភាពតាមដាននិងសកម្មភាពបំពេញផ្សេងទៀតដើម្បីគាំទ្រការច្នៃប្រឌិត ជោគជ័យ និងនិរន្តរភាព។

**ដៃគូអនុវត្តគម្រោង៖** វិទ្យាស្ថានគោលនយោបាយតស៊ូមតិ (API) និ InSTEDD គឺជាសមាជិកនៃសម្ព័ន្ធនៃដែលដឹកនាំដោយនីកូលក្លូប៊ិលសូលូសិន (Nickol Global Solutions) ត្រូវបានទទួលថវិកាអនុវត្តគម្រោងចំនួន បីឆ្នាំពីទីភ្នាក់ងារ USAID គម្រោងការសិក្សាសម្របគឺ ដើម្បីចូលរួមនៅក្នុងសហគមន៍ដែលនៅជុំវិញការិយាល័យច្រកចេញចូលតែមួយក្នុងខេត្តបាត់ដំបង ខេត្តសៀមរាប និងកំពង់ខេត្តធំ។ API ទទួលបានថវិកាចំនួន *៥៦១.៨១៩.៨១* ដុល្លារអាមេរិចនៃគម្រោងសរុប ៣ លានដុល្លារ នៅខែតុលាឆ្នាំ ២០១៩ - កញ្ញា ២០២២ ។

**សម្មតិកម្មអភិវឌ្ឍន៍ដើម្បីសម្រេចបានគោលដៅនេះត្រូវបានបង្ហាញដូចខាងក្រោម៖**

- ប្រសិនបើប្រជាពលរដ្ឋមានពេលវេលាជាក់លាក់ក្នុងការផ្តល់និងទទួលព័ត៌មានគួរឱ្យទុកចិត្តអំពីសេវាកម្មការិយាល័យច្រកចេញចូលតែមួយតាមរយៈការច្នៃប្រឌិតបច្ចេកវិទ្យាថ្មី។
- ហើយប្រសិនបើពួកគេចូលរួមតាមរយៈដំណើរការដែលមានអត្ថន័យ
- បន្ទាប់មកពួកគេនឹងអាចជួយដោយរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធិភាពក្នុងការធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈតាមរយៈការិយាល័យច្រកចេញចូលតែមួយ។

តាមរយៈវិធីស្រាវជ្រាវ (SBAR)ដោយការប្រើប្រាស់កិច្ចសន្យាទិញសម្ភារៈ NGS API INSTEDD នឹងកំណត់អនុវត្តនិងជំរុញដំណោះស្រាយដែលមានបច្ចេកវិទ្យាដើម្បីពង្រីកការទទួលបាននិងការយល់ដឹងជាសាធារណៈអំពីសេវាកម្មការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋនិងបង្កើតឧបករណ៍ត្រួតពិនិត្យដើម្បីជួយពលរដ្ឋនិងអាជីវកម្មដើម្បីរាយការណ៍ពីប្រសិទ្ធភាពរបស់ពួកគេ/ការពេញចិត្តនៃសេវាកម្មការិយាល័យច្រកចេញចូលតែមួយជាមធ្យោបាយសម្រាប់អាជ្ញាធររដ្ឋាភិបាលក្នុងការវាស់វែងដំណើរការឲ្យកាន់តែប្រសើរឡើងលើការផ្តល់សេវាកម្មនិងឆ្លើយតបទៅនឹងតម្រូវការផ្តល់សេវាឲ្យប្រជាពលរដ្ឋ។

ចាប់ផ្តើមជាមួយនឹងការកៀរគរបុគ្គលិកវាជាសកម្មភាពមួយភាគបួននៃសកម្មភាពបង្កើតគំរោងបុគ្គលិកនិងការចូលរួមដោយផ្ទាល់ជាមួយអ្នកពាក់ព័ន្ធ។

## សកម្មភាពបានបញ្ចាប់មាននៅខាងក្រោមៈ

ជួបប្រជុំជាមួយអគ្គនាយក នៃក្រសួងមហាផ្ទៃ និងក្រសួងមហាផ្ទៃបានចេញលិខិតគាំទ្រដល់អភិបាលខេត្តបាត់ដំបងដើម្បីគាំទ្រដល់ការអនុវត្តគម្រោង។

ប្រជុំជាមួយអភិបាលរងខេត្តបាត់ដំបងអភិបាលនិងការិយាល័យច្រកចេញចូលតែមួយនៅតាមស្រុកគោលដៅនិងជ្រើសរើសស្រុកគោលដៅនិងក្រុងចំនួន ៦ គោលដៅ។

ចុះមូលដ្ឋាននៅបាត់ដំបងការចូលរួមនៅតាមស្រុកចំនួ - ន ៦ជាមួយការគ្រប់គ្រងការិយាល័យច្រកចេញចូលតែមួយស្រុក ការិយាល័យប្រជាពលរដ្ឋនិងអ្នកប្រើប្រាស់ការិយាល័យច្រកចេញចូលតែមួយ

- សិក្ខាសាលាស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងបាត់ដំបង ONG/ CBO។
- បទសម្ភាសន៍ប្រវត្តិរូបការិយាល័យច្រកចេញចូលតែមួយនៅក្នុងខេត្តបាត់ដំបង
- លំហាត់ផែនទីត្រូវបានបញ្ចប់
- ការវិភាគបញ្ចប់ការនៃអ្នកចូលរួមរបស់ភាគីពាក់ព័ន្ធ;
- សិក្ខាសាលាស្តីពីទេសភាព OWSO
- ការប្រជុំក្រុមផ្តោតលើថ្ងៃប្រឌិតនៃអ្នកប្រើប្រាស់នៅមជ្ឈមណ្ឌលអ្នកប្រើប្រាស់

**មេរៀនដែលបានរៀនសូត្រ**

- គំនិតផ្តួចផ្តើមដំបូង គឺផ្តោតទៅលើការអភិវឌ្ឍន៍បច្ចេកវិទ្យាសំរាប់ការសាកល្បង និងការប្រើប្រាស់ឧបករណ៍សំរាប់ ច្រកចេញចូលតែមួយ និងយល់ពីចំនុចគោលពីបុគ្គលិកច្រកចេញចូលតែមួយ និងចំណុចពិសេសជាការយល់ដឹងរបស់ប្រជាពលរដ្ឋ តម្រូវការប្រជាពលរដ្ឋ។

**ផែនការ**

- ការផ្សព្វផ្សាយដល់សាធារណៈទាំងការផ្សព្វផ្សាយ និងការផ្តល់ព័ត៌មានអំពីបច្ចេកវិទ្យាដែលកំពុង បង្កើត និង ភ្ជាប់ដោយផ្ទាល់ជាមួយសហគមន៍ ដោយស្របនិងដំណើរការដាក់ពន្ទុ
- បច្ចេកវិទ្យា ការអប់រំផ្ទាល់តាមសម្ភារះ ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗនិងត្រូវបង្កើតឡើង និង សម្របសម្រួលដោយផ្ទាល់ពីមុខងាររបស់បច្ចេកវិទ្យាដោយក្រុមហ៊ុនបច្ចេកវិទ្យា។
- ផ្តល់ការបណ្តុះបណ្តាលដល់យុវជនពីតួនាទី និងកាតព្វកិច្ចរបស់អ្នកតាមដាន ការដាក់ពន្ទុដោយប្រជាបលរដ្ឋ
- កំណត់អង្គការសង្គមស៊ីវិល និងអង្គការសហាកមន៍(ផ្លូវការ និង មិនផ្លូវការ) សំរាប់សហគមន៍ដើម្បីអនុវត្តពីសេវាសាធារណៈ
- បង្កើតក្រុមការងារក្នុងការជ្រើសរើសស្រុក ខេត្ត ពីយន្តការទទួលពាក្យបណ្តឹង និង ដំណើរការដោះស្រាយ
- ប្រមូលទិន្នន័យគោលមុនការអនុវត្តគម្រោង
- ផ្តល់វគ្គបណ្តុះបណ្តាល់ដល់យុវជន និង ការប្រមូលទិន្នន័យ
- ការស្ទង់មតិតាមរយៈការដាក់ពិន្ទុ ដែលបង្កើតឡើងអោយទៅនិងគម្រោង OWSO and DO និងស្រុក
- រៀបចំការប្រជុំថ្នាក់ខេត្ត និងស្រុកសំរាប់ក្រុមការងារគណនេយ្យភាពរបស់គម្រោង
- វេទិការសាធារណៈ និងកម្មវិធីផ្សព្វផ្សាយ តាមរយៈប្រពន្ធផ្សព្វផ្សាយ និងការចុះផ្សាយតាមផ្ទះពីគម្រោង OWSO

## លទ្ធផលគម្រោងទី១១៖កសាងសមត្ថភាពអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាស្តីពីជំនាញការកៀរគរការគាំទ្រ និង ការកៀរគរធនធានក្នុងស្រុក

គោលបំណង គឺដើម្បីធានានូវធនធានគ្រប់គ្រានរបស់អង្គការសង្គមស៊ីវិល ដើម្បីបន្តប្រតិបត្តិការរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ ដែលគម្រោងមានថវិកាសរុបចំនួន ៦៧,៨៦៣.២អឺរ៉ូ គាំទ្រដោយ Stichting Wilde Ganzen ។ អង្គការAPI និងអង្គការCCC គឺជាអ្នកសម្របសម្រួល/គ្រូបណ្តុះបណ្តាលលើគម្រោងនេះក្នុងឆ្នាំ២០១៩-២០២០ ។

**ដៃគូអនុវត្តន៍៖** គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

### លទ្ធផល

អង្គការAPI និងអង្គការCCC បានសម្របសម្រួល៨វគ្គ ដែល៥ថ្ងៃក្នុងមួយវគ្គ គឺសម្រាប់កម្មវិធីការស្វែងរកការគាំទ្រ/ការតស៊ូមតិ និងកម្មវិធីការកៀងគរថវិកាក្នុងស្រុក ដែលមានអ្នកចូលរួម៣០នាក់ (ស្រី១១នាក់) ដែលមកពីតំណាងអង្គការថ្នាក់ក្រោមជាតិ និងសមាគមខេត្តនៃក្រុមប្រឹក្សាមូលដ្ឋាន។ សម្រាប់អ្នកចូលរួមកម្មវិធី ការកៀងគរថវិកាក្នុងស្រុក បានពន្យល់ច្បាស់ពីតំរូវការ ហេតុអ្វីបានជាត្រូវមានកម្មវិធីនេះ ចំពោះកម្មវិធីការកៀងគរថវិកាក្នុងស្រុក បានបង្ហាញពីខ្លឹមសារនៃការស្វែងរក ប្រភពចំណូលផ្សេងៗគ្នា និងវិធីសាស្ត្រប្រមូលធនធានឱ្យមានប្រសិទ្ធិភាពនៅគ្រប់កម្រិត។ អ្នកចូលរួមវគ្គស្វែងរកការគាំទ្រ/ការតស៊ូមតិ អាចបង្កើតគំនិតថ្មីល្អៗ សម្រាប់ដោះបញ្ហា សកម្មភាពមួយជាក់លាក់ ដែលពួកគេអាចដោះស្រាយបានសម្រាប់អង្គការរបស់ពួកគេ ដូចជាការដឹកនាំ និងអនុវត្តផ្ទាល់។ ចំពោះអ្នកចូលរួមកម្មវិធីទទួលបានការណែនាំអំពី ការរៀបចំផែនការសកម្មភាព និងរបៀបរាយការណ៍អំពីសកម្មភាពរបស់ពួកគេ។ នៅក្នុងវគ្គនេះមានអង្គការចំនួន៨ ដូចជាអង្គការ ខ្មែរអភិវឌ្ឍន៍ជនពីការ និងអ្នកក្រីក្រ អង្គការ Epic Arts អង្គការក្រុមទ្រទ្រង់ភូមិ និងអង្គការទ្រទ្រង់ស្ត្រីខ្មែរខេត្តកំពង់ធំ ត្រូវបានបណ្តុះបណ្តាល និងបង្វឹក លើការអភិវឌ្ឍន៍គម្រោង និងហិរញ្ញវត្ថុ។

អ្នកចូលរួមកម្មវិធីសរុបចំនួន១៣នាក់ (ស្រី៥នាក់) ដែលមកពីអង្គការក្រៅរដ្ឋាភិបាលផ្សេងៗគ្នា បានចូលរួមក្នុងវគ្គស្វែងរកការគាំទ្រ/ការតស៊ូមតិ (ដែលមាន៤វគ្គ សម្រាប់១២ថ្ងៃ) ហើយ ២ដង សម្រាប់ការតាមដានបង្វឹកម្នាក់ម្តងៗ។ នៅអំឡុងពេលវគ្គបណ្តុះបណ្តាល អ្នកសម្របសម្រួលបានដឹកនាំ អ្នកចូលរួមឲ្យចេះ សរសេរ និងអនុវត្តគម្រោងផែនការ ដោយផ្អែកលើបញ្ហារបស់អង្គការផ្ទាល់ខ្លួនដើម្បីដោះស្រាយ។

សម្រាប់កម្មវិធីវគ្គកៀងគរថវិកាក្នុងស្រុក មានអ្នកចូលរួមចំនួន២៣នាក់ (ស្រី៥នាក់) ដែរមកពីអង្គការក្រៅរដ្ឋាភិបាលបានផ្សេងៗគ្នា (វគ្គនេះមាន៣វគ្គ ចំនួន៧ថ្ងៃ) ដោយមានការតាមដានហ្វឹកហាត់សម្រាប់អ្នកចូលរួមម្នាក់ៗដូចគ្នា។ កំឡុងពេលបណ្តុះបណ្តាល អ្នកចូលរួមទាំងអាចអភិវឌ្ឍន៍ និងអនុវត្តផែនការកៀងគរថវិកាក្នុងស្រុក ដើម្បីគាំទ្រដល់បេសកកម្មអង្គការរបស់ពួកគេ។

កម្មវិធីការស្វែងរកការគាំទ្រ/ការតស៊ូមតិអ្នកចូលរួមមានគម្រោងផែនការសរុប៨ ដែលត្រូវបានលើកយកមកដោះស្រាយ និងអនុវត្តដោយគម្រោងផែនការខ្លះទទួលបានជោគជ័យ និងគម្រោងខ្លះមានឧបសគ្គ។ បង្ហាញខាងក្រោមនេះគឺជាគោលបំណងនៃផែនការ សំរាប់ដៃគូនីមួយៗរួមជាមួយនឹងលទ្ធផលនៃការអនុវត្ត។

- **មូលនិធិសម្រាប់ការអភិវឌ្ឍ/ ជំនួយសង្គ្រោះអន្តរជាតិ (FIDR)៖** បានស្វែងរកការគាំទ្រពី ក្រុមប្រឹក្សាឃុំ សាលារៀន មន្ទីរអប់រំ និងក្រុមប្រឹក្សាស្រុក ដើម្បីគាំទ្រថវិកាចូលរួមចំណែកក្នុងការកសាងគម្រោងសាលា និងគាំទ្រថវិកាប្រចាំឆ្នាំដើម្បីគាំទ្រការថែទាំ។
- **អង្គការក្តីករុណា៖** បានធ្វើការស្វែងរកការគាំទ្រពី សាលាក្រុងភ្នំពេញ និងក្រសួងមហាផ្ទៃ ដើម្បីផ្តល់កន្លែងសម្រាប់សាងសង់បណ្ណាល័យខ្មែរក្រហមនៅទីតាំង វាលពិឃាតជើងឯក និងដាក់បញ្ចូលគម្រោង" ផ្កាស្លាក្រោយអង្គរ" ទៅក្នុងកម្មវិធីអប់រំថ្នាក់ជាតិ។
- **អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍន៍សង្គម៖** ស្វែងរកការគាំទ្រពី មន្ទីរខេត្ត និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីគាំទ្រនិងផ្តល់អនុស្សរណៈទទួលស្គាល់សាលាអង្គការសកម្មភាពព្រះពុទ្ធសាសនា ដើម្បីការអភិវឌ្ឍន៍សង្គម សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- **មូលនិធិដុនបូស្កូកម្ពុជា(ខេត្តកែប)៖** បានស្វែងរកការគាំទ្រ ដើម្បីឱ្យមន្ទីររៀបចំដែនដី ន គរូបនីយកម្ម និងសំណង់ផ្លាស់ប្តូរប្លង់ដី ពីបុគ្គល ទៅជាមូលនិធិដុនបូស្កូកម្ពុជានៅខេត្តកែប។
- **អង្គការស្ពាន៖**បានស្វែងរកការគាំទ្រតាមរយៈក្រុមប្រឹក្សាឃុំ និងសាលារៀន ដើម្បីគាំទ្រថវិកាក្នុងការចូលរួមសាងសង់កន្លែងស្តុកទឹកក្នុងអាគារសាលារៀនថ្មី។
- **ការអភិវឌ្ឍន៍សម្លេងសហគមន៍៖**ផែនការស្វែងរកការគាំទ្រពីរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ដើម្បីកំណត់ព្រំប្រទល់សហគមន៍នេសាទ

## ការរៀនសូត្រ

មុនពេលបណ្តុះបណ្តាល គ្រូបង្គោលបានសាកល្បងមេរៀនតាមប្រព័ន្ធអ៊ិនធឺណែត ស្តីពីមេរៀនការកៀងគរថវិកាក្នុងស្រុក និងមេរៀនការស្វែងរកការគាំទ្រ/ការតស៊ូមតិ ដែលមានការចាប់អារម្មណ៍ច្រើនចំពោះខ្លឹមសារមេរៀនសម្រាប់វគ្គសិក្សា បទពិសោធន៍ការកៀងគរថវិកាក្នុងស្រុក យុទ្ធសាស្ត្រ ឧបករណ៍ និងចំណេះដឹងជាក់ស្តែង។ បុគ្គលិកអង្គការAPI បានព្យាយាមស្វែងយល់ និងចំណាយពេលវេលាពិភាក្សាច្រើនដង ក្នុងការរកវិធីសាស្ត្រអនុវត្ត ដែលមានភាពដូចគ្នានៅក្នុងប្រទេសកម្ពុជា ជាពិសេសរបៀបបង្កើត និងធ្វើឱ្យមានការរីកចម្រើនដល់អង្គការក្រៅរដ្ឋាភិបាល និងប្រើវិធីសាស្ត្រទន់ភ្លន់ក្នុងការស្វែងរកការគាំទ្រនៅក្នុងបរិបទនយោបាយរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន។

បន្ថែមពីនេះទៀត កម្មវិធីCtGA មានគុណតម្លៃ ស្តីពីខ្លឹមសាររបស់មេរៀន ដែលត្រូវបានរៀនចំដោយឈរលើមូលដ្ឋានគ្រឹះរបស់អង្គការដៃគូ CtGA ហើយកម្មវិធីនេះបានអនុវត្តដំបូងគេនៅប្រទេសឥណ្ឌា ប្រទេសគេនយ៉ា និងប្រទេសប្រេស៊ីល។ ជាលទ្ធផលដៃគូសហការ អង្គការAPI និងអង្គការCCC មានបេសកកម្ម ដើម្បីផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាជនកម្ពុជា និងអង្គការសង្គមស៊ីវិល ដើម្បីឆ្ពោះទៅរកការទទួលបានសិទ្ធិក្នុងមូលដ្ឋានរបស់ពួកគេ និងស្វែងរកការគាំទ្រនៅក្នុងសហគមន៍ និងរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងការទាមទារ។ប៉ុន្តែត្រូវចំណាយពេលវេលាច្រើនដើម្បីធ្វើការផ្លាស់ប្តូរបរិបទកម្ពុជា ជាមួយ នឹងស្ថានភាពនយោបាយបច្ចុប្បន្ន។

ការស្វែងការគាំទ្រថវិកាតាមប្រព័ន្ធអ៊ិនធឺណែត ការកៀងគរថវិកាតាមរយៈជួបជុំ កៀងគរថវិកាតាមរយៈទំនួយខុសត្រូវរបស់សង្គម ដោយមិនទទួលបានជោគជ័យក្នុងវគ្គកៀងគរថវិកាក្នុងស្រុកនៅឡើយទេ។ ទោះជាយ៉ាងណា ខ្លឹមសារមេរៀន និងផលពិបាក បានបង្ហាញក្នុងផ្នែកមួយនៃវគ្គសិក្សាការកៀងគរថវិកាក្នុងស្រុក ដែលមានរយៈពេល១សប្តាហ៍ បូករួមទាំងការហ្វឹកហាត់ តាមរយៈសិក្ខាសាលា និងការឆ្លុះបញ្ចាំងចុងក្រោយ ហើយខ្លឹមសារមេរៀននេះ គឺជាមេរៀនថ្មីសម្រាប់អង្គការAPI ដែលត្រូវអនុវត្ត និងរៀនសូត្រ។ ដូច្នេះមេរៀននេះបានបន្ថែមចំណេះដឹង វិធីសាស្ត្រស៊ីជម្រៅ មានប្រយោជន៍សម្រាប់អ្នកដែលចង់យល់កាន់តែច្បាស់អំពីវិធីសាស្ត្រកៀងគរថវិកាក្នុងស្រុកប្រកបដោយប្រសិទ្ធភាព។
ឧទាហរណ៍ការកៀងគរថវិកាតាមអ៊ិនធឺណែត អាចត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាស្នូល។ ម្យ៉ាងទៀតខ្លឹមសារមេរៀនការស្វែងរកការគាំទ្រមានភាពប្រហាក់ប្រហែលកម្មវិធីនិងវគ្គបណ្តុះបណ្តាលរបស់

អង្គការAPI ដែលផ្តោតទៅលើការតស៊ូមតិ។ អង្គការAPI បានព្យាយាមស្វែងរកចំណុចសំខាន់ និងសិក្សាអំពីបងពិសោធន៍ថ្មី ដែលស្វែងរកវិធីសាស្រ្តបង្រៀនល្អ ដែលទទួលបានពីប្រទេសស្រីលង្កា និងប្រទេសឥណ្ឌា។

## បញ្ហាប្រឈម និងមេរៀន

- ក្រុមការងារបានចំណាយពេលវេលាដើម្បីរៀបចំផែនការទាំងអស់ ដោយធ្វើការបកប្រែជាភាសារខ្មែរសម្រាប់វគ្គការស្វែងរកការគាំទ្រ ដែលមាន ៥៥៧ផ្នែក និង ៦៦៩ ទំព័រ។
- ចំណាយពេលវេលាក្នុងការ ប្រកាស តាមដាន ហើយស្វែករកអ្នកចូលរួមកម្មវិធីការកៀងគរថវិកាក្នុងស្រុក និង ការស្វែងរកការគាំទ្រ/ការតស៊ូមតិ។
- កម្មវិធីការស្វែងរកការគាំទ្រមិនសូវមានអ្នកចាប់អារម្មណ៍ ដូចកម្មវិធីការកៀងគរថវិកាក្នុងស្រុក ដូចនេះចំនួនអ្នកចូលរួមកម្មវិធីការស្វែងរកការគាំទ្រ/ការតស៊ូមតិមិនមានអ្នកចូលរួមដូចគម្រោងព្រៀងទុក។
- អ្នកចូលរួមកម្មវិធីការស្វែងរកការគាំទ្រ/ការតស៊ូមតិ មានការរវល់ច្រើនចំពោះអាជីវកម្មរបស់ពួកគេ ដូចនេះពួកគេដូចជាមិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួម។
- គំនិតក្នុងកម្មវិធីការស្វែងរកការគាំទ្រ/ការតស៊ូមតិហាក់ដូចជាថ្មី និងក្រៅបទពិសោធន៍ការងារ ហើយមានវិសាលភាពការងារធំដូចនេះមានភាពពិបាកក្នុងការផ្សារភ្ជាន់ទៅជាមួយការងាររបស់ពួកគេ

## ផែនការ

អង្គការAPI និងអង្គការ CCC បានសហការគ្នាឲ្យមានវគ្គចំនួន៤ មាន៥ថ្ងៃ សម្រាប់កម្មវិធីការស្វែងរកការគាំទ្រ/ការតស៊ូមតិ និង៥ថ្ងៃសម្រាប់កម្មវិធីការកៀងគរថវិកាក្នុងស្រុក ហើយកម្មវិធីបង្វឹកនេះជាដំណាក់កាល ផែនការក្នុងការអនុវត្ត វិធីការស្វែងរកការគាំទ្រ/ការតស៊ូមតិ និងកម្មវិធីការកៀងគរថវិកាក្នុងស្រុកដែលមានចំនួន៤០ផែនការ បានពីអង្គការសង្គមស៊ីវិល និងអង្គការសហគមន៍មូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។

## សមទ្ធិផលសមាសភាគទី ៣៖ ធ្វើអោយប្រសើរឡើងក្នុងការទទួលបានព័ត៌មាន និងការបើកចំហព័ត៌មានសាធារណៈស្តីពីបញ្ហាសំខាន់ៗចាប់ពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ។

APIបានធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងរបស់ពលរដ្ឋអំពីសិទ្ធិទទួលបានព័ត៌មាននិងអនុវត្តសិទ្ធិរបស់ពួកគេក្នុងការទទួលបានព័ត៌មានសាធារណៈ និងគាំទ្ររដ្ឋបាលមូលដ្ឋានក្នុងការផ្សព្វផ្សាយព័ត៌មានសាធារណៈស្តីពីបញ្ហាសំខាន់ៗចាប់ពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ។ ជាមួយនឹងការអនុវត្តគម្រោងខាងលើទាំងអស់ នៅកម្រិតគោលនយោបាយ និងសហគមន៍ដើម្បីទទួលបានលទ្ធផល៣ខាងលើ៖

គម្រោងបានធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងជាសាធារណៈលើការរៀបចំផែនការ និងថវិកាមូលដ្ឋានរបស់ឃុំ និងស្រុកតាមរយៈវីដេអូ។ វីដេអូចំនួន ៣ ត្រូវបានបកប្រែ និងធ្វើចេញជាកូនសៀវភៅចំនួន ៣ គឺ ១) សៀវភៅស្តីពីសំឡេង ជម្រើស និងការសម្រេចចិត្ត ២) សៀវភៅព័ត៌មានអំពីថវិកាឃុំ ៣) សៀវភៅព័ត៌មានអំពីថវិកាស្រុក សម្រាប់ការយល់ដឹងជាសាធារណៈកម្មវិធីជជែកពិភាក្សាតុមូលចំនួន ១០ ដង និងវីដេអូឯកសារត្រូវបានបង្កើត និងផ្សព្វផ្សាយជាសាធារណៈ។ ២៣៦២គ្រួសារ ជាពិសេសយុវជន ស្ត្រី និងក្រុមដែលងាយរងគ្រោះត្រូវបានឈានដល់តាមរយៈសកម្មភាពតាមផ្ទះដោយផ្ទាល់ ដូច្នេះ ពួកគេបង្កើនការយល់ដឹងអំពីសិទ្ធិទទួលបានព័ត៌មានស្តង់ដានៃថវិកា និងសេវាកម្មសាធារណៈហើយពួកគេក៏បានទាមទារ ឲ្យ រដ្ឋាភិបាលមានព័ត៌មានសាធារណៈប្រសើរជាងមុន។

គម្រោងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលប្រើហ្វេសប៊ុកឃុំ ស្រុក។ ជាមធ្យមមានប្រហែល ៥ ទៅ ៥០ Post នៅក្នុងហ្វេសប៊ុកឃុំសង្កាត់ និងស្រុកនីមួយៗក្នុងមួយខែនៅក្នុងឃុំគោលដៅ និងស្រុកចំនួន ២៨ ដែលមានហ្វេសប៊ុក CBOs ចំនួន ៧ ផងដែរ។ ពួកគេបានpostមានសកម្មភាពដូចជាការប្រជុំប្រចាំខែរបស់ឃុំ និងស្រុក ព័ត៌មានអំពីសេវាកម្មឃុំ និងព័ត៌មានថវិកា ច្បាប់ / ច្បាប់ថ្មី / គោលការណ៍ណែនាំសកម្មភាពអភិវឌ្ឍន៍ឃុំ និងស្រុក។
គម្រោងពង្រឹងតម្លាភាពស្ថាប័នផ្តល់សេវារដ្ឋបាលមូលដ្ឋានរបស់ឃុំសង្កាត់ ស្រុក មណ្ឌលសុខភាព សាលាបឋមសិក្សា។ ទំព័រហ្វេសប៊ុកនៃឃុំ និងស្រុកគោលដៅទាំងអស់ និងអង្គការសហគមន៍មូលដ្ឋានមួយចំនួន (CBOs) ត្រូវបានដាក់ឱ្យដំណើរការ និងផ្សព្វផ្សាយព័ត៌មានសាធា រណៈជាមធ្យមប្រហែលជា ៥០ អត្ថបទក្នុងមួយខែ។ នេះរួមបញ្ចូលការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ និងស្រុក សេវាកម្មឃុំ ព័ត៌មានថវិកាច្បាប់ / ច្បាប់ថ្មី / គោលការណ៍ណែនាំ វេទិកាឃុំសង្កាត់ វេទិកាវៀបចំផែនការ និង

ការអភិវឌ្ឍមូលដ្ឋាន ការប្រជុំភូមិ ការបំរែបំរួលអាកាសធាតុការប្រជុំលទ្ធកម្ម ការគាំទ្រសិស្សក្រីក្រ គោលនយោបាយភូមិឃុំមានសុវត្ថិភាព ការប្រជុំក្របខ័ណ្ឌគណនេយ្យភាពសង្គម កិច្ចប្រជុំផែនការសកម្មភាពគណនេយ្យភាពរួម (JAAP) និងកិច្ចប្រជុំI4C។

សរុបមាន៣៣ឃុំ ៣សង្កាត់ ១ខណ្ឌ និង២ស្រុក ៨មណ្ឌលសុខភាព ៩ប៉ុស្តិ៍រដ្ឋបាលនគរបាល និង២២សាលាបឋមសិក្សាត្រូវបានបើកចំហព័ត៌មានសាធារណៈលើថវិកា និងស្តង់ដារនៃព័ត៌មានសេវាកម្មតម្លាភាពកាន់តែច្រើន។

អត្ថបទចំនួន ៦២ ត្រូវបានផ្សព្វផ្សាយនៅលើទំព័រហ្វេសប៊ុកផេករបស់APIដែលជាអត្ថបទដ៏មានប្រជាប្រិយភាព (១៦៣.៣K) ដល់សាធារណជន ប្រជាពលរដ្ឋជាពិសេសយុវជនបានចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលយុវជន និងគោលនយោបាយដែលមានអ្នក like ៦.៣ ខេនិង ៣២៤ ចែករំលែក។ ជាទូទៅអត្ថបទមួយចំនួនស្តីពីខ្លឹមសារព័ត៌មានសាធារណៈ និងការងារ API ទាក់ទងនឹងលើកកម្ពស់អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងលទ្ធភាពទទួលបានព័ត៌មានឈានដល់ប្រជាជនប្រមាណ ២,៧K នាក់ក្នុងមួយសប្តាហ៍។

បោះពុម្ពផ្សាយបដាចំនួន ២៤ ស្តីពីសិទ្ធិរបស់ពលរដ្ឋក្នុងការទទួលបានព័ត៌មានថវិកា និងដាក់បង្ហាញនៅវេទិកាចំនួន ២ និងនៅសាលាស្រុក និងឃុំ សង្កាត់។

- បោះពុម្ពកូនសៀវភៅចំនួន៣០០០ក្បាលស្តីអំពីថវិកាឃុំ ស្រុក និងត្រូវបានចែកចាយ និងផ្សព្វផ្សាយតាមខ្នងផ្ទះ និងក្នុងវេទិកាផ្សព្វផ្សាយស្តីពីថវិកា។
- បោះពុម្ព និងចែកចាយកូនសៀវភៅចំនួន៦០០ក្បាលស្តីអំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ ស្រុក។
- ចែកចាយកូនសៀវភៅចំនួន៦០០ក្បាលស្តីអំពីសិទ្ធិ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍឃុំ សង្កាត់ដល់អ្នកចូលរួមក្នុងវេទិកាសាធារណៈ។
- សកម្មភាពផ្សព្វផ្សាយតាមខ្នងផ្ទះស្តីអំពីផែនការអភិវឌ្ឍឃុំ សង្កាត់ ថវិកាឃុំ សង្កាត់ សិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមថវិកាឃុំ សង្កាត់ បានចំនួន១៧៨៩ខ្នងផ្ទះក្នុង៧ភូមិក្នុងឃុំគំរូនៃស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។
- បានផលិតប័ណ្ណព័ត៌មានប្រជាពលរដ្ឋនៅក្នុង៣សង្កាត់នៃខណ្ឌសែនសុខ ស្តីអំពីព័ត៌មានស្តង់ដារនៃរដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ មណ្ឌលសុខភាព និងសាលាបឋមសិក្សា (មាតិកាព័ត៌មានរបស់ប្រជាពលរដ្ឋត្រូវបានអនុម័តដោយ គ.ជ.អ.ប)
- ការផ្សព្វផ្សាយប័ណ្ណព័ត៌មានរបស់ប្រជាពលរដ្ឋ ដោយក្រុមCAFក្នុង៨ភូមិនៃសង្កាត់ ខ្មួញ និងសង្កាត់ឃ្លាងដែលមានអ្នកចូលរួម៣២៥នាក់ក្នុងនោះមានស្ត្រីចំនួន១៥១នាក់ អ្នកមានប័ណ្ណក្រី

ក្រចំនួន១៦នាក់ ជនដែលមានពិការភាពពនាក់ យុវជន៥០នាក់ និងស្ត្រីមេម៉ាយចំនួន១៩នាក់។

- បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន២ដែលមានអ្នកចូលរួមចំនួន១៦៨ ស្ត្រី៣៩ មកពីសាលាបឋមសិក្សា មណ្ឌលសុខភាព និងឃុំសង្កាត់ដែលគាំទ្របច្ចេកទេសដោយគ.ជ.អ.ប។ អ្នកចូលរួមបានយល់ដឹងពីដំណើរការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គមជាពិសេសក្នុងវិស័យអប់រំ សុខភាព និងរដ្ឋបាលឃុំ សង្កាត់។ ពួកគេយល់អំពីតួនាទីក្នុងការផ្តល់ព័ត៌មានជាសាធារណៈជាពិសេសព័ត៌មានស្តង់ដារដែលមាននៅក្នុង I4Cនៃក្របខណ្ឌគណនេយ្យភាពសង្គម។

## លទ្ធផលគម្រោងទី១២. ពង្រឹងសមត្ថភាពស្ថាប័ន និងការអនុវត្តសមាជិកសមាគមន៍ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្ត/ក្រុង

គម្រោង ចាប់ផ្តើមពីឆ្នាំ២០១៩ - ២០២១, គោលបំណងរួមនៃគម្រោង គឺពង្រឹងសមត្ថភាពស្ថាប័ន និងការអនុវត្តសមាជិកសមាគមន៍ថ្នាក់មូលដ្ឋានរាជធានី/ខេត្ត ស្រុក/ក្រុង ឃុំ/សង្កាត់ និងសមាជិកក្នុងខេត្តគោលដៅ ដើម្បីអោយពួកគាត់មានសមត្ថភាពក្នុងការចូលរួមលើកកំពស់ការងារគណៈនេយ្យភាព តម្លាភាព និងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងក្រុមងាយរងគ្រោះ។ អង្គការ វិទ្យាស្ថាន តស៊ូមតិ និងគោលនយោបាយ (អេ ភី អាយ - API) បានទទួលថវិកាចំនួន៩៩៥.០៣១អឺរ៉ូ នៃទំហំថវិកាសរុបចំនួន៩៧៧.៩៣៨អឺរ៉ូ ដែលត្រូវបានផ្តល់មូលនិធិពីអង្គការសហភាពអឺរ៉ុប និងអង្គការដៃគូរមូលនិធិមួយចំនួន។

### លទ្ធផល

គម្រោងបានគាំទ្រសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងខេត្តគោលដៅចំនួន៦ ដើម្បីបង្កើតនូវសមាជសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានថ្មីក្នុងខេត្តគោលដៅចំនួន៥ ដែលមានសមាជិកប្រមាណចំនួនជិត២០០០រូប ដើម្បីពង្រឹងសមត្ថភាពដល់ពួកគាត់អំពីការគ្រប់គ្រងប្រត្តិប័ត្ត និងបរិយាប័ណតាមរយៈការបោះឆ្នោតដោយសេរី ដោយអនុលោមទៅតាមគោលនយោបាយ និងផែនការរបស់ពួកគាត់។ សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន មានរចនាសម្ព័ន្ធច្បាស់លាស់ និងត្រូវបានអនុមត្តិដោយសមាជក្រុមប្រ្សឹភិបាលរបស់ពួកគាត់នៅចុងឆ្នាំ២០១៩។ គម្រោងបានជួយគាំទ្រដល់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងការកែសំអរន្ទូវលក្ខ័ន្តិកៈ គោលនយោបាយ សៀវភៅណែនាំក្នុងការគ្រប់គ្រង និងអនុវត្តបទបញ្ជាផ្ទៃក្នុង ផែនការ និងសៀវភៅគ្រប់គ្រងទូទៅ ដែលបានរួមបញ្ចូលនូវរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវ គោលនយោបាយ ការគ្រប់គ្រងទិន្នន័យ ការធានារ៉ាប់រង ក្រមសីលធម៍វិជ្ជាជីវៈការងារ និតិវិធីលទ្ធកម្ម និងយន្តការនៃការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ។ ជាងនេះទៀត គម្រោងក៏បានដាក់បញ្ចូលនូវផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩ -២០២១របស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានផងដែរ។ គម្រោងត្រូវតែធានាថាៈមានគោលនយោបាយស្របគ្នា ជាពិសេសតម្លៃនៃការធ្វើដំណើររបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានផ្សេងៗគ្នា ដែលមានសារៈសំខាន់សំរាប់ភាពជោគជ័យនៃការអនុវត្តគម្រោង។ អនុសារណៈនៃការយោគយល់គ្នា រវាងគម្រោង ជាមួយសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានទាំង៦ខេត្តគោលដៅ ត្រូវបានព្រមព្រាង និងចុះហត្ថលេខា ដោយកំណត់បានច្បាស់លាស់នូវតួនាទីនិងភារកិច្ច និងថវិកាលំអិតស្តីពីការពង្រឹងសមត្ថភាព តម្លាភាព និងគណនេយ្យភាពរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។ ជាងនេះទៀត ផែនការសកម្មភាព និងថវិកានៃការពង្រឹងសមត្ថភាពរបស់

គម្រោង គឺជាផ្នែកមួយនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៩ - ២០២១របស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននីមួយៗ។

គម្រោងបានបញ្ចប់នូវការសិក្សាស្រាវជ្រាវគ្រាដំបូងមុនពេលអនុវត្តគម្រោង។ ពត៌មាននៃការសិក្សាគ្រាដំបូងមុនពេលអនុវត្តគម្រោង ត្រូវបានប្រមូល និងបានបង្ហាញថាៈមានតែ៥៣.៥០%នៃផែនការគ្រប់គ្រង និងអនុវត្តស្ថាប័នត្រូវបានអនុវត្តដោយសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន អាស្រ័យដោយកំរិតកំណត់នៃសមត្ថភាព និងធនធានរបស់សមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន (ការគ្រប់គ្រងហិរញ្ញវត្ថុ បច្ចេកទេស និងភាពជាអ្នកដឹកនាំ)។

គម្រោងបានបញ្ចប់នូវការសិក្សាស្រាវជ្រាវអំពីស្ថាប័នជាមួយថ្នាក់ដឹកនាំ និងសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៃខេត្តគោលដៅទាំង៦។ ថ្នាក់ដឹកនាំ និងសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានទទួលស្គាល់នូវចំណេះដឹង តួនាទី ភារកិច្ច និងលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ និងពួកគាត់បានចូលរួមធ្វើផែនការពង្រឹងសមត្ថភាពរបស់ពួកគាត់ប្រកបដោយប្រសិទ្ធិភាពខ្ពស់។

ការបណ្តុះបណ្តាលសមត្ថភាពអំពីការគៀងគរធនធានមូលដ្ឋានដល់ថ្នាក់ដឹកនាំ និងលេខានៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន រយៈពេល៥ថ្ងៃ និងចំនួន២ថ្ងៃចុះពង្រឹងដល់មូលដ្ឋាន ដែលមានអ្នកចូលរួមសរុបចំនួន១២នាក់ ដោយមូលនិធិនៃអង្គការឆេងឌីហ្គេមអាកាដេមៀ និងអង្គការវិទ្យាស្ថាន តស៊ូមតិ និងគោលនយោបាយ (អេ ភី អាយ -API) និងអង្គការ ស៊ី ស៊ី ស៊ី ខេមបូឌៀ(CCC-Cambodia) បានធ្វើប្លង់មេរៀន ផែនការបង្រៀន និងមេរៀន។ពួកគាត់បានកើននូវសមត្ថភាពក្នុងការកំណត់នូវបញ្ហា និងចាត់អាទិភាពនៃបញ្ហាក្នុងការឆ្លើយតបនឹងតម្រូវការ កំណត់នូវស្ថាប័នដៃគូរ និងអាចរៀបចំនូវផែនការសកម្មភាពក្នុងការលើកសំណើររកនូវមូលនិធិមូលដ្ឋាន និងផែនការព្រឹត្តិការណ៍នានា សំរាប់ខេត្តគោលដៅទាំង៦។ សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន គឺជាអ្នកធ្វើសកម្មភាពក្នុងការគៀងគរធនធានមូលដ្ឋានរបស់ខ្លួន ដើម្បីពង្រឹងនូវតួនាទី និងភារកិច្ចរបស់ពួកគាត់ក្នុងការឆ្លើយតបនឹងតម្រូវការរបស់សហាគមន៍។ ថ្នាក់ដឹកនាំ និងលេខាទាំង១២រូប នៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន បានពង្រឹងសមត្ថភាព និងការអនុវត្តលើការងារគៀងគរធនធានមូលដ្ឋាននេះ។ គោលការណ៍ណែនាំនៃការអនុវត្តគម្រោងផ្តួចផ្តើមខ្នាតតូច ត្រូវបានកសាងដោយបានបញ្ជាក់ច្បាស់អំពីតម្រូវការនៃថវិកាបដិភាគពីប្រភពធនធាននានាក្នុងការឆ្លើយតបនឹងការដោះស្រាយនូវបញ្ហារបស់ប្រជាពលរដ្ឋ ក៏ដូចជាសមាជិកនៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

លទ្ធផលនៃការសិក្សាស្រាវជ្រាវគ្រាដំបូងនៃការអនុវត្តគម្រោងបានបញ្ជាក់ថា:៤៨.២% នៃសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដែលក្នុងនោះ បុរសចំនួន៤៩.២% និងស្ត្រីចំនួន៤៤.៧% បានកែលំអរនូវជំនាញ និងជឿជាក់លើសមត្ថភាពរបស់ខ្លួនក្នុងការដឹកនាំគម្រោងផ្តួចផ្តើមខ្នាតតូច និងសកម្មភាពសាកល្បងនានា ដើម្បីលើកកម្ពស់សមត្ថភាពរបស់ពួកគាត់ក្នុងការបំពេញនូវមុខងារជាជំរើស និងការអនុវត្តនូវមុខងារ តួនាទីរបស់ពួកគាត់ក្នុងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ សមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានជាងពាក់កណ្តាលទៀត ត្រូវការនូវការពង្រឹងសមត្ថភាពខ្លាំង ជាពិសេសចំពោះសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានថ្មីដែលទើបបានតែងតាំង/ ជាប់ដោយការបោះឆ្នោត(មកពីគណបក្សសមរង្ស៊ី) ក្រោយពីសមាជិកមកពីគណបក្សនេះត្រូវបានរំលាយ។ មានតែជាងពាក់កណ្តាលនៃសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន បានដឹងពីតួនាទី និងភារកិច្ចរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរាជធានី/ខេត្ត និងសម្ព័ន្ធភាពជាតិនៃសមាគមក្រុមប្រឹក្សាថ្នាក់រាជធានី/ខេត្ត ជាពិសេសចំពោះសមាជិកថ្មីដែលទើបតែបានជាប់ឆ្នោត ដែលមានចំនួនប្រមាណជា៤៣.៧%បានជឿជាក់ថា: ពួកគាត់បានបំពេញនូវតួនាទី និងភារកិច្ចក្នុងកំរិតចន្លោះពិន្ទុ ពី៥១%-៧០% នៃតួនាទី និងភារកិច្ចរបស់ពួកគាត់។ ជាងនេះទៀត ទិន្នន័យគ្រាដំបូងនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា:៥៤.៣%នៃសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដែលក្នុងនោះ៥៤.០%ជាបុរស និង៥៥.៣%ជាស្ត្រី ត្រូវបានកែលំអរនូវសមត្ថភាពជំនាញផ្នែកខាងអនុវត្តនូវមុខងារ និងការទទួលខុសត្រូវរបស់ពួកគាត់។

*យោងតាមការរកឃើញ និងការផ្តល់នូវអនុសាសន៍នៃការសិក្សាស្រាវជ្រាវអំពីបរិយប័ណ និងការសិក្សាស្រាវជ្រាវដំបូងនៃការអនុវត្តគម្រោង ត្រូវបានធ្វើបទបង្ហាញជូនទៅដល់ស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នសម្ព័ន្ធភាពជាតិ នៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងឱកាសនៃសិក្ខាសាលាស្វែងរកការគាំទ្រមតិ បានសង្កេតឃើញថា:ស្ថាប័នសម្ព័ន្ធភាពជាតិនៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរាជធានី/ខេត្តបានចាប់អារម្មណ៍ខ្លាំង និងសន្យាថានឹងយកចិត្តទុកដាក់នូវរាល់សំណើរបញ្ហារបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរាជធានី/ខេត្តគោលដៅទាំង៦ ដោយធ្វើការប្តេជ្ញាថា: នឹងចូលរួមជំរុញលើកទឹកចិត្តអោយមានស្ត្រីចូលរួមបានច្រើនក្នុងការងារថ្នាក់ដឹកនាំរបស់សមាគម ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងការស្នើសុំអោយមាននូវមូលនិធិសោធននិវត្តសំរាប់មន្ត្រីដែលបានធ្វើការបានយ៉ាងតិចចាប់ពីពអាណត្តិឡើងទៅ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវគ្រាដំបូងនៃការអនុត្តកម្រោងបានបង្ហាញថា: ៤៩.៥%របស់សមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៃខេត្តគោលដៅទាំង៦ ដែលក្នុងនោះ៤៨.៤%ជាបុរស និង៣១.៦%ជាស្ត្រី បានបង្ហាញថា: ពួកគាត់បានពេញចិត្តនូវការឆ្លើយតប*

*របស់ស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិលើបញ្ហានេះ ជាពិសេសចំពោះការឆ្លើយតបនឹងការស្វែងរកនូវការគាំទ្រមតិរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។*

*ស្ថាប័នសម្ព័ន្ធភាពជាតិនៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានទទួលស្គាល់នូវបញ្ហាដែលបានលើកឡើងក្នុងពេលបច្ចុប្បន្នរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងបានទទួលយកនូវរាល់អានុសាសន៍ទាំងនេះ។ ស្ថាប័នសម្ព័ន្ធភាពជាតិនៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក៏បានឯកភាពនិងតស៊ូមតិដើម្បីស្វែងរកនូវការគាំទ្រនូវរាល់បញ្ហាទាំងនោះទៅកាន់ស្ថាប័នថ្នាក់ខ្ពស់ៗ ជាពិសេសចំពោះអានុសាសន៍នៃការសុំអោយមាននូវមូលនិធិសោធននិវត្តចំពោះសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានដែលបានបំពេញការងារយ៉ាងតិចចាប់ពីពអាណត្តិឡើងទៅ និងការលើកទឹកចិត្តក្នុងការបង្កើនអោយមានស្ត្រីបានចូលរួមច្រើនក្នុងការងារដឹកនាំសកមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងការយកចិត្តទុកដាក់ជាអាទិភាពចំពោះអ្នកក្រីក្រ និងក្រុមដែលងាយរងគ្រោះនានានៅក្នុងសហគមន៍។ ចំពោះអានុសាសន៍របស់ក្រុមដែលងាយរងគ្រោះ និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានទាំងនោះ ត្រូវបានកត់ត្រាទុក និងត្រូវបានតស៊ូមតិដើម្បីស្វែងរកការគាំទ្រទៅកាន់ស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិលនានា និងដៃគូអភិវឌ្ឍន៍នានា ដើម្បីពិចារណានូវកិច្ចអន្តរាគមន៍។ បញ្ហាសំខាន់ៗចំនួនពីរ រួមទាំងបញ្ហានៃការលើកទឹកចិត្តស្ត្រីអោយចូលរួមបានច្រើនក្នុងការងារថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសំណើរអោយមាននូវប្រាក់សោធននិវត្តចំពោះសមាជិកណាដែលបានបំពេញការងារចាប់ពីពអាណតិតិ(១៥ឆ្នាំ)ឡើងទៅ ត្រូវបានយកចិត្តទុកដាក់ជាទីបំផុតដោយគ្រប់ភាគី។ គម្រោង ក៏នឹងពង្រឹងផងដែរនូវការប្រឹងប្រែងផ្នែកការស្វែងរកការគាំទ្រមតិជូនដល់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៃខេត្តគោលដៅទាំង៦នៅឯថ្នាក់ជាតិ និងគាំទ្រនូវការអនុវត្តគម្រោងដល់មន្ត្រីនូវឯកសារគតិយុត្តិថ្មីៗរបស់រាជរដ្ឋាភិបាល ដូចជា"អនុក្រិត្យស្តីពីការផ្ទេរមុខងារពីថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ស្រុក" និងការអនុម័ត្តិនូវផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប ឆ្នាំ២០២០ ដោយមានការបង្កើននូវផែនការថវិកា និងការទំលាក់ថវិកាទៅថ្នាក់ក្រោមជាតិចំនួន២០០% (ថវិការបស់ជាតិជាមធ្យមប្រចាំឆ្នាំចំនួន ១២៨.០០០ ដុល្លារសំរាប់ឃុំ/សង្កាត់នីមួយៗ និង៣០៧.១៦០ដុល្លារ សំរាប់ក្រុង/ស្រុកនីមួយៗ ជាពិសេសអំពីសេវាកម្មផ្នែកសង្គម ដែលនឹងត្រូវស្វែងរកនូវការគាំទ្រមតិដើម្បីទំលាក់នូវថវិកាចំនួន២០%សំរាប់ថ្នាក់ឃុំ ១០%សំរាប់ថ្នាក់ស្រុក នៃថវិកាសរុបប្រចាំឆ្នាំ២០២០ តទៅ និងការគាំទ្រដល់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តគោលដៅ និងថ្នាក់ដឹកនាំនៃសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងការចែករំលែកនូវបញ្ហា និងបទពិសោធន៍ល្អៗក្នុងការអនុវត្តជាក់ស្តែងជូនដល់បណ្តាញការងារថ្នាក់តំបន់តាមរយៈស្ថាប័ន ឡុកអ៊ីន អេស្ញី (LOGIN ASIA)។ ក្រុមការងារទាំងពីររួមមាន អង្គការអេភីអាយ (API) និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន (NLCs) គឺជាសមាជិកនៃស្ថាប័ន LOGIN ASIA។*

ម្យ៉ាងវិញទៀត ថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានទាំងអស់គ្នា បានទទួលស្គាល់ថាៈមានការខ្វះខាតនូវការគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រ និងក្រុមសហគមន៍ងាយរងគ្រោះ។ ពួកគាត់ទាំងអស់គ្នាក៏បានទទួលស្គាល់ថាៈ ការខ្វះខាតនូវធនធាន និងការផ្តួចផ្តើមគំនិត និងធ្វើសកម្មភាពក្នុងការជួយដល់ប្រជាពលរដ្ឋក្រីក្រ និងទន្ទឹមគ្នានេះផងដែរ ពួកគាត់ក៏ទទួលស្គាល់នូវការពេញចិត្តចំពោះការឆ្លើយតបដោយអជ្ញាធរមូលដ្ឋានជាប្រចាំ។ យោងទិន្នន័យនៃការសិក្សាដើមគ្រានៃការអនុវត្តគម្រោងបានបង្ហាញថាៈចំនួន២៧.៣%នៃប្រជាពលរដ្ឋដែលបានពិភាក្សា បានពេញចិត្តចំពោះការឆ្លើយតបនឹងកិច្ចអន្តរាគមន៍បន្ទាន់របស់ប្រជាពលរដ្ឋសហគមន៍មូលដ្ឋាន ដោយអជ្ញាមូលដ្ឋាន (យុវវ័យចំនួន៣៦.៤%, ជនពិការចំនួន០%, ប្រជាពលរដ្ឋក្រីក្រចំនួន៦០%, ស្ត្រីងាយរងគ្រោះចំនួន២៩.២%)។

គម្រោងបានចាប់ផ្តើមគាំទ្រដល់ថ្នាក់ដឹកនាំ និងសមាជិកទាំងអស់នៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានដើម្បីអនុវត្តភារកិច្ចរបស់ពួកគាត់ក្នុងគោលបំណងលើកកំពស់នូវគណនេយ្យភាព តម្លាភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមងាយរងគ្រោះ ដោយអង្គការសហគមន៍មូលដ្ឋាន ក្នុងវេទិការសាធារណៈក្នុងខេត្តពោធិ៍សាត់។ ក្នុងនោះ មានបញ្ហា សំនួរសរុបចំនួន ១៥៣ នៃបញ្ហា សំណួរសរុបចំនួន ២៥៣ របស់ប្រជាពលរដ្ឋនៃក្រុមងាយរងគ្រោះ ត្រូវបានដោះស្រាយក្នុងវេទិកាសាធារណៈក្នុងក្រុងពោធិ៍សាត់ និងក្នុងស្រុកក្រគរនៃខេត្តពោធិ៍សាត់។ ចំពោះបញ្ហា សំនួរទាំងអស់ដែលត្រូវបានលើកឡើងពាក់ព័ន្ធនឹងហេត្ថារចនាសម្ព័ន្ធ អគ្គិសនី ប្រព័ន្ធទឹកស្អាត ប្រព័ន្ធស្រោចស្រព្វ ដីធ្លី សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន និងសេវាសាធារណៈ ។ វាទិកាសាធារណៈផ្សេងៗដែលធ្វើអោយមានផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងក្រុមងាយរងគ្រោះអំពីគម្រោងផ្តួចផ្តើមខ្នាតតូច នឹងត្រូវអនុវត្តក្នុងខេត្តគោលដៅចាប់ពីឆ្នាំ២០២០តទៅ។
ប្រជាពលរដ្ឋច្រើនពាន់នាក់ បានដឹងអំពីគម្រោងដែលគាំទ្រថវិកាដោយអង្គការសហភាពអឺរ៉ុបសំរាប់សកម្មភាពពង្រឹងសមត្ថភាព ក៏ដូចជាទិដ្ឋភាពនៃបណ្តាញផ្សព្វផ្សាយសង្គមនានា និងគេហទំព័រសង្គមនានា។ ផែនការវីស៊ីប៊ីលីធី (Visibility) ផែនការនៃការពង្រឹងសមត្ថភាព និងក្របខ័ណ្ឌនៃការត្រួតពិនិត្យ និងវាយតម្លៃគម្រោង ត្រូវបានកសាងឡើង សំរាប់ការអនុវត្តគម្រោង ដែលប្រកបដោយការចែករំលែកនូវព័តមានទូលំទូលាយទៅដល់សមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដៃគូរអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នរដ្ឋ តាមរយៈការសម្ពោធន៍នៃការចាប់ផ្តើមអនុវត្តគម្រោង សិក្ខាសាលាចែករំលែកព័ត៌មានគម្រោងនៅថ្នាក់ខេត្ត បណ្តាញផ្សព្វផ្សាយសង្គម និងបណ្តាញសាធារណៈសង្គមនានា។ ប្រព័ន្ធបណ្តាញ ត្រួតពិនិត្យ និងវាយតម្លៃ អនឡាញ កំពុងកសាងតាមរយៈប្រព័ន្ធបច្ចេកវិជ្ជាថ្មី ដើម្បីវាស់វែងនូវទិន្នន័យប្រកបដោយកម្លាភាព និងភាពច្បាស់លាស់ផ្នែកហិរញ្ញវត្ថុ។ ប្រព័ន្ធនៃការកសាងបទពិសោធន៍

មេរៀននៃការអនុវត្តគម្រោង ត្រូវបានគ្រោងនិងកំពុងធ្វើតេសសាកល្បង ដែលពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន គឺធ្វើឡើងតាមរយៈប្រព័ន្ធសិក្សាពីបទពិសោធន៍ នៃការអនុវត្តគម្រោងរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៃខេត្តពោធិសាត់ ដែលកំពុងតែធ្វើការកែលំអរតាមរយៈការចុះបង្រៀនអនុវត្តផ្ទាល់ជាប្រចាំ។

## បទពិសោធន៍ មេរៀននានានៃការអនុបត្តគម្រោង

ការពន្យាពេលនៃសកម្មភាពនៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តគម្រោង បានធ្វើអោយការសិក្សាស្រាវជ្រាវគ្រាដំបូងនៃការអនុវត្តគម្រោងមានភាពលម្អៀងក្នុងការប្រៀបធៀបជាមួយនឹងលទ្ធផលនៃការសិក្សាស្រាវជ្រាវពេលចុងបញ្ចប់នៃការអនុវត្តគម្រោង។ វាក៏បានប្រាប់នូវព័ត៌មានលំអិតនានារបស់គម្រោងជូនដល់សមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានដែលត្រូវបានជ្រើសរើសថ្មី រចនាសម្ព័ន្ធគ្រប់គ្រងថ្មី និងភាពជាអ្នកដឹកនាំថ្មី របស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៃខេត្តគោលដៅទាំងអស់ផងដែរ។

មានទំនាក់ទំនងល្អទៅវិញទៅមកក្នុងចំណោមអជ្ញាធរមូលដ្ឋានគ្រប់កំរិត ជាមួយនឹងស្ថាប័នសង្គមស៊ីវិលនានានៃខេត្តគោលដៅទាំងអស់។ សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តពោធិសាត់ បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការតភ្ជាប់ជាមួយសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានគ្រប់ខេត្តគោលដៅទាំងអស់ ជាមួយអង្គការ អេ ភី អាយ (API) និងអង្គការ អេ អ៊ី អេ(AEA)។

ក្រៅពីសេចក្តីរំពឹងទុកនៃការអនុវត្តគម្រោង ការសិក្សាស្រាវជ្រាវក៏បានរកឃើញថាៈ ចំនួនច្រើនជាង ៩៥%នៃសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងខេត្តគោលដៅទាំងអស់ មានទូរស័ព្ទស្មាតហ្វូនប្រើ ដែលជាចំនុចល្អក្នុងការជួយដល់ការអនុវត្តគម្រោងស្តីពីវេទិកានៃការសិក្សាបទពិសោធន៍មេរៀន និងការអនុវត្តគម្រោងតាមប្រព័ន្ធអនឡាញ។

គម្រោងនេះ បានផ្តល់ជាដំបូងគេបង្អស់នូវឱកាសដល់សមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងខេត្តគោលដៅទាំងអស់ អាចវាយតម្លៃថ្នាក់ដឹកនាំនៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។ ជាងនេះទៀត ថ្នាក់ដឹកនាំនៃក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងខេត្តគោលដៅ អាចបើកចិត្តទូលាយក្នុងការទទួលយកនូវរាល់លទ្ធផលនៃការវាយតម្លៃដោយសមាជិករបស់ខ្លួន និងចូលរួមយ៉ាងសកម្មក្នុងការចូលរួមធ្វើផែនការអភិវឌ្ឍន៍ដើម្បីកែលម្អរនូវស្ថាប័នរបស់ពួកគាត់។

សមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងខេត្តគោលដៅ និងថ្នាក់ដឹកនាំទាំងអស់ បានទទួលស្គាល់នូវកង្វះខាតក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ និងក្រុមងាយរងគ្រោះ (ទាំងលក្ខណៈបុគ្គល និងជាលក្ខណៈគ្រួសារ) និងក្រុមចាស់ជរាផងដែរ។

**បញ្ហានានាដែលបានជួបប្រទះ**

- ថ្មីៗនេះ ស្ថាប័នសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិនានា មានបុគ្គលិកបង្គោលអនុវត្តគម្រោងចំនួន២រូប។ ពួកគាត់បានចំណាយពេលវេលាយូរក្នុងការជ្រើសរើសបុគ្គលិក និងបន្ទាប់មក ក៏សុំលាលែងពីតំណែង និងជ្រើសរើសនូវអ្នកដែលត្រូវជំនួសថ្មី (ដូចជាប្រធានគម្រោង ខេត្តពោធិ៍សាត់ និង មន្ត្រីជាន់ខ្ពស់ ផ្នែកត្រួតពិនិត្យ និងវាយតម្លៃគម្រោង)។
- ការពន្យាពេលនៃការណែនាំពីគម្រោងរហូតដល់ក្រោយពីការបោះឆ្នោតជ្រើសរើសសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីធ្វើអោយសមាជិកដែលត្រូវបានជ្រើសតាំងថ្មី បានស្វែងយល់ និងចូលរួមក្នុងដំណើរការអនុវត្តគម្រោង គឺជាបញ្ហាគន្លឹះដែលធ្វើអោយការអនុវត្តគម្រោងមានភាពយឺតយ៉ាវ។
- ការជ្រើសរើសទីប្រឹក្សាឯករាជ បានចំណាយនូវពេលប្រហែលជា៦ខែ និងបានចំណាយពេលជាង៦ខែបន្ថែមទៀតក្នុងការសិក្សាស្រាវជ្រាវគ្រាដំបូងនៃការអនុវត្តគម្រោង និងបញ្ចប់នូវរបាយការណ៍សិក្សាស្រាវជ្រាវចំនួន២ គឺរបាយការណនៃការសិក្សាស្រាវជ្រាវគ្រាដំបូងនៃការអនុវត្តគម្រោង និងរបាយការណ៍នៃការសិក្សាស្រាវជ្រាវស្តីពីការលើកកម្ពស់ និងការប្រតិបត្តិរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ពីព្រោះការផ្លាស់ប្តូរនូវសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ស្រុក/ក្រុង ក្នុងពាក់កណ្តាលនៃឆ្នាំ២០១៩ និងការផ្លាស់ប្តូរនូវសមាភាពនៃថ្នាក់ដឹកនាំ និងសមាជិកខ្លះនៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានគោលដៅទាំងអស់។

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ អគារភ្នំពេញវីឡាលេខ ១២៤ ជាន់ទី ២ បន្ទប់លេខ ២០៦ ផ្លូវលេខ ៣៨៨ សង្កាត់ទួលស្វាយព្រៃ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (+855) 23 213 486 (+855) 23 213 487 www.apiinstitute.org ។ ហ្វេសប៊ុក: Advocacy and Policy Institute